# នៅចំពោះមុខអង្គបុរេជំនុំជម្រះ
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ៖ ០០៣/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ)

ភាគីដាក់ឯកសារ៖ សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី

ដាក់ជូន៖ អង្គបុរេជំនុំជម្រះ

ភាសាដើម៖ អង់គ្លេស

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី៧ ខែមីនា ឆ្នាំ២០១១

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 30-Mar-2019, 13:20
CMS/CFO: Sann Rada

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ៖ សម្ងាត់

ចំណាត់ថ្នាក់ឯកសារដោយ អ.ប.ជ៖ សម្ងាត់/Confidential

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្ដោះអាសន្ន៖

ឈ្មោះមន្ត្រីកត់ត្រា៖

ហត្ថលេខា៖

---

# បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាស្ដីពីភាពអាចទទួលស្គាល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី

---

ដាក់ដោយ៖

**សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖**

ជេត វណ្ណលី
ហុង គឹមសួន
ឡោ ជុនធី
សំ សុគង់
ស៊ិន សុវ៉ន
ទី ស្រីនណា

វ៉ែន ពៅ
Martine JACQUIN
Daniel MCLAUGHLIN
Nushin SARKARATI

នៅចំពោះមុខ៖

**អង្គបុរេជំនុំជម្រះ**

ចៅក្រម ប្រាក់ គឹមសាន
ចៅក្រម Olivier BEAUVALLET
ចៅក្រម ន័យ ថុល
ចៅក្រម BAIK Kang Jin
ចៅក្រម ហួត វុទ្ធី

ផ្ញើជូន៖

**សហចៅក្រមស៊ើបអង្កេត**

ចៅក្រម យូ ប៊ុនឡេង

ចៅក្រម Michael BOHLANDER

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

Laure DESFORGES
Isabelle DURAND
Michael (Yiqiang) LIU
Christine MARTINEAU

គឹម ម៉េងឃី

**សហព្រះរាជអាជ្ញា**

ជា លាង

Nicholas KOUMJIAN

**សហមេធាវីការពារក្តី មាស មុត**

អាង ឧត្តម

Michael G. KARNAVAS

## I. ប្រវត្តិនីតិវិធី

1. នៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់*ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ លើកទី២ របស់សហព្រះរាជអាជ្ញាទាក់ទងទៅនឹងកងទ័ពបដិវត្តកម្ពុជា* ("ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី២") ដើម្បីបើកកិច្ចស៊ើបសួរលើ ស៊ូ ម៉េត និង មាស មុត[1]។ នៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ សហចៅក្រមស៊ើបអង្កេត (ស.ច.ស) បានចេញសេចក្តីជូនដំណឹងបញ្ជាក់ថា កិច្ចស៊ើបសួរបានបញ្ចប់សព្វគ្រប់[2]។ នៅថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១១ ស.ច.ស អន្តរជាតិបានសម្រេចថា កិច្ចស៊ើបសួរលើសំណុំរឿង ០០៣ ដែលបានធ្វើឡើងមកទល់សព្វថ្ងៃនេះ មាន វិការៈ និងប៉ះពាល់ដល់ភាគីទាំងអស់ ហើយបានបង្គាប់ឱ្យបើកកិច្ចស៊ើបសួរឡើងវិញ[3]។ នៅថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៣ ស.ច.ស បានជូនដំណឹងភាគីថា ស៊ូ ម៉េត បានទទួលមរណភាព[4] ហើយកិច្ចដំណើរការនីតិវិធីប្រឆាំងនឹង ស៊ូ ម៉េត ត្រូវបានបញ្ចប់នៅថ្ងៃទី២ ខែមិថុនា ឆ្នាំ២០១៥[5]។ នៅថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៤ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ដោយបានបញ្ជាក់បំភ្លឺអំពីវិសាលភាពនៃកិច្ចស៊ើបសួរនៅក្នុងសំណុំរឿង ០០៣ ហើយបានបន្ថែមបទឧក្រិដ្ឋនៃអាពាហ៍ពិពាហ៍ដោយបង្ខំ (រួមទាំង ការរំលោភសេពសន្ថវៈ) ផងដែរ[6]។ នៅថ្ងៃទី១០ ខែមករា ឆ្នាំ២០១៧ ស.ច.ស អន្តរជាតិបានបន្ថយវិសាលភាពនៃការស៊ើបអង្កេតអនុលោមតាមវិធាន ៦៦*ស្ទួន*[7] ហើយបានចេញ*សេចក្តីជូនដំណឹងអំពីការបិទការស៊ើបសួរប្រឆាំង មាស មុត*[8]

---

[1] សំណុំរឿង ០០៣ ឯកសារ D1 ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ លើកទី២ របស់សហព្រះរាជអាជ្ញាទាក់ទងទៅនឹងកងទ័ពបដិវត្តកម្ពុជា ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ [ចាប់ពីពេលនេះទៅហៅថា "ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី២"]។

[2] សំណុំរឿង ០០៣ ឯកសារ D13 សេចក្តីជូនដំណឹងស្តីពីការបញ្ចប់កិច្ចស៊ើបសួរ ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១។

[3] សំណុំរឿង ០០៣ ឯកសារ D28 ដីកាសម្រេចស្តីអំពីការបើកការស៊ើបអង្កេតបឋមឡើងវិញ ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១១។

[4] សំណុំរឿង ០០៣ ឯកសារ D86 ការជូនដំណឹងអំពីការស្លាប់របស់ជនសង្ស័យម្នាក់នៅក្នុងសំណុំរឿង ០០៣ ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៣ កថាខណ្ឌ ៥។

[5] សំណុំរឿង ០០៣ ឯកសារ D86/3 ការលើកលែងការចោទប្រកាន់ប្រឆាំង ស៊ូ ម៉េត ចុះថ្ងៃទី២ ខែមិថុនា ឆ្នាំ២០១៥ ទំព័រ ៧។

[6] សំណុំរឿង ០០៣ ឯកសារ D120 ដីកាបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីពីទីតាំងឧក្រិដ្ឋកម្មនានាទាក់ទងនឹងសំណុំរឿង ០០៣ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៤ កថាខណ្ឌ ២០។

[7] សំណុំរឿង ០០៣ ឯកសារ D226 ដីកាសម្រេចកាត់បន្ថយវិសាលភាពនៃកិច្ចស៊ើបសួរយោងតាមវិធានផ្ទៃ ៦៦*ស្ទួន* ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៧។

[8] សំណុំរឿង ០០៣ ឯកសារ D225 សេចក្តីជូនដំណឹងអំពីការបិទការស៊ើបសួរប្រឆាំង មាស មុត ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១៧។

។ បន្ទាប់មក សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់ដីកាសន្និដ្ឋានស្ថាពរ អនុលោមតាមវិធាន ៦៦ នៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៧[9]។

2. នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ស.ច.ស បានចេញដីកាដំណោះស្រាយដាច់ដោយឡែកពីគ្នានៅក្នុងសំណុំរឿង ០០៣។ ស.ច.ស ជាតិ បានចេញដីកាដំណោះស្រាយ លើកលែងការចោទប្រកាន់ប្រឆាំងនឹង មាស មុត ដោយបានសម្រេចថា អ.វ.ត.ក ពុំមានយុត្តាធិការបុគ្គលលើជននេះ ក្នុងនាមជាមេដឹកនាំជាន់ខ្ពស់ ឬ អ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងសម័យខ្មែរក្រហមនោះឡើយ[10]។ ក្រោយពេលលើកលែងការចោទប្រកាន់ទាំងអស់លើ មាស មុត រួចហើយ ស.ច.ស ជាតិពុំបានពិនិត្យមើលភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០៣ នោះទេ។ ផ្ទុយទៅវិញ ស.ច.ស អន្តរជាតិ បានសម្រេចថា អ.វ.ត.ក ពិតជាមានយុត្តាធិការលើ មាស មុត នៅក្នុងដីកាដំណោះស្រាយ (“ដីកាដំណោះស្រាយរបស់ ស.ច.ស.អ”)[11] ហើយបានចេញសេចក្តីសម្រេចលើអង្គសេចក្តីនៃភាពអាចទទួលយកបាននៅក្នុងដីកាសម្រេចដោយឡែក (“ដីកាសម្រេចលើភាពអាចទទួលយកបាន”)[12] ក្នុងនោះ គាត់បានច្រានចោលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួននៅក្នុងសំណុំរឿង ០០៣។ ឧបសម្ព័ន្ធ ខ ភ្ជាប់ជាមួយដីកាសម្រេចស្តីពីភាពអាចទទួលយកបាន បង្ហាញមូលដ្ឋានលម្អិតដែល ស.ច.ស អន្តរជាតិ បានសំអាង ហើយសម្រេចថា ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៦០៤ នៅក្នុងសំណុំរឿង ០០៣ មិនអាចទទួលយកបាន[13]។ សំណៅបកប្រែជាភាសាអង់គ្លេសនៃដីកាដំណោះស្រាយរបស់ ស.ច.ស ជាតិ បានជូនដំណឹងដល់ភាគីនៅថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០១៩ ចំណែកសំណៅបកប្រែជាភាសាខ្មែរនៃដីកាដំណោះស្រាយរបស់ ស.ច.ស អន្តរជាតិ បានជូនដំណឹងដល់ភាគីនៅថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៩។ សំណៅបកប្រែជាភាសាខ្មែរនៃដីកាសម្រេច

---

[9] សំណុំរឿង ០០៣ ឯកសារ D226/7 ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិអនុលោមតាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៧។

[10] សំណុំរឿង ០០៣ ឯកសារ D266 ដីកាសម្រេចលើកលែងការចោទប្រកាន់ មាស មុត ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨។

[11] សំណុំរឿង ០០៣ ឯកសារ D267 ដីកាដំណោះស្រាយ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ [ចាប់ពីពេលនេះតទៅហៅថា “ដីកាដំណោះស្រាយរបស់ ស.ច.ស.អ”]។

[12] សំណុំរឿង ០០៣ ឯកសារ D269 ដីកាសម្រេចលើភាពអាចទទួលស្គាល់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ [ចាប់ពីពេលនេះតទៅហៅថា “ដីកាស្តីពីភាពអាចទទួលយកបាន”]។

[13] សំណុំរឿង ០០៣ ឯកសារ D269.2 ឧបសម្ព័ន្ធ ខ៖ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលមិនត្រូវបានទទួលស្គាល់ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨។

របស់ ស.ច.ស អន្តរជាតិ អំពីភាពអាចទទួលយកបាន និងឧបសម្ព័ន្ធ ខ ភ្ជាប់ជាមួយនឹងដីកាសម្រេចលើភាពអាចទទួលយកបាន បានជូនដំណឹងដល់ភាគីនៅថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៩ និងថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៩ ដាច់ដោយឡែកពីគ្នា។

3. សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ធ្វើជាតំណាងអាណត្តិឱ្យអ្នកដាក់ពាក្យសុំ ដែលត្រូវបានច្រានចោលនៅក្នុងដីកាសម្រេចអំពីភាពអាចទទួលយកបាន (ម្ចាស់បណ្តឹងឧទ្ធរណ៍) ដូចបានបង្ហាញនៅក្នុងឧបសម្ព័ន្ធ ក ភ្ជាប់ជាមួយនឹងបណ្តឹងឧទ្ធរណ៍នេះ។

## II. បទដ្ឋាននៃបណ្តឹងឧទ្ធរណ៍

4. វិធាន ៧៧*ស្ទួន* ចែងអំពីការពន្លឿនដំណើរការបណ្តឹងឧទ្ធរណ៍ក្នុងការចេញសេចក្តីសម្រេចលើភាពអាចទទួលយកបានលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ យោងតាមវិធាន ៧៧*ស្ទួន* "ក្នុងរយៈពេល ១០ ថ្ងៃ ចាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីសម្រេចអំពីភាពអាចទទួលយកបាននូវពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ម្ចាស់បណ្តឹងឧទ្ធរណ៍ត្រូវដាក់បណ្តឹងឧទ្ធរណ៍នេះដោយមានបញ្ជាក់អំពីមូលហេតុដែលថា សហចៅក្រមស៊ើបអង្កេតមានការភ័ន្តច្រឡំលើអង្គហេតុ និង/ឬ អង្គច្បាប់ក្នុងការសម្រេចអំពីភាពអាចទទួលយកបាននូវពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនេះ ដោយអនុលោមតាមវិធាន ២៣ *ស្ទួន*"[14]។

5. នៅក្នុងបណ្តឹងឧទ្ធរណ៍ "កំហុសលើអង្គច្បាប់ដែលបានលើកឡើងត្រូវបានពិនិត្យ*ជាថ្មីឡើងវិញ* ដើម្បីពិចារណាថាតើសេចក្តីសម្រេចផ្លូវច្បាប់មានលក្ខណៈត្រឹមត្រូវដែរឬអត់ ហើយកំហុសលើអង្គហេតុត្រូវបានពិនិត្យឡើងវិញ ស្របតាមបទដ្ឋានស្តីពីភាពសមស្រប ដើម្បីសម្រេចថា តើ អ្នកវិនិច្ឆ័យឥតលម្អៀងទៅលើអង្គហេតុ ពិតជាមិនអាចធ្វើសំអាងហេតុផ្នែកអង្គហេតុដែលបានលើកឡើងនេះ ឬយ៉ាងណា"[15]។

## III. ភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍

[14] វិធាន ៧៧*ស្ទួន* នៃវិធានផ្ទៃក្នុង អ.វ.ត.ក (វិ.លើកទី៩)។

[15] សំណុំរឿង ០០២ ឯកសារ D404/2/4 សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៣៤។

6. ភាគីក្នុងសំណុំរឿង ០០៣ បានជូនដំណឹងអំពីដីកាសម្រេចស្តីពីភាពអាចទទួលយកបាននៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨។ នៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៩ សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០៣ បានដាក់សំណើរួមសុំពន្យាររយៈពេល និងចំនួនទំព័រចំពោះបណ្តឹងឧទ្ធរណ៍ អនុលោមតាមវិធាន ៧៧*ស្ទួន* ហើយស្នើសុំអនុញ្ញាតដាក់ជាភាសាតែមួយសិន[16]។ នៅថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១៩ អង្គបុរេជំនុំជម្រះ (អ.ប.ជ) បានយល់ព្រមតាមសំណើសុំពន្យាររយៈពេល និងបង្កើនចំនួនទំព័រ ដោយបានពន្យារកាលបរិច្ឆេទលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងភាពមិនអាចទទួលយកបាននៃដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០៣ រហូតដល់ ៣០ ថ្ងៃ គិតចាប់ពីថ្ងៃជូនដំណឹងអំពីដីកាដំណោះស្រាយរបស់ ស.ច.ស.អ និងឧបសម្ព័ន្ធ ខ ភ្ជាប់ជាមួយដីកាសម្រេចស្តីពីភាពអាចទទួលយកបាន ជាភាសាខ្មែរ ព្រមទាំងបានបង្កើនចំនួនទំព័រដល់ ៤៥ ទំព័រ ជាភាសាអង់គ្លេស ឬ ៩០ ទំព័រ ជាភាសាខ្មែរ និងបានអនុញ្ញាតឲ្យដាក់តែមួយភាសាជាមុនសិន។

7. បណ្តឹងឧទ្ធរណ៍នេះបានដាក់ទាន់ពេលវេលា ក្នុងរយៈពេល ៣០ ថ្ងៃ គិតចាប់ពីថ្ងៃជូនដំណឹងអំពីសំណៅបកប្រែជាភាសាខ្មែរនៃដីកាដំណោះស្រាយរបស់ ស.ច.ស.អ និងឧបសម្ព័ន្ធ ខ នៃដីកាសម្រេចអំពីភាពអាចទទួលយកបាន ហើយស្របតាមការកម្រិតចំនួន ៤៥ ទំព័រ ជាភាសាអង់គ្លេស ដែលបានអនុញ្ញាតដោយ អ.ប.ជ។ ក្រោយពីទទួលបានការអនុញ្ញាតពី អ.ប.ជ បណ្តឹងឧទ្ធរណ៍បានដាក់ជាភាសាអង់គ្លេស។ សំណៅបកប្រែជាភាសាខ្មែរនៃបណ្តឹងឧទ្ធរណ៍ និងឧបសម្ព័ន្ធភ្ជាប់ជាមួយនឹងបណ្តឹងឧទ្ធរណ៍នេះ នឹងត្រូវដាក់ជូនក្នុងពេលឆាប់ៗនៅពេលដែលការបកប្រែរួចរាល់។

## IV. សេចក្តីសន្និដ្ឋានបឋម

8. សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានផ្តល់សេចក្តីសន្និដ្ឋានបឋមចំនួនពីរដូចខាងក្រោម។

9. ចំណុចទី១ ដូច អ.ប.ជ បានទទួលស្គាល់ គោលដៅ និងគោលបំណងនៃវិធាន ២៣*ស្ទួន* គឺដើម្បីកំណត់លក្ខណៈវិនិច្ឆ័យនៃភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ពុំ

[16] សំណុំរឿង ០០៣ ឯកសារ D269/1 សំណើបន្ទាន់របស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សុំបន្ថែមពេលវេលា និងបង្កើនចំនួនទំព័រដើម្បីដាក់បណ្តឹងឧទ្ធរណ៍ជំទាស់ទៅនឹងសេចក្តីសម្រេចពីភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០៣ ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៨។

មែនដើម្បីកំណត់ ឬ រិតត្បិតទស្សនទាននៃបណ្តឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅ អ.វ.ត.ក[17]។ វិធាន ២៣*ស្ទួន*ត្រូវអានរួមជាមួយនឹងវិធាន ២១ ដែលកំណត់គោលការណ៍គ្រឹះនៃ អ.វ.ត.ក រួមទាំង ឯកសារស្នូលរបស់ អ.វ.ត.ក ដែលត្រូវបកស្រាយដើម្បីការពារជាប់ជានិច្ចនូវផលប្រយោជន៍ និងធានាថា សិទ្ធិរបស់ពួកគេត្រូវបានគោរពនៅគ្រប់កិច្ចដំណើរការនីតិវិធី[18]។

10. ម្យ៉ាងវិញទៀត វិធាន ២៣*ស្ទួន*ត្រូវអានរួមគ្នាជាមួយនឹងគោលការណ៍ និងគោលបំណងទូលំទូលាយរបស់តុលាការ ដូចមានចែងនៅក្នុងកិច្ចព្រមព្រៀង អ.វ.ត.ក និងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក[19]។ ដូច អ.ប.ជ បានទទួលស្គាល់នៅក្នុងសំណុំរឿង ០០២ "កិច្ចព្រមព្រៀងបានចែងថា គោលការណ៍ជាសារវន្តមួយ ក្នុងការបង្កើត អ.វ.ត.ក គឺ "ការបង្រួបបង្រួមជាតិ"។ ចំណុចនេះជាការបង្ហាញដល់ចៅក្រម ក៏ដូចជាអង្គជំនុំជម្រះនៅ អ.វ.ត.ក ឲ្យស្វែងរកទាំងការពិតស្តីពីហេតុការណ៍ដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជា ក៏ដូចជាការយកចិត្តទុកដាក់ពិសេស និងការធានាថាមានការចូលរួមប្រកបដោយអត្ថន័យរបស់ជនរងគ្រោះនៃអំពើឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត ដែលនេះគឺជាផ្នែកមួយនៃការបង្រួបបង្រួមជាតិ"[20]។ ជាការពិត អ.ប.ជ បានសម្រេចស្របគ្នាថា "ការបញ្ចូលដើមបណ្តឹងរដ្ឋប្បវេណីទៅកនុងដំណើរការនីតិវិធីគឺជាការទទួលស្គាល់ការបន្តការបង្រួបបង្រួមជាតិ"[21]។ អាស្រ័យហេតុនេះ សិទ្ធិជាមូលដ្ឋានរបស់ជនរងគ្រោះ ដូចមានចែងនៅក្នុងឯក

---

[17] សំណុំរឿង ០០២ ឯកសារ D404/2/4 សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៦២។

[18] សំណុំរឿង ០០២ ឯកសារ D404/2/4 សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៦១។

[19] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី៦ ខែមីនា ឆ្នាំ២០០៣ ("កិច្ចព្រមព្រៀង")។ ច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បូកបញ្ចូលជាមួយច្បាប់វិសោធនកម្មដែលបានប្រកាសឲ្យប្រើនៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ (នស/រកត/១០០៣/០០៦) ("ច្បាប់ អ.វ.ត.ក")។

[20] សំណុំរឿង ០០២ ឯកសារ D404/2/4 សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៦៥ (ដកស្រង់បុព្វកថានៃកិច្ចព្រមព្រៀង)។

[21] សាលដីកាអំពីការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងរឿងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទ នួន ជា ឯកសារ C11/53 ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៨ កថាខណ្ឌ ៣៧។ *សូមមើលផងដែរ* សំណុំរឿង ០០២

សារស្នូលរបស់ អ.វ.ត.ក ពោលគឺ វិធាន ២១ និងវិធាន ២៣*ស្ទួន* និងតួនាទីសំខាន់របស់ដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងស្វែងរកការផ្សះផ្សាជាតិ ត្រូវតែជាគោលការណ៍ណែនាំសម្រាប់ អ.ប.ជ នៅក្នុងការពិនិត្យមើលឡើងវិញលើដីកាសម្រេចស្តីពីភាពអាចទទួលយកបាន និងបណ្តឹងឧទ្ធរណ៍បច្ចុប្បន្ន។

11. ចំណុចទីពីរ អ.ប.ជ គួរបញ្ជាក់បំភ្លឺអំពីឋានៈរបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០៣ ដោយសារថា ស.ច.ស មានការខ្វែងយោបល់គ្នាលើយុត្តាធិការ និងលទ្ធផលនៃការប្រព្រឹត្តខុសគ្នាលើពាក្យសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណី។

12. ដីកាសម្រេចស្តីពីភាពអាចទទួលយកបានបង្កើតឲ្យមានអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីពីរប្រភេទ៖ (១) អ្នកដាក់ពាក្យសុំដែលត្រូវបានទទួលយកដោយ ស.ច.ស អន្តរជាតិ និងពុំបានពិនិត្យដោយ ស.ច.ស ជាតិ[22] និង (២) អ្នកដាក់ពាក្យសុំដែលត្រូវបានច្រានចោលដោយ ស.ច.ស អន្តរជាតិ និងពុំបានពិនិត្យដោយ ស.ច.ស ជាតិ[23]។ ដោយហេតុថា ស.ច.ស ជាតិបដិសេធមិនពិនិត្យលើពាក្យសុំឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី ស.ច.ស ទាំងពីរពុំមានការព្រមព្រៀងគ្នាលើអង្គសេចក្តី ពាក់ព័ន្ធនឹងមូលដ្ឋានសម្រាប់ភាពអាចទទួលយកបាននៃដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០៣។

13. សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សូមរម្លឹកថា អនុលោមតាមវិធាន ២៣*ស្ទួន*(២) ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ត្រូវទទួលបានសច្ចធារណ៍នៃភាពអាចទទួលយកបាន "លើកលែង និងលុះត្រាតែ" ច្រានចោលជាស្ថាពរពី ស.ច.ស[24]។ និយាយជាទូទៅជាងនេះ ការពិចារណា

---

ឯកសារ D404/2/4 សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៦៥។

[22] សំណុំរឿង ០០៣ ឯកសារ D269.1 ឧបសម្ព័ន្ធ ក៖ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវបានទទួលស្គាល់ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨។

[23] សំណុំរឿង ០០៣ ឯកសារ D269.2 ឧបសម្ព័ន្ធ ខ៖ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលមិនត្រូវបានទទួលស្គាល់ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨។

[24] វិធាន ២៣*ស្ទួន* (២) ("[...] សហចៅក្រមស៊ើបអង្កេតអាចបដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរហូតដល់កាលបរិច្ឆេទចេញដីកាដំណោះស្រាយ។ ដីកានេះត្រូវបើកផ្លូវឲ្យប្តឹងឧទ្ធរណ៍សង្ខេបទៅអង្គបុរេជំនុំជម្រះដោយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដូចដែលមានចែងក្នុងសេចក្តីណែនាំអនុវត្ត។ បណ្តឹងឧទ្ធរណ៍សង្ខេបនេះមិនផ្អាកដំណើរការនីតិវិធីទេ។

លើបញ្ហាដើមបណ្ដឹងរដ្ឋប្បវេណី រួមទាំងភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ត្រូវបកស្រាយស្របតាមកម្មវត្ថុ បរិបទ និងគោលបំណងនៃការចូលរួមរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ដែលតម្រូវឱ្យតុលាការ "យកចិត្តទុកដាក់ពិសេស និងការធានាថា មានការចូលរួមប្រកបដោយអត្ថន័យរបស់ជនរងគ្រោះនៃអំពើឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត ដែលនេះគឺជាផ្នែកមួយនៃការបង្រួបបង្រួមជាតិ"[25]។ អាស្រ័យហេតុនេះ ភាពមិនប្រាកដប្រជាពាក់ព័ន្ធនឹងពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរប្បវេណី គួរបានជាប្រយោជន៍ដល់ភាពអាចទទួលយកបាននៃពាក្យសុំនេះ។

14. អ.ប.ជ គួរបញ្ជាក់ថា អ្នកតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ប្រភេទទី១ ត្រូវបានទទួលស្គាល់ជាដើមបណ្ដឹងរដ្ឋប្បវេណី ដោយសារគោលការណ៍សច្ចធារណ៍នៃភាពអាចទទួលយកបាន និងសេចក្ដីសម្រេចរបស់ ស.ច.ស អន្តរជាតិ ដែលបានសម្រេចទទួលយកពួកគេជាដើមបណ្ដឹងរដ្ឋប្បវេណី។ សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីសន្និដ្ឋានថា សច្ចធារណ៍នៃភាពអាចទទួលយកបាននេះបន្តអនុវត្តចំពោះគ្រប់ដើមបណ្ដឹងរដ្ឋប្បវេណីទាំងនេះ "លើកលែង និងលុះត្រាតែ" មានសេចក្ដីសម្រេចភាគច្រើនលើសលប់ រួមជាមួយនឹងសំអាងហេតុពី អ.ប.ជ បង្ហាញផ្ទុយពីនេះ។

15. ស្រដៀងគ្នានេះដែរ អ.ប.ជ គួរសម្រេចថា សច្ចធារណ៍នៃភាពអាចទទួលយកបានចំពោះអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ពុំអាចជំនួសដោយសេចក្ដីសម្រេចរបស់ ស.ច.ស តែម្នាក់នោះទេ។ ជាលទ្ធផល អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ប្រភេទទី២ ដែលត្រូវបានច្រានចោលដោយ ស.ច.ស អន្តរជាតិ ហើយពុំបានទទួលពិនិត្យដោយ ស.ច.ស ជាតិ គួរបន្តអនុវត្តសិទ្ធិរបស់ដើមបណ្ដឹងរដ្ឋប្បវេណី "លើកលែង និងលុះត្រាតែ" មានសេចក្ដីសម្រេចភាគច្រើនលើសលប់ រួមជាមួយនឹងសំអាងហេតុពី អ.ប.ជ បង្ហាញផ្ទុយពីនេះ។

16. ជាជម្រើសមួយទៀត ប្រសិនបើ អ.ប.ជ យល់ឃើញថា ស.ច.ស អន្តរជាតិ អាចច្រានចោលពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ម្ចាស់បណ្ដឹងឧទ្ធរណ៍ដោយឯកតោភាគីបាននោះ សហ

---

លើកលែង និងលុះត្រាតែពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីត្រូវបានបដិសេធចោល អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីអាចអនុវត្តសិទ្ធិជាដើមបណ្ដឹងរដ្ឋប្បវេណីបាន"។

[25] សំណុំរឿង ០០២ ឯកសារ D404/2/4 សាលដីកាលើគ្រប់បណ្ដឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៦៥។

មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីសូមសន្និដ្ឋានថា ដីកាសម្រេចស្តីពីភាពអាចទទួលយកបាន មានកំហុសអង្គច្បាប់ និងអង្គហេតុដូចបានកំណត់នៅក្នុងសេចក្តីសន្និដ្ឋានចំបងៗខាងក្រោម។

## V. សារណាចម្បង

17. ស.ច.ស អន្តរជាតិ មានកំហុសអង្គច្បាប់ និងអង្គហេតុយ៉ាងច្បាស់ក្រឡែតដោយសារច្រានចោលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍។ ចំណុចទី១ ស.ច.ស អន្តរជាតិ បានកំណត់ឧក្រិដ្ឋកម្មដោយខុសច្បាប់ សម្រាប់ការសម្រេចលើភាពអាចទទួលយកបាននៃដើមបណ្តឹងរដ្ឋប្បវេណី ដោយកំណត់ផ្តាច់មុខចំពោះឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ថាបានប្រព្រឹត្តឡើងនៅក្នុងតំបន់ស្វយ័តកំពង់សោម ឬ នៅក្នុងតំបន់ដែនទឹកសមុទ្រ និងកោះនៅម្តុំឆ្នេរនៃរបបកម្ពុជាប្រជាធិបតេយ្យ។ ការធ្វើដូច្នេះ ស.ច.ស អន្តរជាតិ ពុំអើពើការចោទប្រកាន់ថា មាស មុត បានចូលរួមនៅក្នុងសហឧក្រិដ្ឋកម្មរួមនៅក្នុងក្របខ័ណ្ឌជាតិ (JCE) និងបានបកស្រាយមិនត្រឹមត្រូវលើសច្ចធារណ៍នៃព្យសនកម្មជាសមូហភាព ដែលពង្រីកហូតដល់គ្រប់សមាជិកនៃក្រុមគោលដៅ ដោយមិនខ្វល់ពីទីតាំងពួកគេឡើយ។ ចំណុចទី២ ដីកាសម្រេចស្តីពីភាពអាចទទួលយកបានមានចំហុសដោយសារបានដកចេញអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលពុំធ្លាប់ទទួលរងព្យសនកម្មនៅតាមទីតាំងឧក្រិដ្ឋកម្ម ដែលដំបូង ជាផ្នែកមួយនៃការស៊ើបអង្កេតលើសំណុំរឿង ០០៣ ហើយក្រោយមកត្រូវបានដកចេញ អនុលោមតាមវិធាន ៦៦។ ដូចបានបង្ហាញលម្អិតនៅក្នុងមូលដ្ឋានទី៣ និងមូលដ្ឋានទី៤ នៃបណ្តឹងឧទ្ធរណ៍ ដីកាសម្រេចស្តីពីភាពអាចទទួលយកបាន ក៏ខកខានមិនបានបង្ហាញសេចក្តីសម្រេចដែលមានសំអាងហេតុចំពោះការច្រានចោលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងមានកំហុសនៅក្នុងការច្រានចោលអ្នកដាក់ពាក្យសុំដោយសារខកខានមិនបានផ្តល់ព័ត៌មានគ្រប់គ្រាន់ និងមូលដ្ឋានពាក់ព័ន្ធ។

### ក. មូលដ្ឋានទី១ នៃបណ្តឹងឧទ្ធរណ៍៖ ស.ច.ស អន្តរជាតិ មានកំហុសអង្គច្បាប់ និងអង្គហេតុដោយបានសម្រេចថា លក្ខខណ្ឌតម្រូវពីទំនាក់ទំនង អនុលោមតាមវិធាន ២៣*ស្ទួន*(១)(ខ) បានបំពេញដោយជនរងគ្រោះនៃឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅតំបន់ស្វយ័តកំពង់សោម ឬ នៅដែនទឹក និងកោះនៅម្តុំឆ្នេរនៃរបបកម្ពុជាប្រជាធិតេយ្យ

18. ស.ច.ស អន្តរជាតិ មានកំហុសអង្គច្បាប់ និងអង្គហេតុដោយសារខកខានមិនបានសម្រេចថា ជនរងគ្រោះនៃគោលនយោបាយទូទាំងប្រទេស ក៏ទទួលរងពន្យសនកម្មដោយផ្ទាល់ ដោយសារលទ្ធ

ផលនៃឧក្រិដ្ឋកម្មដែលបានចោទប្រកាន់លើ មាស មុត[26]។ សេចក្ដីសម្រេចកម្រិតភាពអាចទទួលយកបាននៃដើមបណ្ដឹងរដ្ឋប្បវេណីត្រឹមឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅតំបន់ស្វយ័តកំពង់សោម ឬ នៅក្នុងដែនទឹក និងកោះមុំផ្នែរនៃរបបកម្ពុជាប្រជាធិបតេយ្យ ពុំស៊ីសង្វាក់គ្នាជាមួយនឹងការបកស្រាយរបស់ អ.ប.ជ លើលក្ខខណ្ឌចំណងទាក់ទងរវាងជនរងគ្រោះ និងឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ ដូចមានចែងនៅក្នុងវិធាន ២៣*ស្ទួន*(១)(ខ)។

19. វិធាន ២៣*ស្ទួន*(១)(ខ) ទាមទារលក្ខខណ្ឌថា អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីត្រូវបង្ហាញ "ព្យសនកម្មខាងរូបរាងកាយ ខាងសម្ភារ ឬ ផ្លូវចិត្ត" ដែលកើតចេញដោយសារ "លទ្ធផលផ្ទាល់ពីបទឧក្រិដ្ឋ យ៉ាងហោចណាស់មួយនៃបទឧក្រិដ្ឋជាច្រើនដែលត្រូវបានចោទប្រកាន់លើជនត្រូវចោទ"[27]។ នៅក្នុងដីកាសម្រេចស្ដីពីភាពអាចទទួលយកបាន ស.ច.ស អន្តរជាតិ ទទួលស្គាល់យុត្តិសាស្ត្ររបស់ អ.ប.ជ ថា លក្ខខណ្ឌចំណងហេតុ និងបច្ច័យគួរត្រូវបកស្រាយ "ក្នុងន័យទូលាយ" ដោយធ្វើយ៉ាងណាវាគួរអនុញ្ញាត "ឲ្យទទួលស្គាល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីដែលការចោទប្រកាន់អំពីព្យសនកម្មរបស់ពួកគាត់ មិនចាំបាច់ទាល់តែកើតឡើងពីបទឧក្រិដ្ឋ ដែលបានប្រព្រឹត្តនៅទីតាំងដែលបានកំណត់ក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា ឬ នៅក្នុងដីកាដំណោះស្រាយនោះទេ"[28]។ ដីកាសម្រេចស្ដីពីភាពអាចទទួលយកបាន ខកខានមិនបានគោរពតាមយុត្តិសាស្ត្ររបស់ អ.ប.ជ លើបញ្ហានេះ ដោយបានបដិសេធឋានៈរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ចំពោះជនរងគ្រោះនៃឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងអនុលោមតាគោលនយោបាយសម្របសម្រួលថ្នាក់ជាតិ អនុវត្តឡើងតាមរយៈសហឧក្រិដ្ឋកម្មរួម (JCE)។ ស្រដៀងគ្នានេះដែរ ដីកាស្ដីពីភាពអាចទទួលយកបានខកខានមិនបានអនុវត្តគោលការណ៍របស់ អ.ប.ជ ស្ដីពីព្យសនកម្មជាសមូហភាព ដែលពង្រីកឋានៈដើមបណ្ដឹងរដ្ឋប្បវេណីរហូតដល់សមាជិកនៃក្រុមគោលដៅ ឬ សហគមន៍ដូចគ្នា ដោយមិនគិតពីទីតាំងរបស់ពួកគេ។ ចំណុចចុងក្រោយ ដីកាសម្រេចស្ដីពីភាពអាចទទួលយកបានមើលរំលងដោយប្រយោលអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមប

---

[26] ដីកាសម្រេចស្ដីពីភាពអាចអាចទទួលយកបាន នៅត្រង់កថាខណ្ឌ ៣៦-២៧។

[27] វិធាន ២៣*ស្ទួន*(១)(ខ)(ការគូសបញ្ជាក់បន្ថែម)។

[28] ដីកាសម្រេចស្ដីពីភាពអាចអាចទទួលយកបាន នៅត្រង់កថាខណ្ឌ ៣៥។ សំណុំរឿង ០០២ ឯកសារ D404/2/4 សាលដីកាលើគ្រប់បណ្ដឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៤៩, ៦៦, ៦៨-៦៩, ៧២, ៧៧។

ណ្តឹងរដ្ឋប្បវេណី ដែលទទួលរងព្យសនកម្មពីគោលនយោបាយ និងឧក្រិដ្ឋកម្មដែលអនុវត្ត *នៅក្នុង*ទីតាំងឧក្រិដ្ឋកម្ម និងតំបន់ ដែលបានរៀបរាប់នៅក្នុងដីកាដំណោះស្រាយរបស់ ស.ច.ស អន្តរជាតិ។

**១. អ.ប.ជ គួរទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណីចំពោះជនរងគ្រោះនៃគោលនយោបាយ និងឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ប្រឆាំងនឹង មាស មុត ដែលត្រូវបានអនុវត្តនៅទូទាំងកម្ពុជា ផ្នែកមួយនៃ JCE មិនមែនត្រឹមតែនៅក្នុងតំបន់ដែលបានកំណត់ នៅក្នុងដីកាស្តីពីភាពអាចទទួលយកបាននោះឡើយ។**

20. ដីកាសម្រេចស្តីពីភាពអាចទទួលយកបាន មិនអើពើចំពោះសេចក្តីសម្រេចពីមុនរបស់ អ.ប.ជ ស្តីពីភាពអាចទទួលយកបាននៃដើមបណ្តឹងរដ្ឋប្បវេណី ដោយផ្តោតលើតែឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងតំបន់ស្វយ័តកំពង់សោម ឬ នៅក្នុងដែនទឹក និងកោះនៅតាមម៉ុំផ្ទេរនៃរបបកម្ពុជាប្រជាធិបតេយ្យ បោះទោះជាការចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយរបស់ ស.ច.ស.អ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីពីរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ដែល មាស មុត បានចូលរួម និងអនុវត្តគោលនយោបាយក្រោម JCE ដែលមានវិសាលភាពនៅទូទាំងប្រទេស។ វិធាន ២៣*ស្ទួន* (១)(ខ) ចែងច្បាស់ ហើយ អ.ប.ជ បញ្ជាក់ច្បាស់ថា លក្ខខណ្ឌចំណងទាក់ទងមិនមែនអាស្រ័យលើព្យសនកម្ម និងអង្គហេតុដែលស៊ើបអង្កេតដោយ ស.ច.ស នោះទេ ប៉ុន្តែ គឺរវាងព្យសនកម្ម និង*ឧក្រិដ្ឋកម្មដែលបានចោទប្រកាន់*[29]។ ភាពខុសគ្នាដ៏សំខាន់នេះគឺរវាងអង្គហេតុ និងអង្គច្បាប់ ដែលមានឧក្រិដ្ឋកម្ម "គឺជាការកំណត់បទចោទទៅលើស្ថានភាពអង្គហេតុដែលត្រូវបានធ្វើការស៊ើបអង្កេត"[30]។

---

[29] វិធាន ២៣*ស្ទួន*(១)(ខ)(ការគូសបញ្ជាក់បន្ថែម)។ សំណុំរឿង ០០២ ឯកសារ D404/2/4 សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៤៩, ៦៦, ៦៨-៦៩, ៧២, ៧៧។

[30] សំណុំរឿង ០០២ ឯកសារ D404/2/4 សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៤២។ *សូមមើលផងដែរ* រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Ayyash និងអ្នកផ្សេងទៀត* STL-11-01/PT/PTJ, F0879 សេចក្តីសម្រេចទី៤ ស្តីពីការចូលរួមរបស់ជនរងគ្រោះនៅក្នុងកិច្ចដំណើរការនីតិវិធី ចុះថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៣ កថាខណ្ឌ ១៥ (សម្រេចថា លក្ខខណ្ឌចំណងរវាងហេតុ និងបច្ច័យ ស្ថិតនៅត្រង់ "ព្យសនកម្មដែលបានចោទប្រកាន់ ជាមួយនឹងឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ជាក់លាក់នៅក្នុងដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះ" ហើយបានពន្យល់ថា "ការអានបែបនេះផ្តល់

21. នៅក្នុងសំណុំរឿង ០០២ អង្គជំនុំជម្រះបានសន្និដ្ឋានថា ស.ច.ស បានច្រានចោលដោយមិនត្រឹមត្រូវលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដោយបានកំណត់លក្ខខណ្ឌដោយមានកំហុសថា អ្នកដាក់ពាក្យសុំបានភ្ជាប់ចំណាងព្យសនកម្មរបស់ពួកគេជាមួយព្រឹត្តិការណ៍អង្គហេតុដែលបានស៊ើបអង្កេត ដូចបានបង្ហាញនៅក្នុងដីកាដំណោះស្រាយ[31]។ អ.ប.ជ បានកត់សម្គាល់ថា "បើទោះបីជាអង្គហេតុដែលត្រូវស៊ើបអង្កេតកំណត់ត្រឹមតែទៅលើតំបន់ ឬ ទីតាំងឧក្រិដ្ឋកម្មមួយចំនួនក៏ដោយ [...] បានរួមបញ្ចូលនូវឧក្រិដ្ឋកម្មដែលតំណាងឲ្យអំពើឃោរឃៅជាទ្រង់ទ្រាយធំ ដែលត្រូវបានចោទប្រកាន់ថា [...] បានធ្វើឡើងរួមគ្នាក្នុងពេលអនុវត្តសហឧក្រិដ្ឋកម្មរួម [...] ប្រឆាំងនឹងប្រជាជន និង "នៅទូទាំងប្រទេស""[32]។ អ.ប.ជ បានសម្រេចថា "វាគឺជាការកំណត់បទចោទទៅលើស្ថានភាពអង្គហេតុដែលត្រូវធ្វើការស៊ើបអង្កេត [ពោលគឺ ឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់] ហើយមិនមែនជាស្ថានភាពអង្គហេតុដែលត្រូវធ្វើការស៊ើបអង្កេតនោះទេ ដែល [ស.ច.ស] គួរធ្វើការពិចារណា"[33]។

22. នៅក្នុងករណីដែលដីកាដំណោះស្រាយសម្រេចថា ការវាយប្រហារប្រឆាំងនឹងប្រជាជនស៊ីវិលមានលក្ខណៈរាលដាល ឬ ជាប្រព័ន្ធ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី "មិនចាំបាច់ត្រូវបង្ហាញពីទំនាក់ទំនងរវាងព្យសនកម្មរបស់ខ្លួនទៅនឹងទីតាំងឧក្រិដ្ឋកម្មតែមួយ ឬ ទីតាំងឧក្រិដ្ឋកម្មនានាដែលមានរៀបរាប់នៅក្នុងផ្នែកសន្និដ្ឋានទៅលើអង្គហេតុ" នៅក្នុងដីកាដំណោះស្រាយ ជាពិសេស នៅពេល "បទឧក្រិដ្ឋទាំងនោះ និងគោលនយោបាយជាមូលដ្ឋានរបស់ខ្មែរក្រហមបាន

លក្ខណៈតាមផ្លូវច្បាប់ចំពោះដែនកំណត់នៃធាតុផ្សំហេតុ និងបច្ច័យ ដូច្នេះ វាផ្តល់ភាពកាន់តែជាក់លាក់ និងរឹងមាំ" ដល់ដំណើរការចូលរួមរបស់ជនរងគ្រោះ)។

[31] សំណុំរឿង ០០២ ឯកសារ D404/2/4 សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៤២។

[32] សំណុំរឿង ០០២ ឯកសារ D404/2/4 សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៤២ (សេចក្តីយោងខាងក្នុងត្រូវបានលុបចោល)។

[33] សំណុំរឿង ០០២ ឯកសារ D404/2/4 សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៤២។

បង្កើតជាមូលដ្ឋាននៃដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានអនុវត្តនៅទូទាំងប្រទេសកម្ពុជា”[34]។ អ្វីដែលគួរកត់សម្គាល់ អ.ប.ជ បានគូសបញ្ជាក់ថា “ការទទួលយកជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងទិដ្ឋភាពនៃអំពើឃោរឃៅជាទ្រង់ទ្រាយធំគួរ [...] សំដៅដល់បរិបទដែលឆ្លើយតបទៅនឹងសកម្មភាពដែលប្រព្រឹត្តយ៉ាងទូលំទូលាយ និងជាប្រព័ន្ធ ដែលកើតចេញពីការអនុវត្តនូវគោលនយោបាយទាំងនេះនៅទូទាំងប្រទេស ដែលក្នុងនោះការទទួលខុសត្រូវជាលក្ខណៈបុគ្គលដែលបានចោទប្រកាន់លើជនជាប់ចោទម្នាក់ៗគួរធ្វើជាលក្ខណៈរួមវិញ ដោយសារមានការចោទប្រកាន់ពីការធ្វើសកម្មភាពរួមគ្នាជាផ្នែកមួយនៃសហឧក្រិដ្ឋកម្មរួម”[35]។

23. ជំហររបស់ អ.ប.ជ នៅក្នុងសំណុំរឿង ០០២ អនុវត្តក្នុងអានុភាពស្មើគ្នានៅក្នុងសំណុំរឿង ០០៣។ យោងតាមដីកាដំណោះស្រាយរបស់ ស.ច.ស.អ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីពីរ និងដីកាបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម មាស មុត បានចូលរួមនៅក្នុង JCE នៅកម្រិតទូទាំងប្រទេស ដែលគោលបំណងរបស់វាគឺអនុវត្តគោលនយោបាយ ប.ក.ក នៅទូទាំងប្រទេស ក្រៅពីតំបន់ស្វយ័តកំពង់សោម ឬ ដែនទឹក និងកោះនៅមុំឆ្នេរនៃរបបកម្ពុជាប្រជាធិបតេយ្យ[36]។ ប.ក.ក

[34] សំណុំរឿង ០០២ ឯកសារ D404/2/4 សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៧២ (សេចក្តីយោងខាងក្នុងត្រូវបានលុបចោល)។

[35] សំណុំរឿង ០០២ ឯកសារ D404/2/4 សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៧៨។ អ្វីដែលគួរឲ្យកត់សម្គាល់ ជនជាប់ចោទអាចត្រូវបានចាប់ឲ្យទទួលខុសត្រូវព្រហ្មទណ្ឌចំពោះការចូលរួមនៅក្នុងសហឧក្រិដ្ឋកម្មរួម (JCE) “ទោះជាការចូលរួមចំណែកជាដុំកំភួនរបស់គាត់ចំពោះសហឧក្រិដ្ឋកម្មនោះ បានកើតឡើងនៅក្នុងតំបន់ភូមិសាស្ត្រតូចមួយជាងនេះក៏ដោយ” ឲ្យតែ “គាត់បានដឹងអំពីគោលបំណងទូលំទូលាយនៃផែនការរួមនោះ”។ រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Sesay, Kallon និង Gbao* SCSL-04-15-T សាលក្រម ចុះថ្ងៃទី២ ខែមីនា ឆ្នាំ២០០៩ កថាខណ្ឌ ២៦២។

[36] ដីកាដំណោះស្រាយរបស់ ស.ច.ស.អ កថាខណ្ឌ ៥៦២ (“មាស មុត... និងកម្មាភិបាលកងទ័ពបដិវត្តន៍កម្ពុជាជាន់ខ្ពស់ដទៃទៀត មានគោលបំណងរួមក្នុងការអនុវត្តគោលនយោបាយរបស់ ប.ក.ក ដូចខាងក្រោម៖ i) ការបង្កើតសហករណ៍ និងការដ្ឋានពលកម្មដោយបង្ខំ ii) ការអប់រំ “សមាសភាពមិនល្អ” និង “ការសម្លាប់ខ្មាំង” ទាំងក្នុង និងក្រៅជួរយោធា iii) ការកំណត់មុខសញ្ញាក្រុមជាក់លាក់ ជាពិសេស អ្នកទាំងឡាយណាដែលជាជនជាតិភាគតិច ឬ ជនជាតិវៀតណាម និងថៃ (ទាំងពិតប្រាកដ និងតាមការសន្មត) ព្រមទាំងអតីតបុគ្គលិកយោធា និងប្រជាជនស៊ីវិល iv) ការអនុវត្តការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំលើប្រជាជនស៊ីវិល និងយោធានៃកងទ័ពបដិវត្តន៍កម្ពុជា”)។ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី២ កថាខណ្ឌ ៣៣, ៩៧។ សំណុំរឿង ០០៣ ឯកសារ D120 ដីកាបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីពីទីតាំងឧក្រិដ្ឋកម្មនានាទាក់ទងនឹងសំណុំរឿង ០០៣ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៤ កថាខណ្ឌ ២០, ២៦។

រក្សាប្រើប្រាស់ប្រព័ន្ធដែលមានការរៀបចំត្រឹមត្រូវសម្រាប់អនុវត្តគោលនយោបាយថ្នាក់ជាតិតាមរយៈបណ្តាញសហគ្រាសនៅថ្នាក់តំបន់ ដែលរួមបញ្ចូលតំបន់ក្រោមបញ្ជារបស់ មាស មុត ផង ដែរ។ ប្រតិបត្តិការទាំងមូលត្រូវបានរៀបចំឡើងដើម្បីជម្រុញ*គោលបំណងជាតិ*គឺការកសាងសង្គមកម្ពុជាទាំងមូលឡើងវិញ[37]។ ដូចបានលើកឡើងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី២ មាស មុត បានចូលរួមពាក់ព័ន្ធខ្លាំងនៅក្នុងការបង្កើតគោលនយោបាយជាតិ និង "បានចូលរួមនៅក្នុងអង្គប្រជុំអគ្គសេនាធិការជាញឹកញាប់ ដែលចូលរួមដោយលេខា និងអនុលេខា" នៃកងពលរបស់កងទ័ពបដិវត្តន៍កម្ពុជា ដែលនៅទីនោះ គាត់រួមជាមួយ "លេខា និងអនុលេខា ក.ប.ក ចំនួន ១៣ នាក់ បានបញ្ជាក់អំពីការគាំទ្រ" ផែនការបោសសម្អាត "ខ្សែក្បត់" នៅក្នុងកងទ័ពបដិវត្តន៍កម្ពុជានៅទូទាំងប្រទេស[38]។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី២ កត់សម្គាល់បន្ថែមទៀតអំពីលិខិតឆ្លើយឆ្លងជាញឹកញាប់រវាង មាស មុត ជាមួយ "ថ្នាក់ដឹកនាំកំពូល" នៃ ប.ក.ក រួមទាំង ប៉ុល ពត នួន ជា អៀង សារី និង សុន សេន ពាក់ព័ន្ធនឹងការកាប់សម្លាប់ជនជាតិថៃ និងវៀតណាមដែលត្រូវបានចាប់ខ្លួន និងការបោសសម្អាតនៃសមាជិកកងទ័ពបដិវត្តន៍កម្ពុជា[39]។ លិខិតឆ្លើយឆ្លងនេះបង្ហាញថា ការចូលរួមរបស់ មាស មុត នៅក្នុង JCE ជាតិ ត្រូវបានដឹងដល់ និងសម្របសម្រួលជាមួយនឹងកម្រិតខ្ពស់បំផុតនៃថ្នាក់ដឹកនាំ ប.ក.ក ក្នុងក្របខណ្ឌថ្នាក់ជាតិ។

24. ដូចបានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយរបស់ ស.ច.ស.អ មាស មុត បានកាន់កាប់ "តួនាទីដែលកាន់តែឡើងឋានៈខ្ពស់ទៅៗ នៅក្នុងឋានានុក្រមរបស់កម្ពុជាប្រជាធិបតេយ្យ ដោយបំពេញភារកិច្ចក្នុងកម្រិតខ្ពស់ នៅក្នុងរចនាសម្ព័ន្ធបញ្ជាការកងទ័ពកម្ពុជាប្រជាធិបតេយ្យដែលស្ថិតនៅក្រោមការដឹកនាំរបស់អ្នកនយោបាយថ្នាក់ជាតិ"[40]។ មាស មុត គឺជាមេបញ្ជាការកងពល ១៦៤ ដែលជា

---

[37] ដីកាដំណោះស្រាយរបស់ ស.ច.ស.អ កថាខណ្ឌ ១៧៥ ("គោលដៅរបស់ ប.ក.ក គឺដើម្បីប្រែក្លាយកម្ពុជាប្រជាធិបតេយ្យទៅជាសង្គមកសិកម្មទំនើប")។ *ដូចខាងលើ* ត្រង់កថាខណ្ឌ ១៨១ ("គោលនយោបាយ[កម្ទេត់ "ខ្មាំង" ឬ "សមាសភាពមិនល្អ"] ត្រូវបានអនុញ្ញាតតាមមាត្រា ១០ នៃរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ ដែលចែងថា "*សកម្មភាពប្រឆាំង និងបំផ្លិចបំផ្លាញដែលមានលក្ខណៈជាខ្សែសង្វាក់ ហើយគ្រោះថ្នាក់ដល់រដ្ឋរបស់ប្រជាជន ត្រូវផ្តន្ទាទោសកម្រិតខ្ពស់បំផុត*")។ *ដូចខាងលើ* ត្រង់កថាខណ្ឌ ២០០ (ពន្យល់ថា "គោលនយោបាយស្តីពីការរៀបអាពាហ៍ពិពាហ៍" ត្រូវបានអនុវត្តដើម្បី "សម្រេចកំណើនប្រជាជន និងមិនឱ្យមានការរៀបការរវាង "សមាសភាពមិនល្អ" ជាមួយនឹងអ្នកមានប្រវត្តិ "ល្អ" ទេ និង "ជាមធ្យោបាយ ដើម្បីជំរុញបដិវត្តន៍សង្គមនិយម")។

[38] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី២ កថាខណ្ឌ ៨៨។

[39] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី២ កថាខណ្ឌ ៩២-៩៣។

[40] ដីកាដំណោះស្រាយរបស់ ស.ច.ស.អ កថាខណ្ឌ ៤៦១។

កងពលធំបំផុតនៃយោធាកម្ពុជាប្រជាធិបតេយ្យ ដែលរួមបញ្ចូលទាំងកងទ័ពជើងទឹក និងកងទ័ពជើងគោក។ តាមតួនាទីនេះ ព្រមទាំងតួនាទីរបស់គាត់ "ជាសមាជិកបម្រុងនៃគណៈកម្មាធិការអគ្គសេនាធិការ និងជាអនុប្រធានរបស់ សុន សេន" មាស មុត "បានដឹងពីសកម្មភាពទាំងអស់របស់ ប.ក.ក នៅក្នុងតំបន់ដែលគាត់ទទួលខុសត្រូវ"[41]។ លើសពីនេះ មាស មុត គឺជាលេខាតំបន់ស្វយ័តកំពង់សោម ដែលអាចឲ្យគាត់គ្រប់គ្រងរដ្ឋបាលលើសកម្មភាពរបស់ជនស៊ីវិល[42]។ ដីកាដំណោះស្រាយរបស់ ស.ច.ស.អ សម្រេចថា មាស មុត "ទទួលខុសត្រូវបំពេញភារកិច្ច និងកាតព្វកិច្ចក្នុងកម្រិតខ្ពស់លេចធ្លោជាង អោ អាន យ៉ាងខ្លាំង ដែលត្រូវបានរកឃើញថា ជាអ្នកទទួលខុសត្រូវខ្ពស់បំផុតមួយរូបផងដែរ" ដោយ ស.ច.ស អន្តរជាតិ នៅក្នុងសំណុំរឿង ០០៤/២[43]។ ផ្អែកតាមមុខតំណែង និងអានុភាពនៃសកម្មភាពរបស់គាត់ ស.ច.ស អន្តរជាតិ បានសន្និដ្ឋានថា កម្រិតនៃការទទួលខុសត្រូវរបស់គាត់ "គឺពិតជាលើសពីអំពើរបស់ អោ អាន អ៊ឹម ចែម និងកាំង ហ្កេកអ៊ាវ ហៅ ឌុច យ៉ាងច្បាស់ក្រឡែតមែនហើយ"[44]។ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី២ និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម បង្ហាញលម្អិតអំពីរបៀប ដែល មាស មុត បានទទួលការងារអនុវត្តគោលនយោបាយជាតិនៃ ប.ក.ក នៅថ្នាក់តំបន់ ដោយសារមុខតំណែងដឹកនាំដូចបានចោទប្រកាន់លើរូបគាត់ រួមមាន៖ (i) ការដាក់ប្រជាជនឲ្យទៅជាទាសករនៅតាមសហករណ៍ ឬការដ្ឋានការងារដោយបង្ខំ (ii) ការអប់រំ ឬ ការកំចាត់ខ្មាំង ប.ក.ក តាមរយៈបណ្ដាញមន្ទីរសន្តិសុខ និងការដ្ឋានកាប់សម្លាប់ (iii) ការកំណត់គោលដៅក្រុមជនសង្ស័យ ដូចជា ជនជាតិថៃ និងវៀតណាម និង (iv) អាពាហ៍ពិពាហ៍ដោយបង្ខំ[45]។ ដីកាដំណោះស្រាយ ស.ច.ស.អ បានរកឃើញថា មាស មុត អនុវត្ត និងបាន "ចូលរួមចំណែកសំខាន់" នៅក្នុងគោលនយោបាយជាតិទាំងបួន[46]។ ជា

---

[41] ដីកាដំណោះស្រាយរបស់ ស.ច.ស.អ កថាខណ្ឌ ៥៦៥។

[42] ដីកាដំណោះស្រាយរបស់ ស.ច.ស.អ កថាខណ្ឌ ១៥៩-៦១។

[43] ដីកាដំណោះស្រាយរបស់ ស.ច.ស.អ កថាខណ្ឌ ៤៦១។ សំណុំរឿង ០០៤/២ ឯកសារ D360 ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ កថាខណ្ឌ ៦៩៩។

[44] ដីកាដំណោះស្រាយរបស់ ស.ច.ស.អ កថាខណ្ឌ ៤៦០។

[45] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី២ កថាខណ្ឌ ៣៣-៣៤។ សំណុះរឿង ០០៣ ឯកសារ D120 ដីកាបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីពីទីតាំងឧក្រិដ្ឋកម្មនានាទាក់ទងនឹងសំណុំរឿង ០០៣ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៤ កថាខណ្ឌ ២០-២៤។

[46] ដីកាដំណោះស្រាយរបស់ ស.ច.ស.អ កថាខណ្ឌ ៥៦៦-៦៨, ៥៧០។ សូមមើលផងដែរ ដីកាដំណោះស្រាយរបស់ ស.ច.ស.អ កថាខណ្ឌ ១៧១ (ពិពណ៌នាគោលនយោបាយជាតិទាំងបួន៖ "ការបង្កើតសហករណ៍ និងការដ្ឋានពលកម្មដោយបង្ខំ" "ការអប់រំ

ពិសេស ជាផ្នែកមួយនៃផែនការឧក្រិដ្ឋកម្មរួម ឬ JCE មាស មុត "ឃុំខ្លួនមិនត្រឹមត្រូវតាមច្បាប់ [សមាសភាពមិនពេញចិត្ត] ហើយបង្ខំឱ្យ [ពួកគេ] ធ្វើការបាក់កម្លាំង"[47]។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី២ រៀបរាប់លម្អិតអំពីតួនាទីរបស់ មាស មុត នៅក្នុងការកំណត់ "ខ្មាំង ឬជនក្បត់" ក្នុងចំណោមកងទ័ពបដិវត្តន៍កម្ពុជា និង "ការបោសសម្អាតសមាសភាពមិនពេញចិត្តទាំងអស់នៅក្នុង ប.ក.ក"[48]។ ដីកាដំណោះស្រាយ ស.ច.ស.អ កំណត់ក្រុមដែលមានទំហំធំ កំណត់គោលដៅដោយមេដឹកនាំ ប.ក.ក រួមទាំង វៀតណាម និងថៃ កម្មាភិបាល ប.ក.ក ដែលគិតថាបានក្បត់ កងទ័ពមកពីភូមិភាគបូព៌ា "ប្រជាជនថ្មី" ឬ "ប្រជាជន ១៧ មេសា" អ្នកដែលជាប់ពាក់ព័ន្ធជាមួយនឹងរបបសាធារណរដ្ឋខ្មែរ ឬ របប លន់ នល់ ខ្មែរក្រោម និងសមាជិកដែលគេសង្ស័យថាជា សេ.អ៊ី.អា ឬ កា.ហ្សេ.បេ[49]។ អាពាហ៍ពិពាហ៍ដោយបង្ខំក៏ជាផ្នែកមួយនៃ "គោលនយោបាយជាតិ" នៃ ប.ក.ក[50]។ ប.ក.ក បានអនុវត្តគោលនយោបាយទាំងនេះ "ដោយបង្កើតមន្ទីរសន្តិសុខនៅទូទាំងប្រទេស ដែលឃុំឃាំង" និង "បោសសម្អាតជាច្រើនលើក" និងសម្លាប់អ្នកដែលគេយល់ឃើញថាជាខ្មាំង និង "សមាសធាតុមិនល្អ" មកពីក្នុងជួរ ឬ ក្រៅជួរ ប.ក.ក[51]។ យោងតាមដីកាដំណោះស្រាយ ស.ច.ស.អ ឧក្រិដ្ឋកម្មដូចបានចោទប្រកាន់មានលក្ខណៈ "ជាប្រព័ន្ធ" និងបានបង្កើតឡើងតាមរយៈ "ការស្តែងចេញពីការរៀបចំផែនការ ការរៀបចំ និងការអនុវត្តពីថ្នាក់មជ្ឈិមដែលជាប់

---

"សមាសភាពមិនល្អ" និង "ការសម្លាប់ខ្មាំង" ទាំងក្នុង និងក្រៅជួរយោធា" "ការកំណត់មុខសញ្ញាក្រុមជាក់លាក់ ជាពិសេស អ្នកទាំងឡាយណាដែលជាជនជាតិភាគតិច ឬ ជនជាតិវៀតណាម និងថៃ (ទាំងពិតប្រាកដ និងតាមការសន្មត) ព្រមទាំងអតីតបុគ្គលិកយោធា និងប្រជាជនស៊ីវិល" "ការអនុវត្តការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំលើប្រជាជនស៊ីវិល និងយោធានៃកងទ័ពបដិវត្តន៍កម្ពុជា")។

[47] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី២ កថាខណ្ឌ ៩។ *សូមមើលផងដែរ* ដីកាដំណោះស្រាយរបស់ ស.ច.ស.អ កថាខណ្ឌ ៣៣០-៤៤២ (រៀបរាប់មន្ទីរសន្តិសុខ និងការដ្ឋានការងារ)។ សំណុំរឿង ០០៣ ឯកសារ D120 ដីកាបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីពីទីតាំងឧក្រិដ្ឋកម្មនានាទាក់ទងនឹងសំណុំរឿង ០០៣ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ ២០១៤ កថាខណ្ឌ ៦-១១, ១៥-១៩។

[48] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី២ កថាខណ្ឌ ៤, ៣៣។

[49] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី២ កថាខណ្ឌ ១៩០, ៣៤៩, ៤១៩។

[50] ដីកាដំណោះស្រាយរបស់ ស.ច.ស.អ កថាខណ្ឌ ៤៧៥។ សំណុំរឿង ០០៣ ឯកសារ D120 ដីកាបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីពីទីតាំងឧក្រិដ្ឋកម្មនានាទាក់ទងនឹងសំណុំរឿង ០០៣ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៤ កថាខណ្ឌ ២៦។

[51] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី២ កថាខណ្ឌ ១០-១១ (ការគូសបញ្ជាក់បន្ថែម)។

ពាក់ព័ន្ធនឹងកម្រិតទាំងអស់នៃកងទ័ពបដិវត្តន៍កម្ពុជា និងផ្នែកនានានៃការគ្រប់គ្រងប្រជាពលរដ្ឋស៊ីវិល"[52]។

27. ដីកាដំណោះស្រាយរបស់ ស.ច.ស.អ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីពីរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ពេញពេញទៅដោយការចោទប្រកាន់អំពីការចូលរួមរបស់ មាស មុត នៅក្នុង JCE ថ្នាក់ជាតិ ដែលរួមបញ្ចូលឧក្រិដ្ឋកម្មដូចបានចោទប្រកាន់លើសពីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងតំបន់ស្វយ័តកំពង់សោម និងនៅក្នុងដែនទឹក និងកោះនៅម្ដុំឆ្នេរនៃរបបកម្ពុជាប្រជាធិបតេយ្យ រួមមាន តួនាទីសំខាន់ៗរបស់គាត់នៅក្នុងការបោសសម្អាតភូមិភាគបូព៌ា និងកម្មាភិបាលស្ថិតនៅក្នុងខេត្តក្រចេះ[53]។ ការបោសសម្អាតកម្មាភិបាល ឬ ជនស៊ីវិល ប.ក.ក ដែលត្រូវបានគេយល់ឃើញថាជា "ខ្មាំង" គឺជាគោលនយោបាយសំខាន់មួយនៅក្នុងផែនការរួមនៅទូទាំងប្រទេសរបស់ ប.ក.ក ដែលត្រូវបានផ្សព្វផ្សាយនៅក្នុងទស្សនាវដ្ដី "ទង់បដិវត្តន៍" របស់បក្ស យោងតាមដីកាដំណោះស្រាយរបស់ ស.ច.ស.អ[54]។ លើសពីនេះ ក្រុមដែល មាស មុត កំណត់គោលដៅជាក់លាក់សម្រាប់ការវាយប្រហារ គឺដូចនឹងក្រុមទាំងនោះនៅទូទាំងប្រទេស ហើយរួមបញ្ចូល "កម្មាភិបាល ប.ក.ក ដែលគេចោទថាធ្វើ "សកម្មភាពក្បត់" "ប្រជាជន ១៧ មេសា" ទាហានមកពីភូមិភាគបូព៌ា និងជនជាតិវៀតណាម និងជនជាតិថៃ"[55]។ អ្វីគួរឲ្យកត់សម្គាល់ បទចោទចំនួនពីរក្នុងចំណោមបទចោទនានានៅក្នុងដីកាដំណោះស្រាយរបស់ ស.ច.ស.អ អន្តរជាតិ ចោទប្រកាន់ថា មាស មុត ទទួលខុសត្រូវលើការបញ្ជូនជនស៊ីវិលថៃ និងវៀតណាមដែលត្រូវបានចាប់ខ្លួនបញ្ជូនទៅ ស-២១ ដែលវាស្ថិតនៅក្រៅតំបន់ក្រោមការគ្រប់គ្រងរដ្ឋបាលរបស់ មាស មុត[56]។ ដូចបានទទួលស្គាល់ដោយដីកាដំណោះស្រាយរបស់ ស.ច.ស.អ "ការពិតដែលថា មាស មុត មិនមានវត្តមានដោយផ្ទាល់នៅមន្ទីរ ស-២១ មិនបានធ្វើឲ្យគាត់រួចផុតពីការទទួលខុសត្រូវនេះទេ ពីព្រោះគាត់បានរៀបចំផែនការឧក្រិដ្ឋកម្មដែលបានកើតឡើងនៅមន្ទីរ ស-២១ ពីកំពង់សោម"[57]។

[52] ដីកាដំណោះស្រាយរបស់ ស.ច.ស.អ កថាខណ្ឌ ៤៧៦។

[53] ដីកាដំណោះស្រាយរបស់ ស.ច.ស.អ កថាខណ្ឌ ២៧៣-២៧៥។

[54] ដីកាដំណោះស្រាយរបស់ ស.ច.ស.អ កថាខណ្ឌ ១៨៣។

[55] ដីកាដំណោះស្រាយរបស់ ស.ច.ស.អ កថាខណ្ឌ ៥៦៨។

[56] ដីកាដំណោះស្រាយរបស់ ស.ច.ស.អ កថាខណ្ឌ ២៥៧-៥៨។

[57] ដីកាដំណោះស្រាយរបស់ ស.ច.ស.អ កថាខណ្ឌ ៥៧១។

28. ទោះបីជាមានការបង្ហាញយ៉ាងច្បាស់អំពី "ទិដ្ឋភាពជារួម" នៃការទទួលខុសត្រូវរបស់ មាស មុត ក៏ដោយ ក៏ ស.ច.ស.អ បានផ្តោតសំខាន់លើតែឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងតំបន់ស្វយ័តកំពង់សោម និងដែនទឹក និងកោះនៅមុំផ្នែរនៃរបបកម្ពុជាប្រជាធិបតេយ្យ ដើម្បីកំណត់ភាពអាចទទួលយកបាននៃដើមបណ្តឹងរដ្ឋប្បវេណី។ នេះគឺជាកំហុស។ ផ្ទុយទៅវិញ ពាក់ព័ន្ធនឹងការវិភាគអំពីភាពអាចទទួលយកបានជាដើមបណ្តឹងរដ្ឋប្បវេណី ស.ច.ស.អ គួរតែបានពិចារណាអំពីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្រៅតំបន់ទាំងនោះ ដែលបង្កើតបានជាផ្នែកនៃ JCE ថ្នាក់ជាតិ ដែល មាស មុត ត្រូវបានចោទប្រកាន់ថាជាសមាជិកម្នាក់ដែរ។ សេចក្តីម្រេចនៅក្នុងដីកាស្តីពីភាពអាចទទួលយកបានរបស់ ស.ច.ស.អ ក្នុងការកម្រិតភាពអាចទទួលយកបាននៃដើមបណ្តឹងរដ្ឋប្បវេណីលើទីតាំងភូមិសាស្ត្រចំនួនពីរ ដែល មាស មុត មានការគ្រប់គ្រងរដ្ឋបាលទាំងស្រុង មិនអាចស៊ី សង្វាក់គ្នាជាមួយនឹងសំអាងហេតុនៅក្នុងដីកាដំណោះស្រាយរបស់គាត់នោះទេ។ ដីកាស្តីពីភាពអាចទទួលយកបាន ខកខានមិនបានបង្ហាញសេចក្តីសម្រេចដែលមានសំអាងហេតុចំពោះការកម្រិតភូមិសាស្ត្រស្តីពីភាពអាចទទួលយកបាននៃដើមបណ្តឹងរដ្ឋប្បវេណី ដែលរារាំងសិទ្ធិរបស់ជនរងគ្រោះក្នុងការទទួលបានព័ត៌មាន និងក្នុងការទទួលបានការពិនិត្យមើលបណ្តឹងឧទ្ធរណ៍ឡើងវិញប្រកបដោយប្រសិទ្ធភាព។

29. ដូចបានរៀបរាប់លម្អិតនៅក្នុងឧបសម្ព័ន្ធ គ (ព្យសនកម្មចំពោះអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលកើតចេញពីការកំណត់គោលដៅ) និង ឃ (ព្យសនកម្មចំពោះអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលកើតចេញពីគោលនយោបាយផ្សេងទៀតនៃ JCE) ម្ចាស់បណ្តឹងឧទ្ធរណ៍បានទទួលរងព្យសនកម្មដោយផ្ទាល់ពីការអនុវត្ត JCE ថ្នាក់ជាតិ ដែល មាស មុត ត្រូវបានចោទប្រកាន់ថាបានចូលរួម។ នៅក្នុងចំណោមអ្នកដែលត្រូវបានបដិសេធឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០៣ រួមមានជនរងគ្រោះដែលទទួលរងព្យសនកម្មដោយសារផលវិបាកនៃគោលនយោបាយជាតិទាំងបួន ដែលបានអនុវត្តដើម្បីពន្លឿនការសម្រេចផែនការឧក្រិដ្ឋរួមនៃ JCE ដូចរៀបរាប់ខាងក្រោម។

(១) នៅក្នុងឆ្នាំ១៩៧៥ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី **កែវ ធារី** (11-VSS-00030) និងគ្រួសាររបស់គាត់ត្រូវបានជម្លៀសដោយបង្ខំពីក្រុងភ្នំពេញទៅកាន់ខេត្តកំពង់ចាម នៅទីនោះ ពួកគេត្រូវបានបង្ខំឲ្យរស់នៅក្នុងសហករណ៍ និងធ្វើការងារពេញមួយរបបខ្មែរក្រហម។ អ្នកដាក់ពាក្យសុំធ្វើការពីព្រឹកដល់

យប់ លើកដី ធ្វើស្រែ លើកទំនប់ ពោលគឺ ការងារដែលបង្ករឬសជាអចិន្ត្រៃយ៍លើស្មារ និងជង្គង់ ដែលកើតមានមកទល់សព្វថ្ងៃ។ សមាជិកគ្រួសាររបស់គាត់មួយចំនួនបានស្លាប់ ហើយខ្លះទៀតជាទាសករនៅតាមសហករណ៍ និងការដ្ឋាន។ ឪពុករបស់អ្នកដាក់ពាក្យសុំ កែវ បាន ស្លាប់នៅក្នុងឆ្នាំ១៩៧៦ ដោយសារអត់អាហារ និងខ្វះការថែទាំសុខភាព ហើយប្អូនប្រុសរបស់គាត់ កែវ សុផល ត្រូវបានកម្មាភិបាលខ្មែរក្រហមសម្លាប់នៅក្នុងឆ្នាំ១៩៧៧ ដោយចោទថាបានហូបដំឡូងមិនបានសុំការអនុញ្ញាត។ ប្អូនប្រុសម្នាក់ទៀត កែវ ស៊ីសុផល ត្រូវបានសម្លាប់នៅពេលធ្វើការនៅក្នុងកងចល័ត។ ពូរបស់គាត់ អតីតទាហានខ្មែរក្រហម ត្រូវបានសម្លាប់នៅភ្នំប្រុសភ្នំស្រី ដោយគេចោទថា គាត់គឺជាវៀតណាម។ នៅចុងឆ្នាំ១៩៧៧ ប្រធានកងបានបង្ខំអ្នកដាក់ពាក្យសុំឱ្យរៀបការជាមួយមនុស្សម្នាក់ដែលគាត់មិនដែលស្គាល់ឈ្មោះ សុខ ហឿង រួមជាមួយអ្នកដែលត្រូវរៀបការចំនួន ៥៧ គូផ្សេងទៀតនៅក្នុងពិធីមួយ ដែលពុំធ្វើទៅតាមទំនៀមទម្លាប់ប្រពៃណីខ្មែរទាំងអស់។ គាត់ និងប្តីគាត់ត្រូវបានកម្មាភិបាលខ្មែរក្រហមតាមដានរយៈពេលបួនប្រាំថ្ងៃ ដែលកម្មាភិបាលរូបនេះអាចសម្លាប់ប្តីប្រពន្ធណាដែលពុំព្រមរួមដំណេកជាមួយគ្នា[58]។

(២) ក្រោយខ្មែរក្រហមឡើងកាន់អំណាចនៅក្នុងឆ្នាំ១៩៧៥ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី **សំ ស៊ីថា** (13-VSS-00370) រស់នៅក្នុងខេត្តព្រៃវែង ដែលនៅទីនោះ គាត់ត្រូវបានគេបង្ខំឱ្យរែកដី ជីកប្រឡាយ និងធ្វើស្រែ ដោយពុំឱ្យសម្រាក និងអាហារហូបគ្រប់គ្រាន់។ នៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៧៥ កម្មាភិបាលខ្មែរក្រហមបានណែនាំគាត់ឱ្យស្លៀកពាក់សម្លៀកបំពាក់ស្អាតៗ ហើយប្រាប់ឱ្យទៅចូលរួមប្រជុំដោយមិនបានប្រាប់ជាក់លាក់។ នៅទីនោះ គាតត្រូវបានបង្ខំឱ្យរៀបការនឹងគ្រូពេទ្យអាយុ ២៤ ឆ្នាំ ឈ្មោះ ឡុង រួមជាមួយអ្នកដែលត្រូវរៀបការចំនួន ១៦ គូផ្សេងទៀតនៅក្នុងសាលប្រជុំមួយក្នុងខេត្តព្រៃវែង។ អ្នកដាក់ពាក្យសុំមិនអាចបដិសេធអាពាហ៍ពិពាហ៍នោះទេ ទោះបីជាគាត់មិនពេញចិត្តក៏ដោយ។

---

[58] *សូមមើល* សំណុំរឿង ០០៣ ឯកសារ D11/226 ទម្រង់បែបបទព័ត៌មានអំពីជនរងគ្រោះ កែវ ធារី ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១០ ត្រង់ 00552619។ សំណុំរឿង ០០៣ ឯកសារ D11/226.2 ឧបសម្ព័ន្ធ ២៖ ទម្រង់ព័ត៌មានបន្ថែមលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី៥ ខែមេសា ឆ្នាំ២០១០ ត្រង់ 00584578។

ក្រោយពេលរៀបអាពាហ៍ពិពាហ៍ អ្នករៀបការចំនួន ៧ គូ រួមទាំង គាត់ និងឡុង ត្រូវបានចាត់ឲ្យរស់នៅក្នុងខ្ទមតូចៗ ដែលរៀបចំរួចស្រេចនៅកន្លែងនោះ ដើម្បីអាចឲ្យកម្មាភិបាលខ្មែរក្រហមតាមដានពួកគេ ចំណែកគូដែលនៅសេសសល់បានត្រឡប់ទៅភូមិវិញ។ គូទាំងនោះដែលគេតាមដាន ប្រសិនបើមិនព្រមរួមភេទជាមួយនឹងគ្នា នឹងត្រូវអង្គការនាំទៅអប់រំ និងសម្លាប់ចោល។ ដោយសារភ័យខ្លាចស្លាប់ គាត់រួមភេទជាមួយប្ដីរបស់គាត់ ហើយគេឲ្យពួកគេត្រឡប់ទៅភូមិវិញបីថ្ងៃក្រោយមក ហើយឲ្យទៅធ្វើការដាច់ពីគ្នា។ នៅក្នុងឆ្នាំ១៩៧៧ មេដឹកនាំខ្មែរក្រហម បានចោទប្ដីគាត់ថាជាខ្មាំងនៃរបប ហើយលែងឲ្យគាត់ធ្វើការជាគ្រូពេទ្យ និងបង្ខំឲ្យគាត់ដឹកស្រូវវិញ។ ក្រោយពេលរបបខ្មែរក្រហមដួលរលំ នៅអំឡុងខែមេសា ឆ្នាំ១៩៨០ អ្នកដាក់ពាក្យសុំបានលែងលះជាមួយប្ដីរបស់គាត់ ហើយដោយសារការឈឺចាប់បណ្ដាលមកពីការរៀបការដោយបង្ខំ គាត់ពុំព្រមរៀបការសាជាថ្មីរហូតមកទល់សព្វថ្ងៃ[59]។

(៣) នៅថ្ងៃទី១៩ ខែមេសា ឆ្នាំ១៩៧៥ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី **សេង ឃាង** (15-VSS-00138) គឺជាព្រះសង្ឃនៅវត្តដំរីស ក្នុងក្រុងបាត់ដំបង នៅពេលកងទ័ពខ្មែរក្រហមបានបញ្ជាឲ្យព្រះអង្គ និងព្រះសង្ឃដទៃទៀត និងសាមណេរ រៀបចំរបស់របរ និងបង្ខំព្រះសង្ឃឲ្យផ្លាស់ទៅនៅវត្តភ្នំធំ បច្ចុប្បន្ន ស្ថិតនៅក្នុងខេត្តបន្ទាយមានជ័យ។ នៅទីនោះ ព្រះសង្ឃត្រូវបានបង្ខំឲ្យផ្សឹក និងបង្ខំឲ្យធ្វើស្រែពីព្រឹកដល់យប់។ ដោយសារព្រះអង្គត្រូវបានជម្លៀស ខ្មែរក្រហមបានចាត់ទុកអ្នកដាក់ពាក្យសុំជា អ្នក "១៧ មេសា" ឬ ប្រជាជន "ថ្មី" ហើយព្រះអង្គត្រូវបានតាមដានដោយប្រជាជន "ចាស់" ឬ "មូលដ្ឋាន"។ ក្រោយមក អ្នកដាក់ពាក្យសុំត្រូវបានជម្លៀសទៅទីតាំងមួយទៀតនៅភូមិភាគឥសាន ហើយ នៅចុងឆ្នាំ១៩៧០ គាត់បានចាប់ផ្ដើមស្រេកគីឡូ ចំណែកព្រះសង្ឃផ្សេងទៀតហាមពេញព្រះកាយ និងសុគតដោយសារអត់ចង្អាន់។ ស្ថានភាពរស់នៅ នៅតាមសហករណ៍កាន់តែលំបាកនៅក្នុងឆ្នាំ១៩៧៦ នៅពេលរបបអាហារត្រូវបានកាត់បន្ថយរហូត

[59] *សូមមើល* សំណុំរឿង ០០៣ ឯកសារ D11/334 ទម្រង់បែបបទព័ត៌មានអំពីជនរងគ្រោះ សំ ស៊ីថា ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១០ ត្រង់ 00974598-99។

ដល់អង្ករ ១០ កំប៉ុង គេយកលាយជាមួយត្រកួនឲ្យកម្មករ ៣០០ នាក់ ហូប ចំណែកកម្មករវិញត្រូវបានគេឲ្យធ្វើការងារយូរម៉ោងដើម្បីបំពេញតាមផែនការ បង្កបង្កើនផលដែលបានបង្កើតឡើងដោយខ្មែរក្រហម ពោលគឺ ធ្វើស្រូវ ៣ ទៅ ៤ តោនក្នុងមួយហិចតា។ ពេលខ្លះ អ្នកដាក់ពាក្យសុំត្រូវបានគេចាត់ចូលក្រុមដែល មានគ្នា ៤ នាក់ ដើម្បីធ្វើស្រែលើដី ៤០ ម៉ែត្រការ៉េ។ កម្មករធ្លាក់ខ្លួនឈឺក្រោម សម្ពាធបែនេះ ត្រូវបានគេចោទថាមាន "ជំងឺសតិអារម្មណ៍"។ ក្រោយពីការ ជម្លៀសដោយបង្ខំម្តងទៀតនៅក្នុងឆ្នាំ១៩៧៧ អ្នកដាក់ពាក្យសុំត្រូវបានគេឲ្យធ្វើដី ធម្មជាតិពីព្រឹកព្រលឹមរហូតដល់ម៉ោង ៦ រសៀល និង បន្ទាប់មក ជីកប្រឡាយ រហូតដល់ពាក់កណ្តាលយប់។ ក្រៅពីគោ ក្របី អ្នកដាក់ពាក្យសុំបានឃើញកម្មករ ត្រូវបានគេបង្ខំឲ្យដកស្ទូងនៅក្នុងស្រែដើម្បីសម្រេចទិសដៅ "មហាលោតផ្លោះ មហាអស្ចារ្យ"។ នៅពេលគាត់ធ្លាក់ខ្លួនឈឺ អ្នកដាក់ពាក្យសុំត្រូវបានបញ្ជូនទៅ មន្ទីរពេទ្យភ្នំតូច ដែលនៅទីនោះ អ្នកជំងឺស្លាប់ដោយសារខ្វះអនាម័យ និងថ្នាំសង្កូវ ព្យាបាល។ ក្រោយមក នៅដើមឆ្នាំ១៩៧៨ បរិយាកាសភ័យខ្លាចបានឡើងកាន់តែ ខ្លាំងនៅពេលកម្មាភិបាលពីភូមិភាគបូព៌ា ត្រូវបានបញ្ជូនទៅបោសសម្អាតមេដឹកនាំ ខ្មែរក្រហមនៅតាមមូលដ្ឋាន រួមទាំង ប្រធានសហករណ៍ កម្មាភិបាលជាច្រើន ទៀត ដែលធ្វើការនៅរោងបាយ និងអ្នកផ្សេងទៀត។ អ្នកដាក់ពាក្យសុំ ដែលត្រូវ បានគេបំបែកពីគ្រួសារនៅពេញមួយរបបកម្ពុជាប្រជាធិបតេយ្យ បានបាត់បង់ គ្រួសារបង្កើតទាំងមូល ឪពុក ម្តាយ និងបង/ប្អូនប្រុស[60]។

(៤) អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី **សេ សុខន** (17-VSS-00021) និងគ្រួសាររបស់គាត់បានទទួលរងស្ថានភាពរស់នៅ និងធ្វើការងារធ្ងន់ធ្ងរ នៅ សហករណ៍ក្នុងខេត្តបាត់ដំបង។ នៅក្នុងឆ្នាំ១៩៧៥ អ្នកដាក់ពាក្យសុំ ដែលមានផ្ទៃ ពោះនៅពេលនោះ ត្រូវបានគេដាក់នៅក្នុងកងនារីធ្វើការងារដោយបង្ខំមានឈ្មោះ ថា "០-២១" និងត្រូវបានបំបែកចេញពីប្តី ដែលត្រូវបានគេដាក់នៅក្នុងកងបុរស។ មានយប់មួយនោះ ប្តីរបស់អ្នកដាក់ពាក្យសុំបានលួចចេញពីកងបុរសដើម្បីយកថ្នាំ

[60] *សូមមើល* សំណុំរឿង ០០៣ ឯកសារ D11/496 ទម្រង់បែបបទព័ត៌មានអំពីជនរងគ្រោះ សេង ឃាង ចុះថ្ងៃទី៥ ខែមករា ឆ្នាំ ២០១៥ ត្រង់ 00520594-96។

ទៅឲ្យប្រពន្ធ។ ខ្មែរក្រហមបានចាប់គាត់ពេលលួចចេញនោះ ហើយបានសម្លាប់គាត់នឹងដំបង។ ក្រោយមក អ្នកដាក់ពាក្យសុំបានដឹងអំពីការស្លាប់នេះពីមេដឹកនាំកងនារី ដែលបានលួចប្រាប់គាត់។ ប្តីរបស់គាត់ ដែលជាអ្នកកាន់សាសនាព្រះពុទ្ធ ពុំអាចទទួលបានការរៀបចំបុណ្យត្រឹមត្រូវទៅតាមពិធីសាសនាព្រះពុទ្ធរបស់ខ្មែរយើងនោះទេ។ ក្រោយពេលអ្នកដាក់ពាក្យសុំសម្រាលកូននៅក្នុងខែវិច្ឆិកា ឆ្នាំ ១៩៧៦ ខ្មែរក្រហមបានយកកូននោះទៅបាត់ ដើម្បីឲ្យគាត់អាចបន្តធ្វើការងារធ្ងន់នៅក្នុងកងនោះបន្តទៀត។ កូននោះត្រូវបានគេប្រគល់ឲ្យយាយៗមើលថែនៅក្នុងកង ដែលពុំបានមើលថែត្រឹមត្រូវ ហើយ ១០ ខែ ក្រោយមក កូននោះបានស្លាប់ដោយសារខ្វះអាហារ។ អ្នកដាក់ពាក្យសុំពុំត្រូវបានគេអនុញ្ញាតឲ្យយំទួញសោកអំពីការស្លាប់ប្តី និងកូននោះទេ ដោយសារអ្នកដែលហ៊ានយំ នឹងត្រូវបានគេវាយដំ ឬ សម្លាប់ចោល។ នៅក្នុងឆ្នាំ១៩៧៧ ខ្មែរក្រហមបានបង្ខំអ្នកដាក់ពាក្យសុំឲ្យរៀបការប្តីទីពីរ។

(៥) អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី **តន់ សុខ** (11-VSS-00120) គ្រួសាររបស់គាត់ និងអ្នកភូមិ ត្រូវបានគេហៅទៅប្រជុំជាមួយកម្មាភិបាលខ្មែរក្រហមនៅខេត្តស្វាយរៀងក្នុងឆ្នាំ១៩៧៥។ នៅទីនោះ កម្មាភិបាលបានប្រមូលព័ត៌មានអំពីសាវតារគ្រប់គ្នា ស្វែងរកអ្នកដែលជាអ្នករដ្ឋការ ឬ ទាហានក្នុងសម័យសាធារណរដ្ឋខ្មែរ។ ប្តីរបស់អ្នកដាក់ពាក្យសុំ រត់ ពុត អតីតទាហាន ឪពុករបស់គាត់ តន់ អ៊ឹម និងមនុស្ស ២០ នាក់ផ្សេងទៀត ត្រូវបានគេចុចឈ្មោះនៅក្នុងបញ្ជីដែលរៀបចំដោយកម្មាភិបាលខ្មែរក្រហម។ គ្រប់គ្នាដែលមានឈ្មោះនៅក្នុងបញ្ជីត្រូវបានគេយកទៅ "រៀនសូត្រ"។ ក្រោយមកទៀត ប្តីរបស់អ្នកដាក់ពាក្យសុំ ឪពុក បងប្រុស និងអ្នកផ្សេងទៀត បានបាត់ខ្លួន ហើយគេសន្មតថាបានស្លាប់។ ក្រោយពេលចាប់ខ្លួន និងបាត់ខ្លួនបុរសទាំងនេះ គ្រួសាររបស់ពួកគេ ត្រូវបានគេធ្វើទុក្ខបុកម្នេញដោយត្រូវគេជម្លៀសដោយបង្ខំច្រើនដងទៅកាន់ការដ្ឋាន និងសហករណ៍ផ្សេងទៀតដោយពុំបានផ្តល់អ្វីទាំងអស់។ គេឲ្យពួកគេធ្វើការងារធ្ងន់ធ្ងរ ដូចជាសាងសង់ផ្លូវ លើកទំនប់ ជីកប្រឡាយ ធ្វើស្រែ បោកស្រូវ (៣០ តៅ ក្នុងមួយថ្ងៃ) ជាយូរម៉ោងជារៀងរាល់ថ្ងៃ។ ពួកគេបានទទួលបបររាវៗ ២ វែក សម្រាប់ហូប។ នៅទីបំផុត នៅក្នុងឆ្នាំ១៩៧៧ ខ្មែរក្រហម បានបញ្ជាឲ្យអ្នកដាក់ពាក្យសុំរៀបការ

រួមជាមួយអ្នកដែលត្រូវរៀបការចំនួនប្រាំបីគូផ្សេងទៀត។ នៅក្នុងពិធីនោះ គូប្តីប្រពន្ធប្តេជ្ញាគោរពតាមបញ្ជាអង្គការ និងត្រូវបានបង្គាប់ឱ្យបង្កើតកូនចៅ។ នៅពេលយប់ ខ្មែរក្រហមបានតាមដានអ្នកដាក់ពាក្យសុំដើម្បីមើលថាតើគាត់ និងប្តីគាត់ "ត្រូវរ៉ូវគ្នា" ឬទេ។ អ្នកដែលមិនត្រូវរ៉ូវគ្នា ត្រូវបានគេនាំយកទៅសម្លាប់ចោល។ នៅព្រឹកបន្ទាប់ពីថ្ងៃរៀបការ ប្រធានសហករណ៍បានសួរអ្នកដាក់ពាក្យសុំថាតើគាត់បានរួមភេទជាមួយប្តីរបស់គាត់ទេ ហើយដោយភ័យខ្លាចមានការសងសឹក គាត់បាននិយាយថាគាត់បានរួមភេទ[61]។

30. អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលបានកំណត់អត្តសញ្ញាណនៅក្នុងឧបសម្ព័ន្ធ គ (ព្យសនកម្មចំពោះអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលកើតចេញពីការកំណត់គោលដៅ) និង ឃ (ព្យសនកម្មចំពោះអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលកើតចេញពីគោលនយោបាយនានានៃ JCE) បានទទួលរងព្យសនកម្មដែលជាផលវិបាកដោយផ្ទាល់នៃការអនុវត្ត JCE ថ្នាក់ជាតិ ដែល មាស មុត ត្រូវបានចោទប្រកាន់ថាបានចូលរួម។ យោងតាមសំអាងហេតុខាងលើ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំឱ្យ អ.ប.ជ ទទួលយកអ្នកដាក់ពាក្យសុំទាំងនេះជាដើមបណ្តឹងរដ្ឋប្បវេណី។

**២. អង្គបុរេជំនុំជម្រះគួរតែទទួលយកជនរងគ្រោះនៃក្រុមគោលដៅជាក់លាក់ជាដើមបណ្តឹងរដ្ឋប្បវេណី ដែលពួកគាត់បានទទួលរងព្យសនកម្មរួម ដែលបានពង្រីកហួសពីតំបន់ដែលបានកំណត់អត្តសញ្ញាណ នៅក្នុងដីកាស្តីពីភាពអាចទទួលយកបានដីកាសម្រេចទទួលយក ជាដើមបណ្តឹងរដ្ឋប្បវេណី**

31. ដីកាស្តីពីភាពអាចទទួលយកបាន ក៏មានកំហុសឆ្គងផងដែរ ក្នុងការកម្រិតវិសាលភាពភូមិសាស្ត្រនៃភាពអាចទទួលយកបានជាដើមបណ្តឹងរដ្ឋប្បវេណី ដែលរស់នៅក្នុងតំបន់ដែល មាស មុត មានសិទ្ធិអំណាចគ្រប់គ្រងរដ្ឋបាល ដោយហេតុថា សមាជិកនៃសហគមន៍ ឬក្រុមគោលដៅជាក់លាក់ដែលរស់នៅក្រៅតំបន់ទាំងអស់នេះ ក៏បានទទួលរងនូវព្យសនកម្ម ពីការខូចខាតជាសមូហភាពផងដែរ។

---

[61] *សូមមើល* សំណុំរឿង ០០៣ ឯកសារ D11/269 ទម្រង់បែបបទព័ត៌មានអំពីជនរងគ្រោះ គន់ សុខ ចុះថ្ងៃទី៧ ខែមករា ឆ្នាំ២០០៨ ត្រង់ 00516240-42។ សំណុំរឿង ០០៣ ឯកសារ D11/260.1 ឧបសម្ព័ន្ធ ២៖ ទម្រង់ព័ត៌មានបន្ថែមអំពីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១០ ត្រង់ 00581330-32។

32. នៅក្នុងសំណុំរឿង ០០២ អង្គបុរេជំនុំជម្រះបានទទួលស្គាល់ថា "សច្ចធារនៃការខូចខាតជាសមូហភាព" ដែលពង្រីកលើសពីសមាជិកនៃក្រុម ឬសហគមន៍ ដែលត្រូវបានធ្វើទុក្ខបុកម្នេញដូចគ្នា នៅពេលដែលឧក្រិដ្ឋកម្មសាហាវយង់ឃ្នង់ជាទ្រង់ទ្រាយធំ ដូចជាអំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ត្រូវបានចោទប្រកាន់[62]។ តាមរយៈការសន្និតនេះ "ករណីដែលអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី បានលើកឡើងថាគាត់គឺជាសមាជិកនៃក្រុមឬសហគមន៍គោលដៅតែមួយ ជាមួយនិងជនរងគ្រោះផ្ទាល់ គឺព្យសនកម្មអាចជាព្យសនកម្មផ្លូវចិត្ត ដែលជនរងគ្រោះដោយប្រយោលបានទទួលរង ដែលព្យសនកម្មនេះ កើតចេញពីព្យសនកម្មដែលជនរងគ្រោះផ្ទាល់បានទទួលរង"[63]។ អង្គបុរេជំនុំជម្រះបានផ្តល់សំអាងហេតុថា "នៅពេលជនរងគ្រោះដោយប្រយោល ជាសមាជិកនៃក្រុមមនុស្ស ឬសហគមន៍ណាមួយ ដែលក្លាយជាគោលដៅនៃការអនុវត្តគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជានោះ មិនមានភាពខុសគ្នារវាងអ្វីដែលមានកើតឡើងចំពោះបុគ្គលម្នាក់ៗ និងអ្វីដែលបានកើតឡើងជារួមឡើយ"[64]។ អង្គបុរេជំនុំជម្រះក៏យល់ឃើញថែមទៀតថា "វាជាការមិនត្រឹមត្រូវ ប្រសិនបើយើងពិនិត្យមើលការខូចខាត ដែលបង្កដោយអំពីសាហាវឃោឃៅជាទ្រង់ទ្រាយធំ តែទៅលើមូលដ្ឋានជាបុគ្គល [...]។ អំពើសាហាវឃោឃៅជាទ្រង់ទ្រាយធំដែលជាផលវិបាកនៃការអនុវត្តគោលនយោបាយជាប្រព័ន្ធនិងជាទ្រង់ទ្រាយធំ ហើយដែលការអនុវត្តនេះផ្តោតទៅលើសហគមន៍ទាំងមូល ក៏ដូចជាទៅលើក្រុមជាក់លាក់នានា ព្រមទាំងបុគ្គលនៅក្នុងសហគមន៍នោះផងដែរ"[65]។ ដូច្នេះ ចំពោះការខូចខាតជាលក្ខណៈមូហភាព អង្គបុរេជំនុំជម្រះ

---

[62] សំណុំរឿង ០០២ **D404/2/4** សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេត លើភាពអាចទទួលយកបាននៃ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៨៣ ដល់៩៣។

[63] សំណុំរឿង ០០២ **D404/2/4** សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេត លើភាពអាចទទួលយកបាននៃ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៩៣ (ដោយគូសបញ្ជាក់បន្ថែម)។

[64] សំណុំរឿង ០០២ **D404/2/4** សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេត លើភាពអាចទទួលយកបាននៃ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៨៨ (ដោយគូសបញ្ជាក់បន្ថែម)។

[65] សំណុំរឿង ០០២ **D404/2/4** សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេត លើភាពអាចទទួលយកបាននៃ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៧០។

មិនតម្រូវឱ្យមានភាពជិតគ្នាផ្នែករូបរាងកាយរវាងសមាជិកនៃក្រុមមនុស្ស ឬសហគមន៍គោលដៅតែមួយឡើយ។

33. ការអនុវត្តគោលការណ៍ស្តីពី "ការខូចខាតជាសមូហភាព" របស់ អ.វ.ត.ក ស្របគ្នាជាមួយការអនុវត្តជាអន្តរជាតិ។ អង្គជំនុំជម្រះតុលាការកំពូលរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ បានទទួលស្គាល់ថា "ប្រហែលជាច្បាស់ហើយថា ព្យសនកម្មអាចមានលក្ខណៈជាបុគ្គល និងជាសមូហភាព"[66]។ គោលការណ៍យុត្តិធម៌ជាមូលដ្ឋានឆ្នាំ១៩៨៥ របស់អង្គការសហប្រជាជាតិ សម្រាប់ជនរងគ្រោះដោយឧក្រិដ្ឋកម្ម និងការរំលោភបំពានលើអំណាច បានកំណត់និយមន័យ "ជនរងគ្រោះ" ថាជា "បុគ្គលទាំងឡាយ ទោះជាឯកត្តបុគ្គល ឬជាសមូហភាពក្តី ដែលបានទទួលរងអន្តរាយ"[67]។ បើយោងតាមគោលការណ៍យុត្តិធម៌ជាមូលដ្ឋានឆ្នាំ១៩៨៥ "ទម្រង់នៃការធ្វើឱ្យក្លាយជាជនរងគ្រោះនាពេលនោះ ជាពិសេសនៅពេលធ្វើឡើងប្រឆាំងនឹងមនុស្ស ក៏អាចត្រូវបានប្រព្រឹត្តឡើង*ប្រឆាំងនឹងក្រុមមនុស្សដែលត្រូវបានកំណត់គោលដៅជាសមូហភាពផងដែរ*"[68]។ ស្ថាប័នសិទ្ធិមនុស្សជាច្រើនក៏បានទទួលស្គាល់ផងដែរថា សមូហភាពមានសិទ្ធិ និងមានលទ្ធភាពទទួលរងព្យសនកម្ម ដែលតម្រូវឱ្យមានសំណងសម្រាប់ពួកគេ[69]។

---

[66] រដ្ឋអាជ្ញា តទល់នឹង *Thomas Lubanga Dyilo*, ICC-01/04-01/06-1432 សាលដីកាលើបណ្តឹងសាទុក្ខរបស់រដ្ឋអាជ្ញានិងមេធាវីការពារក្តី ប្រឆាំងដីកាសម្រេចរបស់ អង្គជំនុំជម្រះសាលាដំបូង I ស្តីពីការចូលរួមរបស់ជនរងគ្រោះនៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០០៨ ថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០០៨ កថាខណ្ឌ ៣៥។

[67] សេចក្តីប្រកាសស្តីពីគោលការណ៍ជាមូលដ្ឋាន នៃយុត្តិធម៌សម្រាប់ជនរងគ្រោះដោយឧក្រិដ្ឋកម្មនិងការរំលោភបំពានអំណាច U.N.G.A Res. 40/34 ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ១៩៨៥ ឧបសម្ព័ន្ធ ក.១។

[68] គោលការណ៍ជាមូលដ្ឋាន និងគោលការណ៍ណែនាំស្តីពី សិទ្ធិក្នុងការទទួលបានឧបាស្រ័យ និងសំណង សម្រាប់ជនរងគ្រោះដោយការរំលោភបំពានយ៉ាងធ្ងន់ធ្ងរ ទៅលើច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរ ទៅលើច្បាប់មនុស្សធម៌អន្តរជាតិ U.N.G.A. Res. 60/147 ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៥ (បុព្វកថា) (ដោយគូសបញ្ជាក់បន្ថែម)។

[69] សូមមើល ជាឧទាហរណ៍ គណៈកម្មាធិការសិទ្ធិមនុស្ស និងសិទ្ធិប្រជាជនអាហ្វ្រិក, *មជ្ឈមណ្ឌលអភិវឌ្ឍន៍សិទ្ធិជនជាតិភាគតិច (ប្រទេសកេនយ៉ា) និងក្រុមសិទ្ធិជនជាតិភាគតិចអន្តរជាតិ ក្នុងនាមក្រុមប្រឹក្សាសុខុមាលភាពអង់ដូរ័ស់ តទល់នឹង ប្រទេសកេនយ៉ា* ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៩ កថាខណ្ឌ ២៤៨ (គូសបញ្ជាក់ថា រដ្ឋមាន "កាតព្វកិច្ចកម្រិតខ្ពស់ ក្នុងការចាត់វិធានការវិជ្ជមាន ដើម្បីការពារក្រុម និងសហគមន៍នានា ដូចជាសហគមន៍អង់ដូរ័ស់នេះ")។ គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ *មតិយោបល់ទូទៅលេខ ២១, សិទ្ធិរបស់បុគ្គលគ្រប់គ្នាក្នុងការចូលរួមក្នុងជីវភាពវប្បធម៌* E/C.12/GC/21 ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៩ កថាខណ្ឌ ៣៧ (ជនជាតិដើមភាគតិចមានសិទ្ធិធ្វើសកម្មភាពជាសមូហភាព ដើម្បីធានានូវការគោរពសិទ្ធិរបស់ខ្លួន ក្នុងការថែរក្សា គ្រប់គ្រង ការពារ និងអភិវឌ្ឍន៍មរតកវប្បធម៌ ចំណេះវិជ្ជាប្រពៃណី ការបង្ហាញទំនៀមទម្លាប់វប្បធម៌របស់ខ្លួន [...] រដ្ឋជាភា

34. បើយោងតាមដីកាដំណោះស្រាយរបស់ ស.ច.ស.អ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីពីរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម មាស មុត ត្រូវទទួលខុសត្រូវចំពោះការវាយប្រហារ នៅក្នុងតំបន់ស្វយ័តកំពង់សោម និងផ្ទៃទឹកព្រមទាំងបណ្តាកោះនៃឆ្នេរសមុទ្រ របស់កម្ពុជាប្រជាធិបតេយ្យ ដែលមានគោលដៅទៅលើក្រុមឬសហគមន៍ជាក់លាក់ រួមទាំងប្រជាជននិងជនជាតិវៀតណាម ជនជាតិថៃ "ប្រជាជនថ្មី" អតីតអ្នករដ្ឋការសាធារណរដ្ឋខ្មែរ និងអ្នកក្រោមបង្គាប់លន់ នល់ កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា ដែលត្រូវបានគេគិតថាក្បត់ (រួមទាំងកម្មាភិបាលភូមិភាគបូព៌ា) ខ្មែរក្រោម និង "គិញ" របស់សេអ៊ីអានិងកាហ្សេបេ[70]។ យោងទៅលើសំអាងហេតុរបស់អង្គបុរេជំនុំជម្រះ ការសន្មតអំពីការខូចខាតជាសមូហភាព ដែលកើតចេញពីព្យសនកម្មដែលជនរងគ្រោះផ្ទាល់បានទទួលរង នៅក្នុងតំបន់ស្វយ័តកំពង់សោម និងផ្ទៃទឹកព្រមទាំងបណ្តាកោះនៃឆ្នេរសមុទ្រ របស់កម្ពុជាប្រជាធិបតេយ្យ បានពង្រីករហូតដល់សមាជិកទាំងអស់ នៃក្រុមឬសហគមន៍ដែលជាគោលដៅជាក់លាក់ ដោយមិនគិតអំពីទីកន្លែងរបស់ពួកគេឡើយ។

35. នៅក្នុងដីកាស្តីពីភាពអាចទទួលយកបាន សហចៅក្រមស៊ើបអង្កេតបានទទួលស្គាល់ គោលការណ៍ការខូចខាតជាសមូហភាពរបស់អង្គបុរេជំនុំជម្រះ ដោយសារតែគោលការណ៍នេះទាក់ទងជាមួយភាពអាចទទួលយកបាន ជាដើមបណ្តឹងរដ្ឋប្បវេណី ដោយបានបញ្ជាក់ថា "ជនរងគ្រោះមិនផ្ទាល់អាចទទួលរងព្យសនកម្មបែបនេះ ទោះបីជាគាត់គ្មានទំនាក់ទំនងជាគ្រួសារ ជាមួយនឹងជនរងគ្រោះផ្ទាល់ក៏ដោយ ពោលគឺឲ្យតែពួកគាត់ជាសមាជិក នៅក្នុងក្រុមគោលដៅតែមួយ ឬក្នុងសហគមន៍តែ

---

គឺត្រូវតែគោរពគោលការណ៍យល់ព្រមដោយសេរីជាមុន និងផ្អែកលើព័ត៌មានគ្រប់គ្រាន់របស់ជនជាតិដើមភាគតិចក្នុងគ្រប់កិច្ចការទាំងអស់ ដែលត្រូវបានគ្របដណ្តប់ ដោយសិទ្ធិជាក់លាក់ទាំងនេះ"។ តុលាការសិទ្ធិមនុស្សអន្តរទ្វីបអាមេរិក រឿងក្តី ជនជាតិដើមភាគតិច *Kichwa* នៃអំបូរ *Sarayaku* *តទល់នឹង ប្រទេសអេក្វាឌ័រ* សាលក្រម (អង្គសេចក្តី និងសំណង) ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១២ កថាខណ្ឌ ២៣១ ដល់២៣២, ២៨៤ (បញ្ជាក់អះអាងថា "ច្បាប់អន្តរជាតិស្តីពីសហគមន៍ និងជនជាតិដើមភាគតិច ឬកុលសម្ព័ន្ធ ទទួលស្គាល់សិទ្ធិរបស់ជនជាតិដើមទាំងនេះជាកម្មវត្ថុសមូហភាពនៃច្បាប់អន្តរជាតិ មិនត្រឹមតែទទួលស្គាល់ជាសមាជិកសហគមន៍ទាំងនោះឡើយ [...]"។ ក្រោយមកទៀត រកឃើញថា ប្រទេសអេក្វាឌ័រ បានរំលោភបំពានទៅលើ "សិទ្ធិទទួលបានទ្រព្យសម្បត្តិសមូហភាពរបស់ជនជាតិ Sarayaku" និងសម្រេចឲ្យប្រទេសអេក្វាឌ័រទទួលខុសត្រូវចំពោះជនជាតិទាំងនេះជាភាគីដែលទទួលរងការខូចខាត)។

[70] ដីកាដំណោះស្រាយរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កថាខណ្ឌ ១៩០, ២៧៣, ២៧៧, ២៧៩, ៣៤៩ ដល់៣៥០, ៣៩០, ៤១៣, ៤១៩។ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីពីរ កថាខណ្ឌ ៥៣ ដល់៥៤, ៥៩ ដល់៦០។ សំណុំរឿង ០០៣ ឯកសារ **D120** ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ របស់សហព្រះរាជអាជ្ញាអន្តរជាតិ ពាក់ព័ន្ធទីតាំងឧក្រិដ្ឋកម្មទាក់ទងសំណុំរឿង ០០៣ ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៤ កថាខណ្ឌ ៦។

មួយ”[71]។ ទោះជាបែបនេះក្តី សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានដាក់លក្ខខណ្ឌតម្រូវដោយខុសឆ្គងថា សមាជិកដែលរស់នៅក្នុងក្រុម ឬសហគមន៍គោលដៅតែមួយ ត្រូវតែស្ថិតនៅក្នុងតំបន់ស្វយ័តកំពង់សោម ឬផ្ទៃទឹកព្រមទាំងបណ្តាកោះនៃឆ្នេរសមុទ្ររបស់កម្ពុជាប្រជាធិបតេយ្យ ដោយច្រានចោលនូវលក្ខណៈជាសមូហភាព ដែលជាចំណុចស្នូលនៃគោលការណ៍នេះ។

36. ក្នុងចំណោមអ្នកដែលត្រូវបានបដិសេធ មិនទទួលបានឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងសំណុំរឿង០០៣ គឺជាជនរងគ្រោះដែលជាសមាជិកនៃក្រុមគោលដៅ ដែលត្រូវបានកំណត់អត្តសញ្ញាណនៅក្នុងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលបានរៀបរាប់លម្អិតដូចខាងក្រោម៖

(១) កម្មាភិបាលខ្មែរក្រហមបានបង្ខំ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឡេង ណាន (11-VSS-00070) ឲ្យរៀបការជាមួយប្តីរបស់គាត់ឈ្មោះ តែ យ៉ាង នៅក្នុងឆ្នាំ១៩៧៦ ជាមួយគូស្រករដទៃទៀតចំនួនបួនគូរ។ តាសេងជាមេខ្មែរក្រហមក្នុងស្រុកនោះ បានប្រាប់គាត់ថាអង្គការបានរៀបចំអាពាហ៍ពិពាហ៍ឲ្យគាត់ ហើយគាត់យល់ឃើញថាគាត់មិនអាចតវ៉ាបានទេ ព្រោះប្រសិនបើគាត់តវ៉ា គេនឹងបញ្ជូនគាត់ទៅរៀនសូត្រ។ ក្នុងពេលរៀបអាពាហ៍ពិពាហ៍ ទាំងឪពុកម្តាយគាត់ក៏ដូចជាសាច់ញាតិរបស់គាត់ មិនត្រូវបានអនុញ្ញាតិឲ្យចូលរួមឡើយ ហើយក្រោយមកគាត់និងប្តីរបស់គាត់ ត្រូវបានគេបញ្ជូនទៅធ្វើការឆ្ងាយដាច់ពីគ្នា នៅក្នុងខេត្តកំពង់ចាម។ បន្ទាប់ពីកូនស្រីរបស់គាត់បានប្រសូតហើយ គ្រួសាររបស់គាត់ត្រូវបានគេបង្ខំ ឲ្យវិលត្រឡប់មកខេត្តកំពង់ធំវិញ នៅក្នុងឆ្នាំ១៩៧៧ ដោយពួកមេខ្មែរក្រហមក្នុងស្រុក បានចាត់ទុកពួកគេថាជា ប្រជាជន “ផ្ញើរ”។ បន្ទាប់មកនៅក្នុងខែវិច្ឆិកាក្នុងឆ្នាំ១៩៧៧ សមាជិកគ្រួសាររបស់ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចំនួនប្រាំនាក់គឺ ប្តីរបស់គាត់ ឪពុកក្មេក បងថ្លៃប្រុស បងថ្លៃប្អូនថ្លៃស្រីពីរនាក់ ត្រូវបានមេឃ្លាំបនិងប្រធានសន្តិសុខភូមិសម្លាប់ចោល ដោយចោទថាជា “ខ្សែយួន” ដោយសារតែឈ្មោះពួកគេ “ដូចយួន”។ តែ ថាន ជាប្អូនថ្លៃរបស់ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានគេរំលោភផ្លូវភេទនៅមុនគេសម្លាប់។ ក្រោយពេលដែលសមាជិកក្រុមគ្រួសាររបស់គាត់ ត្រូវបាន

[71] ដីកាស្តីពីភាពអាចទទួលយកបាន កថាខណ្ឌ ៣៣។

គេសម្លាប់រួចហើយ អ្នកដាក់ពាក្យសុំត្រូវបានគេសង្ស័យ ហើយឈ្លបខ្មែរក្រហមពីរនាក់គឺឈ្មោះ នឿម និងគយ បានតាមដានសកម្មភាពរបស់គាត់ជាប្រចាំ[72]។

(២) នៅក្នុងឆ្នាំ១៩៧៥ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី វ៉ែន វ៉ន (11-VSS-00276) បានរៀបការជាមួយប្រពន្ធជាជនជាតិវៀតណាម ហើយពួកគាត់មានកូនជាមួយគ្នា។ នៅក្នុងរបបខ្មែរក្រហម អ្នកដាក់ពាក្យសុំ និងភរិយារបស់គាត់ ត្រូវបានគេចាត់ឲ្យទៅរកត្រី និងចម្អិនអាហារ នៅសហករណ៍បាក់ចិញ្ចៀន ក្នុងខេត្តពោធិសាត់។ ក្នុងឆ្នាំ១៩៧៥ ប្រជាជនវៀតណាមដែលរស់នៅក្នុងតំបន់ ត្រូវបានគេបញ្ជូនត្រឡប់ទៅវៀតណាមវិញ ប៉ុន្តែប្រពន្ធរបស់គាត់មិនព្រមទៅ ដូច្នេះគាត់អាចរស់នៅជាមួយគ្រួសាររបស់គាត់។ នៅដើមឆ្នាំ១៩៧៦ អ្នកដាក់ពាក្យសុំត្រូវបានខ្មែរក្រហមចោទប្រកាន់ថា "ក្បាលយួនខ្លួនខ្មែរ" ព្រោះតែគាត់រកត្រីមិនបានគ្រប់។ គាត់និងកូន១ធំ១ត្រូវបានគេបំបែកចេញពីប្រពន្ធនិងកូនពៅរបស់គាត់។ កូន១របស់គាត់ត្រូវបានគេបង្ខំឲ្យជ្រើសរើស ថារស់នៅជាមួយអ្នកដាក់ពាក្យសុំ ឬទៅនៅជាមួយម្តាយជនជាតិវៀតណាមរបស់ពួកគេ។ កូនទាំងអស់លើកលែងតែកូនតូច ជាទារកប៉ុណ្ណោះ បានរស់នៅជាមួយអ្នកដាក់ពាក្យសុំ។ ក្រោយមកប្រពន្ធរបស់គាត់ត្រូវបានគេចាត់តាំងឲ្យទៅធ្វើស្រែ នៅភូមិមួយផ្សេងទៀត ហើយគេអនុញ្ញាតិឲ្យប្រពន្ធគាត់ បានមកជួបក្រុមគ្រួសារត្រឹមតែពីរដងប៉ុណ្ណោះក្នុងមួយខែ។ នៅក្នុងឆ្នាំ១៩៧៧ ភរិយានិងកូនតូចរបស់អ្នកដាក់ពាក្យសុំ ត្រូវបានគេយកទៅសម្លាប់នៅទួលកកោះ រួមជាមួយគ្រួសារផ្សេងទៀតចំនួនប្រាំគ្រួសារ ដោយចោទប្រកាន់ថាពួកគេមានទំនាក់ទំនង ជាមួយសត្រូវវៀតណាម ឬជាគិញ[73]។

(៣) នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ សមាជិកគ្រួសារជាច្រើននាក់របស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឈន់ យាន (11-VSS-00143) ត្រូវបានកម្មាភិបាលខ្មែរក្រហមសម្លាប់។ នៅក្នុងខែកក្កដា ឆ្នាំ១៩៧៧ កម្មាភិបាលខ្មែរក្រហម បានចាប់ឪពុករបស់គាត់ឈ្មោះ ឈន់

---

[72] សូមមើល សំណុំរឿង ០០៣ ឯកសារ **D11/202**, ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ឡេង ណាន ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៩ នៅត្រង់ 00473548, 00473553។ សំណុំរឿង ០០៣ ឯកសារ **D11/202.1**, ឧបសម្ព័ន្ធ ១៖ ព័ត៌មានបន្ថែមរបស់ អ្នកដាក់ពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណី ថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១០ នៅត្រង់ 00588514-15។

[73] សូមមើល សំណុំរឿង ០០៣ ឯកសារ **D11/120**, ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ វ៉ែន វ៉ន VEN Vân ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៤ នៅត្រង់ 00426923។ សូមមើលផងដែរ សំណុំរឿង ០០៣ ឯកសារ **D11/120/3** កំណត់ហេតុស្តាប់ចម្លើយរបស់ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី វ៉ែន វ៉ន ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៤ នៅត្រង់ 00986178, 00986180-82។

និងពូរបស់គាត់ដែលជាអតីតមេភូមិឈ្មោះ ឃួន សេង យកទៅសម្លាប់ ដោយចោទប្រកាន់ថាពួកគេជាជនជាតិវៀតណាម។ ឪពុករបស់អ្នកដាក់ពាក្យសុំ ត្រូវបានបញ្ជូនទៅវត្តគរក្នុងភូមិគគរ ឃុំគគរ ខេត្តកំពង់ចាម ដែលបងជីដូនមួយរបស់គាត់ឈ្មោះ ឈន់ ដុង ដែលជាសន្តិសុខនៅទីនោះ បានប្រាប់គាត់ថា ឪពុករបស់គាត់ត្រូវគេធ្វើទារុណកម្មដោយឆក់ខ្សែរភ្លើង រហូតដល់គាត់ស្លាប់។ កម្មាភិបាលខ្មែរក្រហមក៏បានសម្លាប់ ឃួន សេង ដែលជាពូរបស់អ្នកដាក់ពាក្យសុំផងដែរ ដោយសារតែគេចោទថាគាត់លួចដំឡូងយកទៅហូប[74]។

(៤) បន្ទាប់ពីខ្មែរក្រហមបានគ្រប់គ្រងប្រទេស អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ថេង វណ្ណៈ (15-VSS-00139) ត្រូវបានគេបំបែកចេញពីឪពុកម្តាយរបស់គាត់ ហើយដាក់គាត់ឲ្យទៅជាទាសករ នៅក្នុងកងកុមារ ដោយត្រូវដកស្មៅនៅតាមវាលស្រែ ដោយគ្មានសម្លៀកបំពាក់ត្រឹមត្រូវ និងចំណីអាហារគ្រប់គ្រាន់។ បងប្អូនស្រីបួននាក់របស់គាត់ បានស្លាប់ដោយសារអត់អាហារនៅក្នុងសហករណ៍។ ក្រោយមកសមាជិកគ្រួសារជិតស្និទ្ធិ របស់អ្នកដាក់ពាក្យសុំមួយចំនួនត្រូវបានកម្មាភិបាលខ្មែរក្រហមសម្លាប់ចោល ដោយចោទប្រកាន់ថាជាខ្មែរក្រោម។ នៅក្នុងឆ្នាំ ១៩៧៨ ម្តាយរបស់គាត់ឈ្មោះ ប៉ាង និងប្អូនស្រីដែលជាទារិការ ត្រូវបានកម្មាភិបាលខ្មែរក្រហមសម្លាប់ ដោយសារតែពួកកម្មាភិបាលខ្មែរក្រហមជឿថា ពួកគេគឺជាខ្មែរក្រោម។ នៅក្នុងឆ្នាំ១៩៧៨ ឈ្លបខ្មែរក្រហម ព្យាយាមយកអ្នកដាក់ពាក្យសុំ និងបងប្រុសរបស់គាត់ឈ្មោះ ម៉ៅ វណ្ណា ទៅសម្លាប់ដោយមូលហេតុដូចគ្នា ប៉ុន្តែឪពុករបស់គាត់អាចជួយសង្គ្រោះពួកគេបាន នៅពាក់កណ្តាលអាធាត្រ ហើយនាំយកពួកគេត្រឡប់ទៅភូមិ ដែលគាត់រស់នៅវិញ។ ជាចុងក្រោយនៅក្នុងឆ្នាំ ១៩៧៨ សាច់ញាតិដែលនៅសេសសល់របស់ម្តាយអ្នកដាក់ពាក្យសុំ ដែលរស់នៅក្នុងភូមិមួយផ្សេងទៀត ដែលមានចំនួនសរុប២០នាក់ ត្រូវបានគេសម្លាប់ចោទទាំងអស់ ដោយសារតែពួកគេជាខ្មែរក្រោម[75]។

(៥) នៅចន្លោះពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៧ កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា បានផ្លាស់ទីលំនៅអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ប៉ែន ហឿន (11-VSS-00094) យ៉ាងហោច

---

[74] សូមមើល សំណុំរឿង ០០៣ ឯកសារ **D11/279** ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ឈន់ យាន ថ្ងៃទី០៨ ខែធ្នូ ឆ្នាំ ២០០៩ នៅត្រង់ 00472014, 00472020។

[75] សូមមើល សំណុំរឿង ០០៣ ឯកសារ **D11/497** ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ថេង វណ្ណៈ ថ្ងៃទី២១ ខែមករា ឆ្នាំ២០១០ នៅត្រង់ 01337239-40។

ណាស់ទៅកាន់ប្រាំទីតាំងផ្សេងៗគ្នា នៅក្នុងខេត្តកំពង់ចាម ដែលនៅទីនោះគាត់ត្រូវធ្វើការយ៉ាងយូរ ចាប់ពីម៉ោង៧ព្រឹក រហូតដល់ម៉ោង៨យប់ ដោយធ្វើការកសាងទំនប់ប្រឡាយ ហើយអ្នកយាម របស់ខ្មែរក្រហម ផ្តល់ដល់គាត់និងកម្មករដទៃទៀត ត្រឹមតែបបរាវសម្រាប់ហូបប៉ុណ្ណោះ។ នៅក្នុងខែមីនា ឆ្នាំ១៩៧៧ ឪពុករបស់គាត់ឈ្មោះ ប៉ែន ចន ត្រូវបានគេចាប់ខ្លួនដោយចោទប្រកាន់ថា គាត់បានផ្តល់ស្រូវដល់ពួកខ្មែរស (ចលនា "ក្រមាស" របស់ខ្មែរក្រោម)។ ពីដំបូងឪពុករបស់គាត់ ត្រូវបានឃុំខ្លួន នៅមន្ទីរសន្តិសុខស្រុក នៅឯស្រុកព្រៃឈរ ខេត្តកំពង់ចាម ហើយត្រូវបានគេបង្ខំឲ្យកសាងទំនប់និងជីកប្រឡាយ ប៉ុន្តែបន្ទាប់ពីប្រាប់ប្អូនស្រីរបស់អ្នកដាក់ពាក្យសុំថា គាត់ត្រូវគេបញ្ជូនទៅមន្ទីរសន្តិសុខតំបន់រួចមក ឪពុករបស់អ្នកដាក់ពាក្យសុំបានបាត់ខ្លួន ហើយក៏សន្មតថាគេសម្លាប់ទៅហើយ។ ដូចគ្នានេះដែរ ពូរបស់អ្នកដាក់ពាក្យសុំបួននាក់មានឈ្មោះ ហាង ផាត ហាង យយ ហាង ឆាត និងហាង កាន ត្រូវបានគេចាប់ខ្លួន ហើយបញ្ជូនទៅមន្ទីរសន្តិសុខទួលបេង នៅស្រុកកំពង់សៀម ខេត្តកំពង់ចាម ហើយបន្ទាប់មកត្រូវបានបញ្ជូន ទៅមន្ទីរសន្តិសុខមួយផ្សេងទៀត នៅក្នុងស្រុកព្រៃឈ ខេត្តកំពង់ចាម ហើយនៅទីនោះពួកគាត់ត្រូវបានគេសម្លាប់ ដោយចោទប្រកាន់ថា ក្បត់អង្គការ ហើយចូលជាមួយពួកខ្មែរស[76]។

(៦) អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ប៉ាង ស្រី (13-VSS-00730) និងក្រុមគ្រួសាររបស់គាត់ រួមទាំងឪពុករបស់គាត់ដែលជា អតីតទាហានលន់ នល់នោះ ត្រូវបានគេបញ្ជាឲ្យចាកចេញពីទីក្រុងភ្នំពេញ នៅក្នុងខែមេសា ឆ្នាំ១៩៧៥។ នៅក្នុងឆ្នាំ១៩៧៥ អ្នកដាក់ពាក្យសុំនិងក្រុមគ្រួសាររបស់គាត់ រស់នៅជា "ប្រជាជនថ្មី" នៅក្នុងសហគមន៍នៃ "ប្រជាជនមូលដ្ឋាន" នៅស្រុកអង្គរជ័យ ខេត្តកំពត រហូតដល់ពេលដែលពួកគេត្រូវបានបង្ខំ ឲ្យផ្លាស់ទីលំនៅទៅស្រុកកោះអណ្តែត ខេត្តតាកែវ នៅក្នុងឆ្នាំ១៩៧៦។ នៅទីនោះមេឃុំបានបញ្ជាដល់គ្រួសារគាត់ ឲ្យធ្វើស្រែនៅតាមដីដែលនៅជុំវិញស្ពានថ្ម ដោយឲ្យពួកគេហូបត្រឹមតែបបរាវ និងពេលខ្លះពោតក្រហមស្ងោរប៉ុណ្ណោះ។ ទោះជាបែបនេះក្តី ក៏ឪពុករបស់អ្នកដាក់ពាក្យសុំ បំពេញចប់សព្វគ្រប់ នូវភារកិច្ចដែលបានចាត់តាំងរបស់គាត់ ដោយមិនមានការតវ៉ា ដោយសារតែគាត់ខ្លាចពួកកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា រកឃើញថាគាត់ធ្លាប់ធ្វើជាទាហានលន់ នល់។ បើទោះបីជាឪពុករបស់គាត់ បានគេចផុតពីជោគវាសនារបស់អតីតទាហានលន់ នល់ ដទៃទៀត ដែលត្រូវបានគេឃុំខ្លួននៅតាមតាម

[76] សូមមើល សំណុំរឿង ០០៣ ឯកសារ **D11/178** ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ប៉ែន ហឿន ថ្ងៃទី១១ ខែមករា ឆ្នាំ២០១០ នៅត្រង់ 00563743-44, 00563748-49។

ចំណុចត្រួតពិនិត្យ ក្នុងអំឡុងពេលជម្លៀសចេញពីទីក្រុងភ្នំពេញក្តី ប៉ុន្តែនៅពេលក្រោយមកគឺក្នុងឆ្នាំ ១៩៧៨ សមមិត្ត យ៉ាត ដែលជាគណៈឃុំ បានប្រាប់ឪពុករបស់អ្នកដាក់ពាក្យសុំថា "មិត្តបាង ហេងឯងធ្លាប់ធ្វើទាហាន អោយទៅនៅមន្ទីរតាម៉នសិន ដើម្បីធ្វើប្រវត្តិរូប"។ បីថ្ងៃក្រោយមកសម មិត្តមុត បានបញ្ជាដល់ឈ្លបខ្មែរក្រហមឈ្មោះ សឹង ង៉ន ឲ្យយកឪពុកខ្ញុំតាមរទេះសេះ ទៅមន្ទីរឃុំ ឃាំងក្រាំងតាចាន់។ នៅក្នុងខែវិច្ឆិកា ឆ្នាំ១៩៧៨ ប្រជាជនមូលដ្ឋានបានប្រាប់ ក្រុមគ្រួសារអ្នកដាក់ ពាក្យសុំថា អតីតទាហានទាំងអស់ ដែលត្រូវបានបញ្ជូនទៅក្រាំងតាចាន់ ត្រូវបានគេសម្លាប់ហើ យ។ ម្តាយរបស់អ្នកដាក់ពាក្យសុំ អស់សង្ឃឹមទាំងស្រុង ហើយអ្នកដាក់ពាក្យសុំមានចិត្តក្តុកក្តួល ដោយសារតែឪពុករបស់គាត់ស្លាប់ ក្រោមស្នាដៃរបស់ខ្មែរក្រហម[77]។

(៧) អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ទូច ឈី (17-VSS-00026) ត្រូវបាន ជម្លៀសដោយបង្ខំពីផ្ទះរបស់គាត់ នៅក្នុងខេត្តប៉ៃលិន ទៅកាន់ការដ្ឋានមួយនៅក្នុងខេត្តបាត់ដំបង។ អ្នកដាក់ពាក្យសុំដែលជាអតីតទាហានលន់ នល់ បានឃើញកងកម្លាំងខ្មែរក្រហម សម្លាប់អតីត ទាហានលន់ នល់ ដទៃផ្សេងទៀតជាច្រើន នៅចំពោះមុខរបស់គាត់។ ដើម្បីលាក់ឋានៈជាទាហាន របស់គាត់ គាត់បានស្លៀកសម្លៀកបំពាក់ស៊ីវិល ហើយលាក់ប្រវត្តិរបស់គាត់។ អ្នកដាក់ពាក្យសុំ ត្រូវបានបង្ខំឲ្យធ្វើការនៅក្នុងព្រៃ ដោយមិនមានអាហារឬថ្នាំពេទ្យ ហើយបានឃើញប្រជាជនស្លូត ត្រង់ជាច្រើន បានស្លាប់ដោយសារតែអត់អាហារ ឬត្រូវខ្មែរក្រហមយកទៅសម្លាប់។ នៅក្នុងខែក ក្កដា ឬសីហា ឆ្នាំ១៩៧៦ កងទ័ពខ្មែរក្រហមបានដឹងអំពី ឋានៈជាអតីតយោធារបស់អ្នកដាក់ពាក្យ សុំ ហើយបានបញ្ជូនគាត់ទៅកាន់គុកបរវិល។ នៅក្នុងគុក គាត់ត្រូវគេធ្វើទារុណកម្មដោយឆក់ខ្សែ ភ្លើង និងធ្វើឲ្យថប់ដង្ហើម។ គាត់ទទួលបានអាហារឬទឹកផឹកតិចតួច ហើយត្រូវបានគេឃុំក្នុងបន្ទប់ មួយ ជាមួយមនុស្សដទៃទៀតចំនួន១០នាក់ ដោយចងដៃទៅក្រោយ ហើយចងជើងជាប់គ្នា។ គាត់ បានឃើញកងទ័ពខ្មែរក្រហមបាញ់អ្នកទោសដូចគ្នា នៅចំពោះមុខគាត់ជារៀងរាល់ថ្ងៃ។ ក្រោយរ យៈពេលពីរខែ គាត់ត្រូវបានដោះលែងហើយត្រឡប់ មកកាន់ការដ្ឋានរបស់គាត់វិញ ដើម្បីបន្តធ្វើ

[77] សូមមើល សំណុំរឿង ០០៣ ឯកសារ **D11/362** ទម្រង់ព័ត៌មានជនរងគ្រោះឈ្មោះ ប៉ាង ស្រី ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៣ 2013 នៅត្រង់ 01195350។

ការងារដោយបង្ខំទៀត។ នៅពេលក្រោយមក ខ្មែរក្រហមបង្ខំគាត់ឱ្យរៀបការ ជាមួយប្រពន្ធរបស់គាត់[78]។

(៨) នៅមុនខែមេសា ឆ្នាំ១៩៧៥ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ម៉ក វណ្ណា (13-VSS-00734) រស់នៅជាមួយឪពុករបស់គាត់ ដែលជានគរបាល និងជាមួយម្តាយព្រមទាំងបងប្អូនគាត់ចំនួនប្រាំពីរនាក់ នៅក្នុងទីក្រុងភ្នំពេញ។ អ្នកដាក់ពាក្យសុំនិងគ្រួសាររបស់គាត់ ត្រូវបានជម្លៀសដោយបង្ខំពីទីក្រុងភ្នំពេញ ហើយត្រូវបង្ខំឱ្យដើរទៅដល់ស្រុកអង្គរជ័យ ខេត្តតាកែវ ដោយរស់នៅជាមួយ "ប្រជាជនមូលដ្ឋាន" នៅទីនោះ ព្រមទាំងធ្វើការនិងហូបរួម។ នៅពេលបន្ទាប់មកគាត់ត្រូវបានគេបំបែកពីក្រុមគ្រួសារ ហើយនៅក្នុងឆ្នាំ១៩៧៧ គណៈឃុំបានបញ្ជាដល់អ្នកដាក់ពាក្យសុំ ឱ្យធ្វើការនៅក្នុងកងចល័តនារី ដើម្បីកសាងទំនប់នៅស្ពានត្នោតចាង។ គាត់ត្រូវធ្វើការយ៉ាងធ្ងន់ធ្ងរ ដោយរែកដីដែលត្រូវប្រើសម្រាប់ធ្វើទំនប់ ដោយធ្វើការងារក្នុងរយៈពេលយ៉ាងយូរដែលចាប់ផ្តើមពីថ្ងៃរហូតដល់យប់ ដោយទទួលបានត្រឹមតែបបររួមគ្នាមួយវែក ឬពោតក្រហមស្ងោរ សម្រាប់របបអាហាររបស់គាត់។ ប្រាំមួយខែក្រោយមក មេកងចល័តនារីបានបញ្ជូនអ្នកដាក់ពាក្យសុំ ត្រឡប់ទៅឃុំនៅកោះអណ្តែតវិញ ដើម្បីស្ទូងស្រូវទាំងថ្ងៃទាំងយប់ ព្រមទាំងធាក់រហាត់ទឹកបញ្ចូលស្រែទៀត។ នៅក្នុងឆ្នាំ១៩៧៨ ក្នុងឱកាសដ៏កម្រមួយដែលគាត់បានទៅជួបឪពុកម្តាយ ឪពុកម្តាយគាត់បានខ្សឹបប្រាប់អ្នកដាក់ពាក្យសុំថា មេភូមិខ្មែរក្រហម និងឈ្លប បានសួរពួកគេថា តើឪពុកអ្នកដាក់ពាក្យសុំធ្លាប់ធ្វើការឱ្យរដ្ឋាភិបាលលន់ នល់ដែរឬទេ ហើយពួកទាំងនោះបានប្រាប់ថា បើគាត់ធ្លាប់ធ្វើការ គេនឹងរៀបចំការងារឱ្យគាត់។ ឪពុករបស់អ្នកដាក់ពាក្យសុំបានឆ្លើយប្រាប់ពួកគេថា គាត់ជាអនុសេនីយត្រី នៅក្នុងកងកម្លាំងនគរបាលលន់ នល់។ នៅថ្ងៃទី០៨ ខែកក្កដា ឆ្នាំ១៩៧៨ អ្នកដាក់ពាក្យសុំបានឃើញកម្មាភិបាលខ្មែរក្រហមឈ្មោះ សិង ង៉ន ដឹកមនុស្សបួននាក់តាមរទេះគោ ទៅមន្ទីរតាម៉ន់ដើម្បីសួរចម្លើយ ហើយឪពុករបស់គាត់ឈ្មោះ ម៉ក ជេន ក៏នៅក្នុងចំណោមមនុស្សទាំងបួននាក់នោះដែរ។ ឪពុករបស់អ្នកដាក់ពាក្យសុំ ត្រូវបានគេសម្លាប់ ហើយប្អូន

[78] សូមមើល សំណុំរឿង ០០៣, **D11/643** ទម្រង់ព័ត៌មានជនរងគ្រោះឈ្មោះ ទូច ឈី ថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៧ នៅត្រង់ 01425408។

ប្រុសរបស់អ្នកដាក់ពាក្យសុំឈ្មោះ ម៉ក ចន្ធី ដែលជាមុខសញ្ញាដោយសារមានទំនាក់ទំនង ជាមួយឪពុករបស់អ្នកដាក់ពាក្យសុំ ជាអតីតយោធាលន់ នល់[79]

(៩) អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ស៊ុង ស៊ាង () គឺជាក្មេងប្រុសម្នាក់ដែលរស់នៅជាមួយឪពុកម្តាយ និងបងប្អូនប្រាំបីនាក់ នៅក្នុងស្រុកកណ្តៀងបច្ចុប្បន្ន ខេត្តពោធិ៍សាត់ នៅពេលដែលខ្មែរក្រហមឡើងកាន់អំណាច នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ បន្ទាប់ពីក្រុមគ្រួសាររបស់អ្នកដាក់ពាក្យសុំ ត្រូវបានគេជម្លៀសដោយបង្ខំ ទៅភូមិផ្សេងទៀតនៅក្នុងឆ្នាំ១៩៧៦ កម្មាភិបាលខ្មែរក្រហមបីនាក់ឈ្មោះ លី (ប្រុស) ឡាញ (ប្រុស) និងផេង (ស្រី) បានយកឪពុករបស់អ្នកដាក់ពាក្យសុំ ដែលជាអតីតទាហានលន់ នល់ ទៅសម្លាប់នៅវាលត្របែកក្បែរនោះ។ អ្នកដាក់ពាក្យសុំបានរត់តាមឪពុក នៅពេលដែលកម្មាភិបាលចាប់យកគាត់ទៅ ប៉ុន្តែមីងរបស់គាត់ឈ្មោះណុប បានចាប់ឃាត់អ្នកដាក់ពាក្យសុំ ទើបគាត់អាចនៅមានជីវិត។ នៅពេលក្រោយមកពួកកម្មាភិបាលដដែលនេះ បានយកបងៗអ្នកដាក់ពាក្យសុំចំនួនបីនាក់ ដែលជាអតីតទាហានលន់ នល់ យកទៅសម្លាប់ដូចគោក្របី។ បងៗរបស់អ្នកដាក់ពាក្យសុំ ត្រូវបានគេចាក់នឹងចំពុះទុង ហើយពួកឃាតករម្នាក់នៅពេលក្រោយមក បានបង្ហាញដល់អ្នកដាក់ពាក្យសុំ នូវចំពុះទុងដែលប្រឡាក់ឈាមក្រហមស្រស់ របស់បងប្រុសគាត់ ហើយបានព្រមានអ្នកដាក់ពាក្យសុំថា "បើខ្ញុំមិនកាន់ចរិតល្អទេ នោះគេនឹងយកខ្ញុំទៅសម្លាប់"។ ក្រោយនោះបន្តិចមក មីងរបស់អ្នកដាក់ពាក្យសុំឈ្មោះ ណុប ត្រូវបានចាប់ខ្លួនហើយសម្លាប់ដោយពួកកម្មាភិបាលទាំងនោះ ដោយចោទប្រកាន់ថាប្តីរបស់គាត់ គឺជាទាហានលន់ នល់។ រហូតមកដល់បច្ចុប្បន្ន អ្នកដាក់ពាក្យសុំនៅតែមានអារម្មណ៍ថា ការចងចាំអំពីការបាត់បង់សមាជិកក្រុមគ្រួសារ គឺឈឺចាប់ហួសមិនអាចទ្រាំទ្របាន[80]។

(១០) បន្ទាប់ពីខ្មែរក្រហមឡើងកាន់អំណាច នៅក្នុងខែមេសា ឆ្នាំ១៩៧៥ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ហែម ចូត (15-VSS-00136) ប្រពន្ធ និងកូនស្រីម្នាក់ កូនប្រុសពីរនាក់របស់គាត់ និងអ្នករស់នៅក្នុងភូមិជាមួយគាត់ ក្នុងស្រុកបាកាន ខេត្តពោធិ៍សាត់ ត្រូវបានបង្ខំឲ្យផ្លាស់ទីទៅនៅតំបន់ផ្សេងទៀត ដែលនៅទីនោះពួកគេត្រូវសង់ជម្រកដោយខ្លួនឯង ហើយធ្វើការនៅ

[79] សូមមើល សំណុំរឿង ០០៣ ឯកសារ **D11/365** ទម្រង់ព័ត៌មានជនរងគ្រោះឈ្មោះ ម៉ក វណ្ណា ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៣ នៅត្រង់ 01195375-77។

[80] សូមមើល សំណុំរឿង ០០៣ ឯកសារ **D11/495** ទម្រង់ព័ត៌មានជនរងគ្រោះឈ្មោះ ស៊ុង ស៊ាង ថ្ងៃទី២៧ ខែមករា ឆ្នាំ២០១០ នៅត្រង់ 01236287។

ក្នុងសហករណ៍។ អ្នកដាក់ពាក្យសុំត្រូវបានបំបែកពីក្រុមគ្រួសារ ហើយបង្ខំឱ្យចូលកងទ័ព នៅក្នុងទ័ពស្រួច២៧ ក្រោមបញ្ជាតាខ្លែង តាញៀ តាគី និងតារ៉ាន់។ អ្នកដាក់ពាក្យសុំត្រូវបានចាត់តាំង ឱ្យត្រួតពិនិត្យមើលលើសហករណ៍ចំនួនបួន ចំណែកប្រពន្ធរបស់គាត់ត្រូវបានចាត់តាំង ឱ្យធ្វើជាមេកងបង្ករបង្កើនផល។ កម្មាភិបាលខ្មែរក្រហមបានទទួលបញ្ជា ឱ្យតាមឃ្លាំមើលកងនៅក្រោមបង្គាប់របស់ពួកគេ និងឃ្លាំមើលគ្នាទៅវិញទៅមក ហើយនៅពេលដែលកម្មាភិបាលមិនគោរពតាមច្បាប់ឬគោលនយោបាយរបស់អង្គការ ឬត្រូវបានគេគិតថាមិនស្មោះត្រង់ ពួកគេនឹងត្រូវបានចាប់ខ្លួន ហើយយកទៅសម្លាប់ជាញឹកញាប់។ ហេតុដូច្នេះនៅពេលដែលអ្នកដាក់ពាក្យសុំ សម្រេច "ទុកកសាង" ដោយមិនសម្លាប់សមមិត្ត មឿន ប្រឹម ដែលត្រូវបានគេចោទប្រកាន់ថាខុសសីលធម៌នោះ អ្នកដាក់ពាក្យសុំខ្លួនគាត់ត្រូវបានគេចាប់ខ្លួន ដោយសារតែ "ការពារខ្មាំង" ហើយត្រូវគេបញ្ជូនទៅគុកត្រាចក្រោល ដែលស្ថិតនៅក្នុងស្រុកបាកាន ខេត្តពោធិ៍សាត់ ដែលនៅទីនោះគាត់ត្រូវបានផ្ដាំគុកធ្វើទារុណកម្ម និងសួរចម្លើយ។ ពីរថ្ងៃក្រោយមក អ្នកដាក់ពាក្យសុំត្រូវបានគេបញ្ជូន ឱ្យទៅធ្វើការងារធ្ងន់ដូចជា គាស់គល់ឈើនៅក្នុងបរិវេណគុក ទាំងជើងជាប់ច្រវាក់។ ស្ថានភាពរស់នៅក្នុងគុកគឺអាក្រក់ណាស់៖ អ្នកដាក់ពាក្យសុំជាប់ច្រវាក់ទាំងយប់ទាំងថ្ងៃ ហូបបាយក៏ជាប់ច្រវាក់ ពេលដេកដៃជើងទាំងពីរជាប់ច្រវាក់ ដេកនៅលើបាវអង្ករដែលមានទំហំត្រឹមពាក់កណ្ដាលខ្លួន ហើយដេកតម្រៀបគ្នាផ្ទាល់ដី ជាមួយអ្នកទោសដទៃទៀត នៅក្នុងបន្ទប់ឃុំឃាំងរួមគ្នា ហើយត្រូវបានឃ្លាំមើលដោយឆ្មាំម្នាក់ ដែលគេចាត់តាំងឱ្យមើលគាត់និងអ្នកទោសបីនាក់ផ្សេងទៀត។ អ្នកដាក់ពាក្យសុំអាចរួចជីវិតបានដោយសារតែមេគុកឈ្មោះ ចេក ដែលជាមិត្តចាស់ធ្លាប់ចូលក្នុងកងទ័ពបដិវត្តកម្ពុជា ក្នុងពេលជាមួយគ្នានោះ បានដឹងអំពីការឃុំឃាំងគាត់ ហើយបានបញ្ជាឱ្យដោះលែងគាត់វិញ។ ក្រោយជាប់ឃុំឃាំងប្រាំមួយថ្ងៃ គាត់ត្រូវបានដោះលែង ប៉ុន្តែអ្នកដាក់ពាក្យសុំមិនបានត្រឡប់ទៅកាន់ការងារដឹកនាំឡើយ ហើយគាត់ត្រូវរស់នៅក្នុងភាពភ័យខ្លាច ត្រូវគេយកទៅសម្លាប់ជារៀងរហូត[81]។

(១១) អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ណាន យ៉េម (13-VSS-00601) និងក្រុមគ្រួសាររបស់គាត់គឺជា "ប្រជាជនមូលដ្ឋាន" រស់នៅក្នុងស្រុកកោះធំ ខេត្តកណ្ដាល នៅពេលដែលខ្មែរក្រហមឡើងកាន់អំណាច នៅក្នុងឆ្នាំ១៩៧៥។ បងប្រុសរបស់អ្នកដាក់ពាក្យសុំឈ្មោះ ណាន ស្រ

---

[81] សូមមើល សំណុំរឿង ០០៣ ឯកសារ **D11/494** ទម្រង់ព័ត៌មានជនរងគ្រោះឈ្មោះ ហែម ចូត ថ្ងៃទី១៣ ខែមករា ឆ្នាំ២០០៨ នៅត្រង់ 01337245-49។

ន បានចូលកងទ័ពខ្មែរក្រហមនៅក្នុងឆ្នាំ១៩៧៤ ហើយឈរជើងនៅតាមព្រំដែនវៀតណាម។ អ្នកដាក់ពាក្យសុំត្រូវបានបង្ខំឲ្យធ្វើការ ក្រោមការតាមដានពីសំណាក់អ្នកគ្រប់គ្រងខ្មែរក្រហម នៅក្នុងកងចល័តនារី ដោយគេបញ្ជាឲ្យគាត់រែកដី ជីកប្រឡាយ លើកទំនប់ និងធាក់រហាត់ទឹកបញ្ចូលស្រែ គឺការងារដែលគ្មានពេលបញ្ចប់។ នៅក្នុងឆ្នាំ១៩៧៧ មានគេរត់ទៅការដ្ឋានរបស់អ្នកដាក់ពាក្យសុំ ដែលស្ថិតនៅក្នុងព្រៃចម្ងាយប្រមាណប្រាំគីឡូម៉ែត្រ ពីសហករណ៍របស់គាត់ ដើម្បីប្រាប់គាត់ថា ឃើញមានហ្វូងមនុស្សប្រសេចប្រសាច នៅក្រៅបរិវេណដែលគ្រួសារគាត់រស់នៅ។ នៅពេលដែលអ្នកដាក់ពាក្យសុំ រត់ត្រឡប់ទៅសហករណ៍វិញ គាត់ឃើញបងប្រុសគាត់ឈ្មោះស្រននៅទីនោះ។ បងប្រុសគាត់បានរត់ចោលជួរទ័ព ដោយសារហេតុផលខ្លះៗ ហើយកងទ័ពខ្មែរក្រហម បានតាមបងប្រុសគាត់រហូតដល់ផ្ទះ។ នៅពេលដែលបងប្រុសអ្នកដាក់ពាក្យសុំ បដិសេធមិនត្រឡប់ទៅកងគាត់វិញ កងទ័ពដទៃទៀតគម្រាមបោកគ្រាប់បែប នៅមុខរោង ហើយបន្ទាប់មកចាប់ចងស្រន ហើយបណ្តើរគាត់យកទៅឃុំឃាំងនៅមន្ទីរ១៥ នៅក្នុងឃុំពោធិទន្លេ ស្រុកកោះធំ។ ចាប់ពីពេលនោះមក គាត់លែងមានព័ត៌មានអ្វីពីបងប្រុសគាត់ ហើយក្រុមគ្រួសារអ្នកដាក់ពាក្យសុំ នៅតែមន្ទិលថាតើគាត់ត្រូវគេសម្លាប់ ឬយកទៅណានោះឡើយ។ ជាចុងក្រោយអ្នកដាក់ពាក្យសុំបានដឹងថា បងប្រុសរបស់គាត់ឈ្មោះស្រន ត្រូវបានគេបញ្ជូនទៅគុកទួលស្លែងនៅទីក្រុងភ្នំពេញ ហើយគេសម្លាប់គាត់នៅទីនោះ[82]។

(១២) អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ម៉ី សារឿន (11-VSS-00042) នាពេលដំបូងបានចូលរួមជាមួយ រណសិរ្សរួបរួមជាតិកម្ពុជា នៅពេលដែលសម្តេច សីហនុ អំពាវនាវដល់ប្រជាជនឲ្យវាយប្រយុទ្ធ ជាមួយរបបលន់ នល់។ នៅក្នុងឆ្នាំ១៩៧៦ កងកម្លាំងខ្មែរក្រហមបានដកហូតអាវុធពីគាត់ និង “កងទ័ពសម្តេចសីហនុ” ផ្សេងទៀត ហើយបញ្ជូនពួកទ័ពទាំងនេះ ទៅ “លត់ដំ” នៅខេត្តព្រៃវែង។ នៅក្នុងខេត្តព្រៃវែងគេបញ្ជាឲ្យគាត់ ធ្វើការងារធ្ងន់ធ្ងរ ដោយជីកប្រឡាយ លើកទំនប់ និងកសាងផ្លូវដ៏គ្រោះថ្នាក់មួយ ដែលកម្មករធ្វើផ្លូវ ត្រូវស្លាប់ជារៀងរាល់ថ្ងៃ ដោយសារតែគ្រឿងផ្ទុះដែលបន្សល់ពីសម័យលន់ នល់។ បន្ទាប់ពីនោះមកសោ ភឹម ដែលជាប្រធានភូមិភាគបូព៌ា បានអំពាវនាវដល់ប្រជាជននៅភូមិភាគបូព៌ា ឲ្យប្រឆាំងនឹងកងទ័ព ប៉ុល ពត ហើយអ្នកដាក់ពាក្យសុំបានចូលរួម ក្នុងការវាយប្រយុទ្ធដោយនៅខាងសោ ភឹម។ នៅពេលដែលសោ ភឹម បាញ់

---

[82] សូមមើល សំណុំរឿង ០០៣ ឯកសារ **D11/342** ទម្រង់ព័ត៌មានជនរងគ្រោះឈ្មោះ ណន យ៉េម ថ្ងៃទី១៣ ខែមករា ឆ្នាំ២០០៨ នៅត្រង់ 01210437។

សម្លាប់ខ្លួនឯង បន្ទាប់ពីវាយប្រយុទ្ធបានបីថ្ងៃរួចមក អ្នកដាក់ពាក្យសុំបានរត់គេច ប៉ុន្តែគាត់ត្រូវគេចាប់បាន ហើយយកទៅឃុំឃាំង។ កម្មាភិបាលខ្មែរក្រហមនាំគាត់ទៅវត្តគ្រញ៉ូង ក្នុងស្រុករមាសហែក ខេត្តព្រៃវែង ដោយគេឃុំឃាំងគាត់នៅទីនោះចំនួនប្រាំពីរថ្ងៃ។ គេចងដៃនិងចងបិទភ្នែកអ្នកដាក់ពាក្យសុំ ហើយគេមិនឲ្យអាហារនិងទឹកដល់គាត់ឡើយ។ គាត់និងអ្នកជាប់ឃុំដទៃទៀត ត្រូវបានគេចងអូសពីក្រោយកង់ ត្រូវគេវាយដំនិងសួរចម្លើយ អំពីការចូលរួមក្នុងការវាយប្រយុទ្ធ។ អ្នកដែលសារភាពថាពួកគេវាយប្រយុទ្ធ ជាមួយកងទ័ពរបស់ ប៉ុល ពត ត្រូវបានគេយកទៅចងនឹងគល់ដូង ហើយបាញ់សម្លាប់បោះចូលទៅក្នុងស្រះ។ ដោយសារតែអ្នកដាក់ពាក្យសុំមិនព្រមសារភាព គេក៏បញ្ជូនគាត់ត្រឡប់ទៅសហករណ៍ នៅក្នុងភូមិភាគបូព៌ាវិញទៅ។ នៅក្នុងសហករណ៍នោះ គាត់ត្រូវគេបង្ខំឲ្យរៀបការ នៅក្នុងពិធីរៀបអាពាហ៍ពិពាហ៍មួយ ដែលមាន៦១គូរ។ ប៉ុន្មានថ្ងៃក្រោយមក គឺនៅក្នុងខែកក្កដាឬសីហា ឆ្នាំ១៩៧៨ កម្មាភិបាលខ្មែរក្រហមបានជម្លៀស អ្នកដាក់ពាក្យសុំ សាច់ញាតិទាំងអស់របស់គាត់ និងប្រជាជនភូមិភាគបូព៌ាដទៃទៀត ដោយបង្ខំ ដោយធ្វើដំណើរថ្មើរជើង តាមទូកនិងរថភ្លើង ទៅខេត្តពោធិ៍សាត់ ដែលនៅទីនោះពួកគេទទួលបានក្រមាពណ៌សខៀវ ហើយតម្រូវឲ្យបង់ក្រមានេះ ដើម្បីសម្គាល់ពួកគេថាជាប្រជាជនភូមិភាគបូព៌ា។ អ្នកដាក់ពាក្យសុំនិងក្រុមគ្រួសាររបស់គាត់ ត្រូវបានគេយកទៅសហករណ៍មួយ ហើយឲ្យធ្វើការងារនៅក្នុងកងផ្សេងៗដាច់ពីគ្នា និងជាកងដែលគេរៀបចំសម្រាប់ប្រជាជន មកពីភូមិភាគបូព៌ា។ នៅចុងឆ្នាំ១៩៧៨ ឬដើមឆ្នាំ១៩៧៩ ខ្មែរក្រហមចាប់ផ្តើមសម្លាប់ជាប្រព័ន្ធ ទៅលើប្រជាជនទាំងអស់មកពីភូមិភាគបូព៌ា នៅក្នុងសហករណ៍របស់គាត់។ ថ្ងៃមួយអ្នកដាក់ពាក្យសុំ និងក្រុមគ្រួសាររបស់គាត់ ត្រូវបានគេបណ្តើរសំដៅទៅក្រោលមួយ ហើយសម្លាប់ចោលដោយចោទថាជា "ខ្មាំងយួន"។ នៅក្នុងពេលកំពុងច្របូកច្របល់នោះ អ្នកដាក់ពាក្យសុំនិងអ្នកដទៃមួយចំនួនតូច បានរត់ចេញពីទីនោះ ហើយបើទោះបីជាគាត់ត្រូវកម្មាភិបាលខ្មែរក្រហម បាញ់ត្រូវចំដៃក្តី តែគាត់អាចនៅរស់រានមានជីវិត រហូតដល់បានឃើញថ្ងៃរំដោះ។ ទោះជាបែបនេះក្តី ប៉ុន្តែសាច់ញាតិរបស់អ្នកដាក់ពាក្យសុំ យ៉ាងហោចណាស់ ៥០នាក់ ត្រូវបានសម្លាប់នៅថ្ងៃនោះ ដែលក្នុងនោះរួមមានប្រពន្ធរបស់គាត់ និងបងប្អូនគាត់បួននាក់[83]។

[83] សូមមើល សំណុំរឿង ០០៣, **D11/206/3** កំណត់ហេតុស្តាប់ចម្លើយរបស់ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ម៉ី សារឿន ថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៣ នៅត្រង់ 00978752-55, 00978757-60, 00978760, 00978763។ សំណុំរឿង ០០៣ ឯកសារ **D11/260.1** ឧបសម្ព័ន្ធ ១៖ ព័ត៌មានបន្ថែម, ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១០ នៅត្រង់ 01194873-75។ សូមមើលផងដែរ

(១៣) អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ជា ម៉ារី (17-VSS-00001) និងគ្រួសាររបស់គាត់ ត្រូវបានគេជម្លៀសដោយបង្ខំចេញពីទីក្រុងភ្នំពេញ នៅថ្ងៃទី៧ ខែមេសា ឆ្នាំ១៩៧៥។ អ្នកដាក់ពាក្យសុំនិងស្វាមីរបស់គាត់ រួមជាមួយប្អូនប្រុស ត្រូវបានគេបង្ខំឲ្យផ្លាស់ទីទៅភូមិថ្មីសេរីសាមគ្គី ដែលនៅទីនោះពួកគាត់ទទួលរងការធ្វើបាបយ៉ាងធ្ងន់ធ្ងរ ដោយពួកខ្មែរក្រហម ព្រោះតែឋានៈរបស់ពួកគាត់ជា "ប្រជាជនថ្មី"។ ខ្មែរក្រហមចង់កម្ទេចប្រជាជនថ្មីទាំងអស់ ហើយបានប្រាប់អ្នកដាក់ពាក្យសុំថា "ទុកក៏មិនចំណេញ ដកចេញក៏មិនខាត"។ នៅក្នុងភូមិអ្នកដាក់ពាក្យសុំ ត្រូវបានគេបង្ខំឲ្យធ្វើការជាទម្ងន់ ហើយមិនមានការថែទាំផ្នែកវេជ្ជសាស្ត្រឡើយ។ គាត់ធ្វើការនៅការដ្ឋានទំនប់នៅពេលថ្ងៃ ហើយនៅពេលយប់ត្រូវបានគេបង្ខំ ឲ្យប្រមូលលាមកមនុស្សនិងដី យកទៅជាធ្វើជាជី។ មានតែអ្នកដាក់ពាក្យសុំនិងនារីជនជាតិចាមម្នាក់ប៉ុណ្ណោះ ដែលត្រូវបានគេបង្ខំឲ្យប្រមូលជីលាមកមនុស្ស ហើយដោយសារតែការងារបែបនេះហើយ ទើបពួកគេត្រូវហូបតែឯង ហើយរស់នៅដាច់ឆ្ងាយពីអ្នកដទៃ។ ប្តីនិងប្អូនប្រុសរបស់គាត់ ត្រូវបានគេបញ្ជូនទៅការដ្ឋានផ្សេង ហើយពួកគាត់បានជួបគ្នាបីឬបួនខែម្តងប៉ុណ្ណោះ។ ក្រោយមកអ្នកដាក់ពាក្យសុំបានធ្លាក់ខ្លួនឈឺ ហើយសន្លប់នៅពេលធ្វើការ។ គាត់ត្រូវបានគេបញ្ជូនទៅវត្តថ្លា ជាទីតាំងសម្លាប់មនុស្ស ដែលនៅទីនោះគាត់បានឃើញមនុស្សជាច្រើន ត្រូវបានគេសម្លាប់ ជាពិសេសប្រជាជនថ្មី។ គេចាក់ថ្នាំឲ្យគាត់ ហើយបង្ខំឲ្យគាត់ផឹកទឹកពណ៌ខ្មៅ ទាំងដែលគាត់មិនដឹងថាទឹកខ្មៅនោះជាទឹកអ្វីឡើយ។ អ្នកដាក់ពាក្យសុំភ័យខ្លាចយ៉ាងខ្លាំង ព្រោះគាត់ឃើញអ្នកជំងឺជាច្រើននាក់ ដួលសន្លប់បន្ទាប់ពីផឹកថ្នាំនេះមក។ អ្នកដាក់ពាក្យសុំបានរួចខ្លួន ក្រោយពេលដែលវៀតណាមចូលមកដល់ ហើយគាត់ក៏ត្រឡប់ទៅទីក្រុងភ្នំពេញ ដើម្បីស្វែងរកសាច់ញាតិរបស់គាត់។ ជាអកុសលគាត់បានដឹងពីមីងរបស់គាត់ថា ខ្មែរក្រហមបានសម្លាប់ប្អូនប្រុសនិងឪពុករបស់គាត់ ហើយម្តាយរបស់គាត់និងបងប្អូនស្រីបីនាក់របស់គាត់ ត្រូវបានសម្លាប់ នៅពេលដែលវៀតណាមចូល។ សរុបទៅគាត់បាត់បង់សាច់ញាតិខាងឪពុក ចំនួន២៥នាក់ និងសាច់ញាតិខាងម្តាយចំនួន៩នាក់[84]។

---

សំណុំរឿង ០០៣ ឯកសារ **D11/260** ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ មុី សារឿន ថ្ងៃទី២៣ ខែមករា ឆ្នាំ២០១០ នៅត្រង់ 01313274-75។

[84] សំណុំរឿង ០០៣ ឯកសារ **D11/590** ទម្រង់ព័ត៌មានជនរងគ្រោះឈ្មោះ ជា ម៉ារី ថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៧ នៅត្រង់ 01377877-78។ សំណុំរឿង ០០២ ឯកសារ **E3/5085a** ព័ត៌មានបន្ថែមរបស់ ដើមបណ្តឹងរដ្ឋប្បវេណី ជា ម៉ារី ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៥។

(១៩) អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី យ៉ាន ញ៉ (11-VSS-00262) និងក្រុមគ្រួសាររបស់គាត់ ត្រូវបានគេជម្លៀសដោយបង្ខំក្រោមចុងកាំភ្លើង ចេញពីទីក្រុងភ្នំពេញ នៅប៉ុន្មានថ្ងៃក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ ពួកគាត់ដើរអស់រយៈពេលពីរខែ ទើបទៅដល់កន្លែងទីមួយ ហើយពួកគេត្រូវបានគេបញ្ជាឲ្យស្នាក់នៅទីនោះ។ បន្ទាប់ពីរស់នៅទីនោះបានបីខែ ពួកគាត់ត្រូវបានគេបញ្ជាឲ្យផ្លាស់ទីទៅស្រុកគីរីវង្ស ខេត្តតាកែវ។ នៅទីនោះមេខ្មែរក្រហមហៅអ្នកដាក់ពាក្យសុំ និងសមាជិកគ្រួសាររបស់ថាជា "ប្រជាជន១៧មេសា"។ ដោយហេតុនេះហើយទើបពួកគាត់ត្រូវគេធ្វើបាប ហើយរងការសង្ស័យ។ កម្មាភិបាលខ្មែរក្រហមដាក់ការងារធ្ងន់ធ្ងរខ្លាំងដល់ពួកគាត់ គឺលំបាកធ្ងន់ធ្ងរជា "ប្រជាជនមូលដ្ឋាន" នៅក្នុងសហករណ៍ ប៉ុន្តែទទួលបានរបបអាហារត្រឹមតែពាក់កណ្តាលនៃប្រជាជនមូលដ្ឋាន។ នៅក្នុងឆ្នាំ១៩៧៦ ខ្មែរក្រហមបានបញ្ជូនអ្នកដាក់ពាក្យសុំ និងក្រុមគ្រួសាររបស់គាត់ ទៅភូមិថ្មីមួយទៀត ហើយពេលទៅដល់ទីនោះ ប្តីរបស់គាត់ត្រូវបានគេចោទប្រកាន់ថាជា ទាហានលន់ នល់ និងជាភ្នាក់ងារសេអ៊ីអា។ ប្តីរបស់គាត់ហៅអ្នកដាក់ពាក្យសុំឲ្យរត់គេចជាមួយគាត់ទៅប្រទេសវៀតណាម ប៉ុន្តែអ្នកដាក់ពាក្យសុំអង្វរប្តីគាត់កុំឲ្យរត់ទៅអី ព្រោះគាត់ខ្លាចថាសមាជិកគ្រួសារដែលនៅ ត្រូវបានគេសម្លាប់ចោលជាការដាក់ទោស។ នៅក្នុងខែមិថុនា ឆ្នាំ១៩៧៦ ប្តីរបស់អ្នកដាក់ពាក្យសុំត្រូវបានគេចាប់ខ្លួន ហើយឃុំឃាំងនៅវត្តព្រៃរំដេង។ អ្នកដាក់ពាក្យសុំបានដឹងថា ក្នុងរយៈពេលបីថ្ងៃប្តីរបស់គាត់ ត្រូវបានគេធ្វើទារុណកម្ម វាយនឹងដំបង អារក និងដុតសម្លាប់ទាំងរស់។ បន្ទាប់ពីប្តីគាត់ស្លាប់ទៅ ពួកកម្មាភិបាលបានបញ្ជាឲ្យអ្នកដាក់ពាក្យសុំ ធ្វើការងារពីរដងធៀបការងារដែលគាត់ធ្វើកន្លងមក។ បើទោះបីជាគាត់ឈឺចាប់ និងកាន់ទុក្ខប្តីរបស់គាត់ដែលត្រូវគេសម្លាប់ក្តី អ្នកដាក់ពាក្យសុំបានប្រឹងប្រែងអស់ពីសមត្ថភាព ដើម្បីគោរពទៅតាមការបញ្ជានេះ ដើម្បីគេចផុតពីសេចក្តីស្លាប់។ ជាលទ្ធផលអ្នកដាក់ពាក្យសុំធ្លាក់ខ្លួនស្គមខ្លាំង នៅសល់តែស្បែកដណ្តប់ឆ្អឹង ។ បន្ទាប់មកនៅដើមឆ្នាំ១៩៧៨ មេកងរបស់គាត់បានបង្ខំអ្នកដាក់ពាក្យសុំ ឲ្យរៀបការជាមួយបុរសម្នាក់ទៀត ប៉ុន្តែគាត់ព្យាយាមប្រកែកមិនព្រមរៀបការជាច្រើនដង ដោយទទូចថាគាត់និងកូនខ្ចីរបស់គាត់ជាមួយប្តីមុនរបស់គាត់នៅក្មេងពេក មិនអាចឲ្យគាត់រៀបការម្តងទៀតបាន[85]។

[85] សូមមើល សំណុំរឿង ០០៣ ឯកសារ **D11/59** ទម្រង់ព័ត៌មានជនរងគ្រោះឈ្មោះ យ៉ាន ញ៉ ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០០៩ នៅត្រង់ 00873677-78។ សំណុំរឿង ០០៣ ឯកសារ **D11/59.1** ព័ត៌មានបន្ថែម ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១០ នៅត្រង់ 00865122 ។

(១៥) បងប្រុសអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឡុង ផាង (11-VSS-00182) ឈ្មោះ ឡុង ពាន ត្រូវបានចាប់ខ្លួននៅឯការដ្ឋានមួយ ក្នុងខេត្តក្រចេះ ដោយសារតែគាត់មិនអាចបំពេញការងារចប់ តាមផែនការដែលដាក់ឲ្យគាត់។ គាត់ត្រូវបានគេយកទៅមន្ទីរសន្តិសុខកូនង៉ែត នៅស្រុកស្នួល ខេត្តក្រចេះ ដោយចោទប្រកាន់ថា "ក្បាលយួនខ្លួនខ្មែរ" និងថាគាត់ជាភ្នាក់ងារកាហ្សេបេ។ បងប្រុសរបស់អ្នកដាក់ពាក្យសុំ ត្រូវទទួលរងការធ្វើទារុណកម្ម ដើម្បីឲ្យគាត់ព្រមឆ្លើយសារភាព ទៅតាមការចោទប្រកាន់ទាំងអស់នេះ។ នៅពេលនោះប្រធានមន្ទីរសន្តិសុខ មិនអនុញ្ញាតិឲ្យម្តាយរបស់អ្នកដាក់ពាក្យសុំ ចូលទៅមើលបងប្រុសអ្នកដាក់ពាក្យសុំឡើយ។ នៅក្នុងឆ្នាំ១៩៧៨ ប្រមាណបីខែនៃការឃុំឃាំង ឡុង ពាន ត្រូវបានគេយកទៅទីតាំងសម្លាប់មនុស្សឈ្មោះ កោះស្មារ ដែលស្ថិតនៅក្នុងស្រុកក្រចេះ ខេត្តក្រចេះ ដោយចងស្លាបសេកក្រពាត់ទៅក្រោយ ហើយចងបិតមុខទៀត។ មួយខែក្រោយមកអ្នកដាក់ពាក្យសុំបានឮថា បងប្រុសរបស់គាត់ត្រូវបានខ្មែរក្រហមសម្លាប់ ព្រោះតែគាត់មិនព្រមឆ្លើយសារភាពថាជាគិញកាហ្សេបេ[86]។

(១៦) អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី សេក ផល្លា (14-VSS-00163) រស់នៅក្នុងស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង ពេលដែលខ្មែរក្រហមឡើងកាន់អំណាច ចំណែកប្តីរបស់គាត់ឈ្មោះ ស្រី ប៊ុនថន ត្រូវបានបញ្ជូនទៅធ្វើការឆ្ងាយ នៅតំបន់មួយផ្សេងទៀត។ អ្នកដាក់ពាក្យសុំត្រូវបានបង្ខំឲ្យធ្វើការ ទាំងមិនមានរបបអាហារគ្រប់គ្រាន់។ នៅក្នុងឆ្នាំ១៩៧៧ កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា បានចោទប្រកាន់អ្នកដាក់ពាក្យសុំ និងប្តីរបស់គាត់ថាជា "ខ្សែសេអ៊ីអាខ្សែយួន" ហើយពួកគាត់ភ័យខ្លាចពីការស្លាប់ដែលមិនអាចជៀសបាន។ ពួកគាត់រួចជីវិតដោយសារតែមានប្រធានថ្មី មកជំនួសប្រធានសហករណ៍ឈ្មោះ ផាន់។ សមមិត្ត ខាន់ ប៊ីន បានយកពូរបស់អ្នកដាក់ពាក្យសុំចំនួនពីរដង ម្តងនៅក្នុងឆ្នាំ១៩៧៧ និងម្តងទៀតនៅក្នុងឆ្នាំ១៩៧៨ ទៅមន្ទីរកងពលធំ៨០១ នៅក្នុងខេត្តរតនគីរី។ នៅលើកទីពីរមេខ្មែរក្រហម បានសម្លាប់ពូរបស់គាត់ធ្វើជាគំរូ ដោយសារតែមើលងាយអង្គការ ព្រោះបណ្តោយឲ្យក្របីដែលគាត់ឃ្វាល ស៊ីសន្ទូងក្នុងស្រែ។ ក្រោយពេលសម្លាប់គាត់ហើយ ខ្មែរក្រហមមិនឲ្យក្រុមគ្រួសារអ្នកដាក់ពាក្យសុំ កាន់ទុក្ខមរណភាពរបស់ពូគាត់ ដោយធ្វើពិធីបុណ្យសពអ្វីនោះទេ។ អ្នកដាក់ពាក្យសុំបានដឹងពីបងប្អូនជីដូនមួយរបស់គាត់ថា បងប្អូនជីដូនមួយម្នាក់ទៀតឈ្មោះ ឯម ហេង ដែលជាអតីតទាហានលន់ នល់ ត្រូវបានខ្មែរក្រហមចាប់

---

[86] សូមមើល សំណុំរឿង ០០៣ ឯកសារ **D11/290** ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ឡុង ផាង ថ្ងៃទី១៧ ខែសីហា ឆ្នាំ២០០៩ នៅត្រង់ 00556746-47។

ខ្លួន ហើយឃុំខ្លួននិងសម្លាប់នៅមន្ទីរសន្តិសុខស-២១ (គុកទួលស្លែង) នៅទីក្រុងភ្នំពេញ។ នៅក្នុងឆ្នាំ ១៩៧៨ផងដែរ ប្អូនស្រីរបស់អ្នកដាក់ពាក្យសុំឈ្មោះ សេក សុខាវ៉ា ត្រូវបានបង្ខំឲ្យរៀបការជាមួយ ឈ្មោះ ខៀត ខាន់ ក្នុងពិធីមួយជាមួយគូរស្រកដទៃទៀតចំនួនប្រាំបីគូរ នៅក្នុងខេត្តស្ទឹងត្រែង[87]។

37. ម្ចាស់បណ្ដឹងឧទ្ធរណ៍ ដែលមានឈ្មោះនៅក្នុងឧបសម្ព័ន្ធ គ (ព្យសនកម្មចំពោះអ្នកដាក់ពាក្យសុំតាំងខ្លួន ជាដើមបណ្ដឹងរដ្ឋប្បវេណី ដែលបណ្ដាលមកពីការកំណត់គោលដៅ) សុទ្ធតែបានផ្ដល់ព័ត៌មានគ្រប់គ្រាន់ ដើម្បីបង្ហាញអំពីសមាជិកភាពរបស់ពួកគាត់នៅក្នុងក្រុមឬសហគមន៍គោលដៅជាក់លាក់មួយឬច្រើន ដូចដែលបានកំណត់អត្តសញ្ញាណនៅក្នុងសារណា។ ដោយផ្អែកលើមូលដ្ឋាននេះ អង្គបុរេជំនុំជម្រះគួរច្រានចោលដីកាស្ដីពីភាពអាចទទួលយកបាន ហើយសម្រេចទទួលយកម្ចាស់បណ្ដឹងឧទ្ធរណ៍ទាំងអស់នេះ ជាដើមបណ្ដឹងរដ្ឋប្បវេណីវិញ។

### ៣. ដីកាស្ដីពីភាពអាចទទួលយកបាន មានកំហុសឆ្គងបន្ថែមទៀត ទាំងលើអង្គច្បាប់និងអង្គហេតុ ដោយបដិសេធជនរងគ្រោះ ដែលមានទំនាក់ទំនងផ្ទាល់ជាមួយឧក្រិដ្ឋកម្ម ដែលត្រូវបានចោទប្រកាន់ នៅក្នុងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ

38. អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីជាច្រើនរូប ត្រូវបានចាត់ទុកថាមិនអាចទទួលយកបាន បើទោះបីជាបានទទួលរងព្យសនកម្ម ដែលកើតចេញពីគោលនយោបាយ និងឧក្រិដ្ឋកម្ម ដែលជាការទទួលខុសត្រូវរបស់ មាស មុត នៅក្នុងតំបន់ស្វយ័តកំពង់សោមក៏ដោយ។ ការនេះគឺមិនស៊ីសង្វាក់គ្នាជាមួយនឹងលក្ខណៈវិនិច្ឆ័យសម្រាប់ភាពអាចទទួលយកបាន ដែលបានកំណត់នៅក្នុងដីកាស្ដីពីភាពអាចទទួលយកបាន ដែលពិចារណាជាក់លាក់ថា "ទទួលស្គាល់អ្នកដាក់ពាក្យតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេនី ដែលការចោទប្រកាន់អំពីព្យសនកម្មរបស់ពួកគាត់ មិនចាំបាច់ទាល់តែកើត

[87] សូមមើល សំណុំរឿង ០០២ ឯកសារ **D22/1177** ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ សេក ផល្លា ថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០០៨ នៅត្រង់ 00839961-62 (ដកស្រង់ទម្រង់ព័ត៌មានជនរងគ្រោះច្បាប់ដើម នៅក្នុងសំណុំរឿង ០០២ ដោយសារតែបើទោះបីជាមានសំណើរជាលាយលក្ខណ៍អក្សររបស់អ្នកដាក់ពាក្យសុំ ក្នុងឯកសារ D11/401 ស្នើបញ្ជូនឯកសារពាក្យសុំតាំងខ្លួនរបស់គាត់ នៅក្នុងសំណុំរឿង០០២ ទៅសំណុំរឿង ០០៣ ក្ដី ប៉ុន្តែឯកសារនោះមិនបានបញ្ជូនទៅឡើយ)។ សំណុំរឿង ០០៣ ឯកសារ **D11/401** ទម្រង់ព័ត៌មានជនរងគ្រោះឈ្មោះ សេក ផល្លា ថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៥ នៅត្រង់ 01373305។ សំណុំរឿង ០០៣ ឯកសារ **D11/401/3** ព័ត៌មានបន្ថែម ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៥ នៅត្រង់ 01185681។

ឡើងពីបទឧក្រិដ្ឋ ដែលបានប្រព្រឹត្តនៅទីតាំងដែលបានកំណត់ក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ របស់សហព្រះរាជអាជ្ញា ឬនៅក្នុងដីកាដំណោះស្រាយនោះទេ”[88]។

39. បន្ថែមពីលើតួនាទីរបស់គាត់ ជាមេបញ្ជាការកងទ័ពបដិវត្តកម្ពុជា មាស មុត ក៏ជាលេខាតំបន់ស្វយ័តកំពង់សោម ដែលរួមបញ្ចូលតំបន់ដទៃទៀតដូចជា ទីរួមខេត្តកំពង់សោម រាម និងបណ្តាកោះនៅតាមតំបន់ឆ្នេរ របស់កម្ពុជាប្រជាធិបតេយ្យ[89]។ ក្នុងនាមជាលេខា មាស មុត មានអំណាចត្រួតត្រារដ្ឋបាល ទៅលើសកម្មភាពរបស់ជនស៊ីវិលដូចជា “ធ្វើស្រែ ស្បៀងអាហារ សុខភាព ចាប់ខ្លួន ការស្លាប់ និង “ស្ថានភាពខ្មាំង””[90]។ ចាប់ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៨ មាស មុត គ្រប់គ្រងទៅលើជនស៊ីវិល និងសមាជិកកងពលធំប្រមាណចំនួន ១៧.០០០នាក់[91]។ ដោយសារតែសិទ្ធអំណាចរដ្ឋបាលរបស់ មាស មុត ទៅលើតំបន់ស្វយ័តកំពង់សោម អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលទទួលរងព្យសនកម្មនៅក្នុងតំបន់នោះ គួរតែត្រូវបានប្រកាសថាអាចទទួលយកជាដើមបណ្តឹងរដ្ឋប្បវេណីបាន បើទោះបីជាព្យសនកម្មរបស់ពួកគាត់ មិនបានកើតឡើងនៅទីតាំងឧក្រិដ្ឋកម្មមួយក្នុងចំណោមទីតាំងឧក្រិដ្ឋកម្មជាក់លាក់នានានៅក្នុងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិក៏ដោយ។

40. ដូចដែលបានរៀបរាប់លម្អិតនៅក្នុង ឧបសម្ព័ន្ធ ខ (អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលទទួលរងព្យសនកម្មដោយសារការប្រព្រឹត្ត នៅទីតាំងឧក្រិដ្ឋកម្មដែលស្ថិតក្នុងវិសាលភាព នៃសំណុំរឿង០០៣) ម្ចាស់បណ្តឹងឧទ្ធរណ៍ គង់ សំណាង (11-VSS-00301),[92] ព្រំ សាម៉ុន (14-VSS-00017),[93] អន ដារ៉ាវុត (17-VSS-00043),[94] ហេង ណារី (14-VSS-00014)[95] and

---

[88] ដីកាស្តីពីភាពអាចទទួលយកបាន នៅត្រង់ កថាខណ្ឌ ៣៥ ដកស្រង់ សំណុំរឿង ០០២ ឯកសារ **D404/2/4** សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ ប្រឆាំងនឹងដីកាសម្រេចនានា របស់សហចៅក្រមស៊ើបអង្កេត លើភាពអាចទទួលយកបាន នៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៤៩, ៦៦, ៦៨, ៦៩ ដល់៧២, ៧៧។

[89]

[90]

[91]

[92] ពួរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ គង់ សំណាង ជាអតីតទាហានលន់ នល់ និងក្រុមគ្រួសាររបស់គាត់ ត្រូវបានផ្លាស់ទីដោយបង្ខំទៅឃុំវាលរិញ ស្រុកព្រៃនប់ កំពង់សោម។

[93] ក្រុមគ្រួសាររបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ ព្រំ សាម៉ុន ត្រូវបានផ្លាស់ទីដោយបង្ខំ ទៅឃុំទឹកល្អក់ ស្រុកព្រៃនប់ ខេត្តកំពង់សោម ហើយបន្ទាប់មកត្រូវបានបញ្ជូនទៅភូមិរាម ឃុំរាម ស្រុកព្រៃនប់ ខេត្តកំពង់សោម ដែលនៅទីនោះពួកគាត់ ត្រូវបានគេបង្ខំឲ្យធ្វើ

ម៉ៅ សុផល (14-VSS-00012)[96] បានទទួលរងព្យសនកម្ម ដែលជាលទ្ធផលនៃឧក្រិដ្ឋកម្ម ដែលត្រូវបានចោទប្រកាន់ប្រឆាំង មាស មុត ថាបានប្រព្រឹត្តឡើងនៅក្នុងតំបន់ស្វយ័តកំពង់សោម។ ទីតាំងនៃព្យសនកម្មរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ នៅក្នុងតំបន់ និងទីតាំងឧក្រិដ្ឋកម្ម ដែលមានចែងនៅក្នុងដីកាដំណោះស្រាយ របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានផ្តល់នូវទំនាក់ទំនងបន្ថែម រវាងព្យសនកម្មរបស់ពួកគេ ជាមួយសកម្មភាពឧក្រិដ្ឋកម្មរបស់ មាស មុត។

**ខ. មូលដ្ឋានទីពីរនៃបណ្តឹងឧទ្ធរណ៍៖ អង្គហេតុដែលបានដកចេញពីការស៊ើបអង្កេត អនុលោមតាមវិធាន ៦៦ ស្ទួន នៃវិធានផ្ទៃក្នុង អាចត្រូវបានយកមកពិចារណា ក្នុងការសម្រេចលើភាពអាចទទួលយកបានជាដើមបណ្តឹងរដ្ឋប្បវេណី**

41. តាមរយៈការកម្រិតវិសាលភាពភូមិសាស្ត្រនៃភាពអាចទទួលយកបានជាដើមបណ្តឹងរដ្ឋប្បវេណី សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានដកចេញនូវជនរងគ្រោះ ដែលអាចត្រូវបានទទួលយក នៅមុនពេលមាន*សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត កាត់បន្ថយវិសាលភាពនៃកិច្ចស៊ើបសួរតាមផ្លូវតុលាការ អនុលោមតាមវិធាន ៦៦ ស្ទួន នៃវិធានផ្ទៃក្នុង*។ លទ្ធផលនេះគឺផ្ទុយគ្នាជាមួយការបញ្ជាក់ជាក់ច្បាស់ នៅក្នុងដីកាស្តីពីភាពអាចទទួលយកបាន និងដីកាសម្រេចមុនៗ ដែលចេញដោយសហចៅក្រមស៊ើបអង្កេត ដែលថាការកាត់បន្ថយវិសាលភាព នៃការស៊ើបសួរ គឺមិនមានអនុភាពចំពោះភាពអាចទទួលយកបាន នៃអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនោះ[97]។ ហេតុដូច្នេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានកំហុសឆ្គងក្នុងការបដិសេធ មិនពិចារណា

---

ការក្នុងស្ថានភាពយ៉ាងលំបាកលំបិន។ម្ចាស់បណ្តឹងឧទ្ធរណ៍ក៏បានឃើញ សាច់ញាតិត្រូវបានគេចាប់ចង ហើយបញ្ជូនទៅចំការទុរេននៅភូមិរាមផងដែរ។

[94] ម្ចាស់បណ្តឹងឧទ្ធរណ៍ អន ដារ៉ារុត និងក្រុមគ្រួសាររបស់គាត់ ត្រូវបានខ្មែរក្រហមជម្លៀស ពីទីរួមខេត្តកំពង់សោម ទៅភូមិមួយនៅឃុំព្រៃនប់ ស្រុកព្រៃនប់ ខេត្តកំពង់សោម ដោយនៅទីនោះពួកគេត្រូវបានបង្ខំ ឱ្យធ្វើការងារក្នុងស្ថានភាពដ៏លំបាកលំបិន។

[95] ម្ចាស់បណ្តឹងឧទ្ធរណ៍ ហេង ណាវី ត្រូវបានបញ្ជូនទៅធ្វើការ នៅក្នុងកងចល័តនៅការដ្ឋានកំពង់ស្មាច ក្នុងឃុំវាលរិញ ស្រុកព្រៃនប់ ខេត្តកំពង់សោម នៅក្រោយខែកក្កដា ឆ្នាំ ១៩៧៦។ បន្ទាប់មកនៅក្នុងឆ្នាំ១៩៧៧ ឪពុកម្តាយរបស់គាត់ ត្រូវបានគេបញ្ជូនទៅធ្វើការ នៅភូមិព្រែកត្នោត ឃុំឬស្សីភូមិ ព្រែកទាល់ នៅក្នុងស្រុកព្រៃនប់ ខេត្តកំពង់សោម។

[96] ម្ចាស់បណ្តឹងឧទ្ធរណ៍ ម៉ៅ សុផល ត្រូវបានគេបញ្ជូនឱ្យទៅជួយសង់ទំនប់នៅឃុំវាលរិញ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ នៅក្នុងឆ្នាំ ១៩៧៦ និងឆ្នាំ១៩៧៧។

[97] សូមមើលដីកាស្តីពីភាពអាចទទួលយកបាន កថាខណ្ឌ ៣៩( "អង្គហេតុដែលបានដកចេញ ផ្អែកលើមូលដ្ឋាននៃវិធាន ៦៦ ស្ទួន នៃវិធានផ្ទៃក្នុង ដែលអ្នកដាក់ពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណី នៅតែអាចបង្កើតជាមូលដ្ឋាន សម្រាប់សេចក្តីសម្រេចលើភាពអាចទទួលយកបាន ប្រសិនបើអ្នកដាក់ពាក្យសុំ បានបំពេញនូវលក្ខខណ្ឌដែលនៅសល់"។

ទៅលើឧក្រិដ្ឋកម្ម ដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ក្នុងសំណុំរឿង០០៣ ដែលកើតឡើងនៅក្រៅតំបន់ស្វយ័តកំពង់សោម និងផ្ទៃទឹកព្រមទាំងបណ្តាកោះនៃឆ្នេ សមុទ្ររបស់កម្ពុជាប្រជាធិបតេយ្យ ដែលប្រការនេះបណ្តាលឲ្យមានការប៉ះពាល់យ៉ាងធ្ងន់ធ្ងរទៅលើម្ចាស់បណ្តឹងឧទ្ធរណ៍។

42. នៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៦ សហចៅក្រមស៊ើបអង្កេតបានចេញ *សំណើសុំមតិយោបល់ ទាក់ទងអង្គហេតុដែលត្រូវបានចោទប្រកាន់ តែមិនត្រូវបានស៊ើបអង្កេតបន្តរ* ដោយគូសបញ្ជាក់ពីអង្គហេតុចំនួនប្រាំពីរ ដែលត្រូវបានចោទប្រកាន់នៅក្នុងដីការសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីពីរ ដែលចៅក្រមមិនមានចេតនា ក្នុងការស៊ើបអង្កេតបន្ថែម[98]។ នៅថ្ងៃទី១០ ខែមករា ឆ្នាំ២០១៧ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចេញ *ដីកាសម្រេចកាត់បន្ថយ វិសាលភាពនៃកិច្ចស៊ើបសួរតាមផ្លូវតុលាការ អនុលោមតាមវិធាន ៦៦ ស្ទួន នៃវិធានផ្ទៃក្នុង* ដែលក្នុងដីកានោះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានដកចេញនូវការចោទប្រកាន់លើអង្គហេតុ ដោយអនុលោមតាមវិធាន ៦៦ ស្ទួន នៃវិធានផ្ទៃក្នុង ទាក់ទងនឹង (ក) មន្ទីរសន្តិសុខស-២១ (ខ) ការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង (គ) ទីតាំងសម្លាប់មនុស្សស្ទឹងតូច (ឃ) ការចូលរួមរបស់កងទ័ពបដិវត្តកម្ពុជា នៅក្នុង "ការបោសសម្អាត" ភូមិភាគកណ្តាល ភូមិភាគឧត្តរថ្មី និងភូមិភាគបូព៌ា ក្រៅពី "ការបោសសម្អាត" ដែលបានចោទប្រកាន់ ទៅលើសមាជិករបស់បណ្តាកង នៃកងទ័ពបដិវត្តកម្ពុជា ដែលស្ថិតនៅក្នុងតំបន់ទាំងនោះ[99]។ តាមវិធាន ៦៦ ស្ទួន (៣) នៃវិធានផ្ទៃក្នុង សហចៅក្រមស៊ើបអង្កេតត្រូវតែសម្រេច ពីផលប៉ះពាល់នៃសេចក្តីសម្រេច ក្នុងការកាត់បន្ថយវិសាលភាព នៃកិច្ចស៊ើបសួរតាមផ្លូវតុលាការទៅលើ "ឋានៈរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងសិទ្ធិរបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងការចូលរួមកិច្ចស៊ើបសួរ"[100]។ ការធ្វើដូច្នេះគឺសហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានបញ្ជាក់យ៉ាងជាក់ច្បាស់ថា ការដកចេញនូវអង្គហេតុខាងលើ អនុលោមតាមវិធាន ៦៦ ស្ទួន នៃវិធានផ្ទៃក្នុង នឹង "មិនប៉ះពាល់ដល់ឋានៈរបស់ដើមបណ្តឹងរដ្ឋប្បវេណី ឬសិទ្ធិ

---

[98] សំណុំរឿង ០០៣ ឯកសារ **D184** សំណើសុំមតិយោបល់ទាក់ទងនឹងការចោទប្រកាន់អំពីអង្គហេតុ ដែលនឹងមិនស៊ើបអង្កេតថែមទៀតទេ ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៦ កថាខណ្ឌ ៣ (ប្រានចោលអង្គហេតុទី៣ ដល់ទី៥ តាមវិធាន ៦៧ នៃវិធានផ្ទៃក្នុង ហើយបញ្ឈប់ការស៊ើបអង្កេតទៅលើអង្គហេតុទី១ ទី២ ទី៦ និងទី៧ តាមវិធាន៦៦ ស្ទួន នៃវិធានផ្ទៃក្នុង)។

[99] សំណុំរឿង ០០៣ ឯកសារ **D226** ដីកាសម្រេចកាត់បន្ថយវិសាលភាព នៃកិច្ចស៊ើបសួរយោងតាមវិធានផ្ទៃក្នុង ៦៦ ស្ទួន ថ្ងៃទី ១០ ខែមករា ឆ្នាំ២០១៧ កថាខណ្ឌ ៥។

[100] វិធាន ៦៦ ស្ទួន (៣) នៃវិធានផ្ទៃក្នុង។

របស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី នៅក្នុងការចូលរួមកិច្ចស៊ើបសួរឡើយ”[101] ។ ដីកាស្ដីពីភាពអាចទទួលយកបាន បានបញ្ជាក់ប្រហែលគ្នាថា អង្គហេតុដែលបានដកចេញ ដោយផ្អែកលើមូលដ្ឋាននៃវិធាន ៦៦ ស្ទួន នៃវិធានផ្ទៃក្នុង “អាចនៅតែជាមូលដ្ឋាននៃដីកាសម្រេចលើភាពអាចទទួលស្គាល់ជាដើមបណ្ដឹងរដ្ឋប្បវេណី”[102]។

43. ទោះបីជាមានការបញ្ជាក់ម្ដងហើយម្ដងទៀតថា ដីកាសម្រេចតាមវិធាន ៦៦ ស្ទួន នៃវិធានផ្ទៃក្នុង មិនប៉ះពាល់ដល់ឋានៈជាដើមបណ្ដឹងរដ្ឋប្បវេណីក្ដី ប៉ុន្តែដីកាស្ដីពីភាពអាចទទួលយកបាន បានកម្រិតទៅលើភាពអាចទទួលយកជាដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០៣ តែចំពោះ “អ្នកដាក់ពាក្យសុំដែលបានទទួលរងព្យសនកម្ម នៅតំបន់កំពង់សោម ឬនៅក្នុងដែនទឹក និងនៅលើកោះតាមឆ្នេរសមុទ្រ របស់កម្ពុជាប្រជាធិបតេយ្យ រវាងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩”[103]។ ប៉ុន្តែ វិសាលភាពពេញលេញនៃឧក្រិដ្ឋកម្ម ដែលត្រូវបានចោទប្រកាន់ពីដើមដំបូងនៅក្នុងសំណុំរឿង ០០៣ បានពង្រីកទីតាំងភូមិសាស្ត្រកាន់តែធំខ្លាំង។ សេចក្ដីសម្រេចក្នុងការកម្រិតភូមិសាស្ត្រទៅលើភាពអាចទទួលយកជាដើមបណ្ដឹងរដ្ឋប្បវេណី បានរារាំងប្រកបដោយប្រសិទ្ធិភាពដល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់នៅក្នុងសំណុំរឿងពីមុន មិនឲ្យពួកគេបន្តចូលរួមក្នុងកិច្ចដំណើរការនីតិវិធី។

44. ជាឧទាហរណ៍ ដូចដែលបានរៀបរាប់លម្អិតនៅក្នុងឧបសម្ព័ន្ធ ខ ដីកាស្ដីពីភាពអាចទទួលយកបាន បានប្រកាសថាអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ចំនួនប្រាំបីនាក់ គឺមិនអាចទទួលយកបានទេ បើទោះបីជាមានភស្តុតាងដែលបង្ហាញថា អ្នកដាក់ពាក្យសុំទាំងអស់នេះ បានទទួលរងព្យសនកម្មនៅការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង និងទីតាំងសម្លាប់មនុស្សស្ទឹងតូច ដែលជាទីតាំងឧក្រិដ្ឋកម្មពាក់ព័ន្ធចំនួនពីរដែលត្រូវបានកំណត់អត្តសញ្ញាណនៅក្នុងដីកាសន្និដ្ឋាន

[101] សំណុំរឿង ០០៣, **D226** ដីកាសម្រេចកាត់បន្ថយវិសាលភាព នៃកិច្ចស៊ើបសួរយោងតាមវិធានផ្ទៃក្នុង ៦៦ ស្ទួន ថ្ងៃទី១០ ខែមករា ឆ្នាំ២០១៧ កថាខណ្ឌ ១២។

[102] ដីកាស្ដីពីភាពអាចទទួលយកបាន កថាខណ្ឌ ៣៩។

[103] ដីកាស្ដីពីភាពអាចទទួលយកបាន កថាខណ្ឌ ៣៦។

បញ្ជូនរឿងឲ្យស៊ើបសួរលើកទីពីរ ដែលនៅពេលបន្ទាប់មកត្រូវបានដកចេញពីដីកាសម្រេចតាមវិធាន ៦៦ ស្ទួន នៃវិធានផ្ទៃក្នុង របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ[104]។

45. សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនបានពិចារណាពីការចោទប្រកាន់ជាទ្រង់ទ្រាយធំ នៅក្នុងសំណុំរឿងដើមប្រឆាំងនឹង មាស មុត ឡើយ ដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ពិចារណាតែទៅលើអ្នកទាំងឡាយណាដែលគាត់ពិចារណាថាស្ថិតនៅក្នុងវិសាលភាព ដែលបានកម្រិតកំណត់ជាថ្មីរបស់សំណុំរឿង០០៣។ សិទ្ធិរបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងការចូលរួមក្នុងកិច្ចដំណើរការនីតិវិធី ក្នុងសំណុំរឿង ០០៣ មិនអាចត្រូវបានបដិសេធចោល ដោយសារតែមូលដ្ឋានបែបនេះឡើយ។ ការសម្រេចផ្ទុយពីនេះ គឺអនុញ្ញាតឲ្យមានការអនុវត្តនីតិវិធីជាធម្មតាក្នុងគោលបំណងពន្លឿនកិច្ចដំណើរការនីតិវិធី ដកហូតសិទ្ធិជនរងគ្រោះក្នុងការចូលរួមប្រកបដោយប្រសិទ្ធិភាពនៅក្នុងកិច្ចដំណើរការនីតិវិធីដែលពាក់ព័ន្ធដោយផ្ទាល់ទៅនឹងឧក្រិដ្ឋកម្ម និងគោលនយោបាយ ដែលត្រូវបានចោទប្រកាន់ ដែលបានធ្វើឲ្យពួកគេទទួលរងនូវព្យសនកម្មយ៉ាងធំធេង។

46. បន្ថែមលើនេះ ការបកស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ អំពីផលប៉ះពាល់នៃការកាត់បន្ថយវិសាលភាពនៃកិច្ចស៊ើបសួរ គឺវាផ្ទុយពីសិទ្ធិរបស់ជនរងគ្រោះ ដែលតម្រូវឲ្យតុលាការមាន ទស្សនៈទូលំទូលាយចំពោះភាពអាចទទួលយកបានជាដើមបណ្តឹងរដ្ឋប្បវេណី។ អង្គបុរេជំនុំជម្រះបានបញ្ជាក់ច្បាស់ហើយថា បើតាមគោលការណ៍ជាសារវន្តរបស់ អ.វ.ត.ក វិធានផ្ទៃក្នុងត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍ និងសិទ្ធិរបស់ជនរងគ្រោះ[105]។ ជាពិសេស ដោយផ្អែកលើគោលដៅនៃការបង្រួបបង្រួមជាតិរបស់ អ.វ.ត.ក អង្គជំនុំជម្រះ និងចៅក្រមរបស់ អ.វ.ត.ក "ត្រូវតែយកចិត្តទុកដាក់ជាពិសេស និងធានានូវការចូលរួមប្រកបដោយអត្ថន័យរបស់ជនរង

---

[104] ម្ចាស់បណ្តឹងឧទ្ធរណ៍ ស៊ូ យឹម (11-VSS-00130) នាង ឡាយ (13-VSS-00499), ង៉ូវ ញ៉ (13-VSS-00602), អ៊ុំ នាង (14-VSS-00129) សុខ ពេជ្រ (13-VSS-00517) និង គង់ សៀក (16-VSS-00054) ឬសមាជិកគ្រួសាររបស់ពួកគាត់ សុទ្ធតែបានទទួលរងព្យសនកម្ម នៅការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង។ម្ចាស់បណ្តឹងឧទ្ធរណ៍ អួន ហាន (13-VSS-00452) និង ម៉ាន់ រយ (13-VSS-00453) សុទ្ធតែមានសមាជិកគ្រួសារ ដែលទទួលរងព្យសនកម្មនៅ ទីតាំងសម្លាប់មនុស្សស្ទឹងតូច។

[105] សំណុំរឿង ០០២ ឯកសារ **D404/2/4** សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៦១។

គ្រោះនៃអំពើឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត”[106]។ ដីកាស្តីពីភាពអាចទទួលយកបាន បានអនុវត្តផ្ទុយពីគោលដៅនេះយ៉ាងច្បាស់ក្រឡែត ដោយកម្រិតមិនសមហេតុផលទៅលើវិសាលភាពនៃភាពអាចទទួលយកបានជាដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងសំណុំរឿង០០៣។

47. ដោយផ្អែកលើការបកស្រាយខាងលើ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ស្នើសុំដល់អង្គបុរេជំនុំជម្រះសម្រេចថា ដីកាស្តីពីភាពអាចទទួលយកបាន បានបដិសេធដោយខុសឆ្គងចំពោះអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលបានកំណត់អត្តសញ្ញាណនៅក្នុងឧបសម្ព័ន្ធ ខ ដែលពួកគាត់បានទទួលរងព្យសនកម្ម ដែលជាលទ្ធផលនៃឧក្រិដ្ឋកម្ម ដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តនៅការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង និងទីតាំងសម្លាប់មនុស្សស្ទឹងតូច នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទីពីរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ដែលក្រោយមកត្រូវបានដកចេញ តាមវិធាន ៦៦ ស្ទួន នៃវិធានផ្ទៃក្នុង។

## គ. មូលដ្ឋានទីបីនៃបណ្តឹងឧទ្ធរណ៍៖ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានកំហុសឆ្គងអង្គច្បាប់ ដោយមិនបានផ្តល់សេចក្តីសម្រេចដោយមានសំអាងហេតុ សម្រាប់ការបដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី

48. ដីកាស្តីពីភាពអាចទទួលយកបាន មិនបានបំពេញតាមបទដ្ឋានអប្បបរមា ដែលអង្គបុរេជំនុំជម្រះបានកំណត់ សម្រាប់សេចក្តីសម្រេចដែលមានសំអាងហេតុ។ អង្គបុរេជំនុំជម្រះបានរំឭកដល់សហចៅក្រមស៊ើបអង្កេតថា សហចៅក្រមស៊ើបអង្កេតត្រូវតែចេញដីកាសម្រេចដោយមានសំអាងហេតុសម្រាប់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនីមួយៗ ដើម្បីគោរពដល់គោលការណ៍នីត្យានុកូលភាពជាសារវន្ត ដែលរួមមានតម្លាភាព និងសច្ចភាពផ្លូវច្បាប់[107]។ បើទោះបីជាសហចៅក្រម

[106] សំណុំរឿង ០០២ ឯកសារ **D404/2/4** សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាន នៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៦៥។ សូមមើលផងដែរ សេចក្តីសន្និដ្ឋានបឋម *ខាងលើ*។

[107] សំណុំរឿង ០០២ ឯកសារ **D411/3/6** សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ ប្រឆាំងនឹងដីកាសម្រេចនានា របស់សហចៅក្រមស៊ើបអង្កេត លើភាពអាចទទួលយកបាន នៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៣៧ ដល់៣៨។ ប្រហែលគ្នានេះ អង្គជំនុំជម្រះតុលាការកំពូលរបស់ តុលាការ ICTY បានសម្រេចថា សិទ្ធិទទួលបានសេចក្តីសម្រេចដោយមានសំអាងហេតុ គឺជាធាតុផ្សំនៃសិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ និងថា មានតែផ្អែកទៅលើមូលដ្ឋាននៃសេចក្តីសម្រេច ដោយមានសំអាងហេតុប៉ុណ្ណោះ ទើបការត្រួតពិនិត្យសមស្របនៅដំណាក់កាលបណ្តឹងឧទ្ធរណ៍អាចធ្វើទៅបាន។សូមមើល រដ្ឋអាជ្ញា តទល់នឹង *Momir Nikolic* សាលដីកាលើបណ្តឹងសាទុក្ខប្រឆាំងការផ្តន្ទាទោស ថ្ងៃទី០៨ ខែ

ស៊ើបអង្កេត មិនចាំបាច់ត្រូវរៀបរាប់លម្អិត កត្តាទាំងអស់នៅក្នុងដំណើរការសម្រេចរបស់ខ្លួនក្តី ប៉ុន្តែយ៉ាងហោចណាស់ក៏សហចៅក្រមស៊ើបអង្កេត ត្រូវតែ "បង្ហាញទាំងស្រុងនូវឯកសារសម្ភារៈ ដែលចៅក្រមបានយកមកពិចារណា នៅពេលចេញសេចក្តីសម្រេច"[108]។ ជាពិសេស សិទ្ធិក្នុងការទទួលបានការពិនិត្យនៅដំណាក់កាលបណ្តឹងឧទ្ធរណ៍ ដែលមានចែងក្នុងវិធានផ្ទៃក្នុង នឹងទៅជាគ្មានន័យ ប្រសិនបើដើមបណ្តឹងរដ្ឋប្បវេណី មិនទទួលបាននូវសំអាងហេតុនៃដីកាសម្រេច ដែលពួកគេប្តឹងឧទ្ធរណ៍នោះ។ ក្នុងន័យប្រហែលគ្នានេះ អង្គបុរេជំនុំជម្រះនឹងមិនអាចធ្វើការពិនិត្យឡើងវិញឱ្យបានត្រឹមត្រូវ និងប្រកបដោយប្រសិទ្ធិភាពទៅលើបណ្តឹងឧទ្ធរណ៍ចំពោះសេចក្តីសម្រេចបដិសេធ ដោយមិនមានការយល់ដឹងគ្រប់គ្រាន់ អំពីសំអាងហេតុជាមូលដ្ឋាននោះបានទេ ប្រសិនបើមាន[109]។

49. នៅក្នុងសំណុំរឿង ០០២ អង្គបុរេជំនុំជម្រះបានសម្រេចថា ការបដិសេធរបស់សហចៅក្រមស៊ើបអង្កេត ចំពោះពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី មិនគោរពតាមលក្ខខណ្ឌតម្រូវ នៃសេចក្តី

---

មីនា ឆ្នាំ២០០៦ សំណុំរឿង IT-02-60/1-A កថាខណ្ឌ ៩៦។ អង្គជំនុំជម្រះតុលាការកំពូល របស់តុលាការ ICTY បានសម្រេចថា "ជាកម្រិតអប្បបរមា អង្គជំនុំជម្រះសាលាដំបូង ចាំបាច់ត្រូវតែផ្តល់សំអាងហេតុ ដើម្បីគាំទ្រដល់ការសម្រេចរបស់ខ្លួន ទាក់ទងការពិចារណាលើអង្គសេចក្តី ពាក់ព័ន្ធសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ"។ រដ្ឋអាជ្ញា តទល់នឹង *Milutinovic et al.*, សាលដីកាលើបណ្តឹងសាទុក្ខបន្ទាន់បន្ទំ លើដីកាសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដោះលែង Nebojsa Pavkovic បណ្តោះអាសន្ន ថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០០៥។ រឿងក្តី IT-05-87-AR65.1, កថាខណ្ឌ ១១។ សូមមើលផងដែរ រដ្ឋអាជ្ញា តទល់នឹង *Lubanga*, ICC-01/04-01/06 -774 សាលដីកាលើបណ្តឹងសាទុក្ខរបស់លោក Thomas Lubanga Dyilo ប្រឆាំងដីកាសម្រេចរបស់អង្គបុរេជំនុំជម្រះ១ ដែលមានចំណងជើងថា "ដីកាសម្រេចលើកទីពីរ លើសំណើររបស់រដ្ឋអាជ្ញា និងសំណើដែលបានកែតម្រូវសម្រាប់ការកោសលប់ តាមវិធាន ៨១" ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៦ កថាខណ្ឌ ៣០៖ "ដោយផ្អែកទៅលើមូលដ្ឋាននៃសេចក្តីសម្រេចដោយមានសំអាងហេតុប៉ុណ្ណោះ ទើបការត្រួតពិនិត្យសមស្របនៅដំណាក់កាលបណ្តឹងឧទ្ធរណ៍ អាចធ្វើទៅបាន"។

[108] សំណុំរឿង ០០២ ឯកសារ **D411/3/6**, សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ ប្រឆាំងនឹងដីកាសម្រេចនានា របស់សហចៅក្រមស៊ើបអង្កេត លើភាពអាចទទួលយកបាន នៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ ប្រឆាំងនឹងដីកាសម្រេចនានា របស់សហចៅក្រមស៊ើបអង្កេត លើភាពអាចទទួលយកបាន នៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៣៩។

[109] សំណុំរឿង ០០២ ឯកសារ **D404/2/4** សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ ប្រឆាំងនឹងដីកាសម្រេចនានា របស់សហចៅក្រមស៊ើបអង្កេត លើភាពអាចទទួលយកបាន នៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៣៨។

សម្រេចដោយមានសំអាងហេតុ[110]។ ក្នុងករណីនោះ សហចៅក្រមស៊ើបអង្កេត មានកំហុសឆ្គង ដោយបានបដិសេធ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដោយផ្អែកលើមូលដ្ឋានទូទៅដូចជា "ទំនាក់ទំនងហេតុនិងផលចាំបាច់រវាងព្យសនកម្មដែលបានលើកឡើង និងអង្គហេតុទាំងឡាយដែលស្ថិតនៅក្រោមការស៊ើបអង្កេត មិនត្រូវបានបង្ហាញ"[111]។ បន្ថែមលើនេះ អង្គបុរេជំនុំជម្រះបានកត់សម្គាល់ថា តារាងឧបសម្ព័ន្ធដែលមានសំអាងហេតុបន្ថែមរបស់សហចៅក្រមស៊ើបអង្កេត សម្រាប់អ្នកដាក់ពាក្យសុំម្នាក់ មានយ៉ាងច្រើនបំផុតពីរឃ្លា ដែលឃ្លានីមួយៗមាន ០៥ ទៅ ១៥ពាក្យ ហើយខ្លឹមសារសម្រាប់ការច្រានចោលអ្នកដាក់ពាក្យសុំម្នាក់ៗ មិនមានភាពជាក់លាក់ ចំពោះអ្នកដាក់ពាក្យសុំនីមួយៗនោះទេ[112]។

50. សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ ត្រូវអនុវត្តក្នុងអានុភាពដូចគ្នា ចំពោះដីកាស្តីពីភាពអាចទទួលយកបាននៅទីនេះ។ កិច្ចស៊ើបសួររបស់សហចៅក្រមស៊ើបអង្កេតជាតិ បានបញ្ចប់នៅត្រឹមកម្រិតផ្នែកយុត្តាធិការ ដោយពុំបានធ្វើការវាយតម្លៃណាមួយ ទៅលើអង្គសេចក្តីជាមូលដ្ឋាន នៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីឡើយ។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានសម្រេចទៅលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ប៉ុន្តែបានច្រានចោលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីយ៉ាងច្រើនលើសលប់ជារួម ដោយពុំបានធ្វើការពិចារណាត្រឹមត្រូវលើពាក្យសុំនីមួយៗនោះឡើយ។ ដូចនៅក្នុងសំណុំរឿង០០២ដែរ សំអាងហេតុនៃការបដិសេធ គឺមានត្រឹមតែពីរបីឃ្លាខ្លីៗ ដែលគេអាចយកមកប្រើប្រាស់ឡើងវិញបានច្រើនដង ឬមិនមានសំអាងហេតុផងក៏សឹងមាន។ ជាពិសេស ដីកាស្តីពីភាពអាចទទួលយកបាន បានបដិសេធសឹងតែ៩៩ភាគរយ នៃម្ចាស់បណ្តឹងឧទ្ធរណ៍ ដោយផ្អែកលើមូលដ្ឋានជាទូទៅថា (ក) អង្គហេតុដែលបានរៀបរាប់ "ស្ថិតនៅក្រៅវិសាលភាពនៃសំណុំរឿង" (ខ) មិនបានបង្ហាញថា ម្ចាស់ប

[110] សំណុំរឿង ០០២ ឯកសារ **D411/3/6**, សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ ប្រឆាំងនឹងដីកាសម្រេចនានា របស់សហចៅក្រមស៊ើបអង្កេត លើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៣៧។

[111] សំណុំរឿង ០០២ **D411/3/6** សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេត លើភាពអាចទទួលយកបាន នៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៣៧។

[112] សំណុំរឿង ០០២ **D411/3/6** សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេត លើភាពអាចទទួលយកបាន នៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៣៧។

ណ្ដឹងឧទ្ធរណ៍ទទួលរងព្យសនកម្ម ជាផលវិបាកដោយផ្ទាល់ពីបទឧក្រិដ្ឋយ៉ាងហោចណាស់មួយ នៃបទឧក្រិដ្ឋជាច្រើន ដែលត្រូវបានចោទប្រកាន់"" ឬ (គ) អង្គហេតុ "មិនពាក់ព័ន្ធនឹងបញ្ហាណាមួយ ដែលអាចអនុញ្ញាតឲ្យអ្នកដាក់ពាក្យសុំ ចូលរួមជាដើមបណ្ដឹងរដ្ឋប្បវេណី"[113]។ ដីកាស្ដីពីភាពអាចទទួលយកបាន មិនបានផ្ដល់ការបញ្ជាក់បំភ្លឺណាមួយឡើយ អំពីអត្ថន័យនៃមូលដ្ឋានទាំងអស់នេះក្នុងការបដិសេធ ឬថាតើមូលដ្ឋានទាំងនេះអាចខុសពីគ្នាដោយរបៀបណា។ កង្វះភាពជាក់លាក់ពាក់ព័ន្ធនឹងសំអាងហេតុ សម្រាប់ការបដិសេធអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីម្នាក់ៗនេះ មិនអាចឲ្យម្ចាស់បណ្ដឹងឧទ្ធរណ៍ អនុវត្តសិទ្ធិប្ដឹងឧទ្ធរណ៍របស់ខ្លួន ប្រកបដោយអត្ថន័យនោះឡើយ។

51. ដូចដែលបានរៀបរាប់លម្អិតនៅក្នុងឧបសម្ព័ន្ធ ង (មូលដ្ឋានសម្រាប់ការសម្រេច លើភាពមិនអាចទទួលយកបាន របស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី) សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី សូមស្នើដល់អង្គបុរេជំនុំជម្រះ ច្រានចោលដីកាស្ដីពីភាពអាចទទួលយកបានក្នុងគ្រប់ករណីដែលពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ត្រូវបានសម្រេចថាមិនអាចទទួលយកបាន ដោយសារតែ "ស្ថិតនៅក្រៅវិសាលភាពនៃសំណុំរឿង" (មូលដ្ឋានទី១) ឬក្នុងករណីដែល "មិនត្រូវបានបង្ហាញថា ម្ចាស់បណ្ដឹងឧទ្ធរណ៍ទទួលរងព្យសនកម្ម ជាផលវិបាកដោយផ្ទាល់ពីបទឧក្រិដ្ឋយ៉ាងហោចណាស់មួយ នៃបទឧក្រិដ្ឋជាច្រើន ដែលត្រូវបានចោទប្រកាន់" (មូលដ្ឋានទី៣) ឬក្នុងករណីដែលអះអាងថាអង្គហេតុ "មិនពាក់ព័ន្ធនឹងបញ្ហាណាមួយ ដែលអាចអនុញ្ញាតឲ្យអ្នកដាក់ពាក្យសុំ ចូលរួមជាដើមបណ្ដឹងរដ្ឋប្បវេណី" (មូលដ្ឋានទី៨) ដោយផ្អែកលើមូលដ្ឋានថា ការបដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីទាំងនេះ មិនត្រូវបានធ្វើឡើងដោយដីកាសម្រេចដែលមានសំអាងហេតុ។

**ឃ. មូលដ្ឋានទីបួននៃបណ្ដឹងឧទ្ធរណ៍៖ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានកំហុសឆ្គងលើអង្គច្បាប់ និងអង្គហេតុ ដោយសារបដិសេធលើម្ចាស់បណ្ដឹងឧទ្ធរណ៍ ដែលមិនបានផ្ដល់ព័ត៌មានគ្រប់គ្រាន់ បើទោះបីជាបានបំពេញតាមបទដ្ឋាននៃការបង្ហាញភស្តុតាង ដែលបានតម្រូវតាមវិធានផ្ទៃក្នុង និងស្ថានសម្រាលទោសក្តី**

[113] សំណុំរឿង ០០៣ ឯកសារ **D269.2** ឧបសម្ព័ន្ធ ខ៖ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ដែលត្រូវបានប្រកាសថាមិនអាចទទួលយកបាន ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨។

52. ដីកាស្តីពីភាពអាចទទួលយកបាន មានកំហុសឆ្គងក្នុងការបដិសេធ អ្នកដាក់ពាក្យសុំ ដែលមិនបានផ្តល់ព័ត៌មានគ្រប់គ្រាន់។ ដូចដែលបានរៀបរាប់លម្អិត នៅក្នុងឧបសម្ព័ន្ធ ច (ទម្លើករណ៍នៃភាពអាចទទួលយកបាន សម្រាប់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវបានសម្រេចថាមិនអាចទទួលយកបាន ដោយសារតែពុំមានភស្តុតាង ឬមូលដ្ឋានពាក់ព័ន្ធគ្រប់គ្រាន់) បទដ្ឋានបង្ហាញភស្តុតាង និងភាពគ្រប់គ្រាន់នៃព័ត៌មាន ដែលបានតម្រូវតាមវិធានផ្ទៃក្នុង (បកស្រាយរួមគ្នាជាមួយស្ថានសម្រាលទោស ដែលបានរៀបរាប់លម្អិតដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ នៅក្នុងដីកាស្តីពីភាពអាចទទួលយកបាន) គឺត្រូវបានបំពេញដោយអ្នកដាក់ពាក្យសុំទាំងអស់នោះ។

53. វិធាន ២៣ ស្ទួន (១) និង(៤) នៃវិធានផ្ទៃក្នុង និងមាត្រា ៣.២ នៃសេចក្តីណែនាំអនុវត្តបានចែងថា ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចាំបាច់ត្រូវតែមានព័ត៌មានគ្រប់គ្រាន់ ដើម្បីធានាដល់ការពិនិត្យបញ្ជាក់អំពីភាពសមស្របជាមួយនឹងវិធានផ្ទៃក្នុង[114]។ ពិសេសទៅទៀតនោះ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ត្រូវតែមានព័ត៌មានលម្អិតអំពីអត្តសញ្ញាណនិងឋានៈជាជនរងគ្រោះឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ និងភស្តុតាងនានាអំពីព្យសនកម្មដែលបានទទួលរង ឬព័ត៌មាន "បង្ហាញអំពីពិរុទ្ធភាពរបស់ឧក្រិដ្ឋជន ដែលត្រូវបានចោទប្រកាន់"[115]។ ព័ត៌មានត្រូវបានចាត់ទុកថាគ្រប់គ្រាន់ នៅពេលដែលព័ត៌មាននោះអនុញ្ញាតិឲ្យ សហចៅក្រមស៊ើបអង្កេតជឿជាក់បានថា អង្គហេតុដែលបានអះអាង អាចជាការពិត[116]។

54. ដូចដែលបានទទួលស្គាល់ដោយអង្គបុរេជំនុំជម្រះ វិធាន ២៣ *ស្ទួន* នៃវិធានផ្ទៃក្នុង មានកម្មវត្ថុ និងគោលបំណងកំណត់លក្ខណៈវិនិច្ឆ័យសម្រាប់ភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី មិនមែនដាក់កំហិត ឬកម្រិតលើទស្សនៈនៃបណ្តឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណី

---

[114] វិធាន ២៣ ស្ទួន(១) និង(៤) នៃវិធានផ្ទៃក្នុង។ សេចក្តីណែនាំអនុវត្តរបស់ អ.វ.ត.ក ស្តីពីការចូលរួមរបស់ជនរងគ្រោះ មាត្រា ៣.២។

[115] វិធាន ២៣ ស្ទួន (៤) នៃវិធានផ្ទៃក្នុង។

[116] សំណុំរឿង ០០២ ឯកសារ **D404/2/4** សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ ប្រឆាំងនឹងដីកាសម្រេចនានា របស់សហចៅក្រមស៊ើបអង្កេត លើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៩៤។

នៅអ.វ.ត.ក ឡើយ[117]។ ការដាក់វិធាន ២៣ *ស្ទួន* នៃវិធានផ្ទៃក្នុង នៅក្នុងអនុជំពូកស្ដីពីបទប្បញ្ញត្តិទូទៅនៃជំពូកស្ដីពីនីតិវិធីនៃវិធានផ្ទៃក្នុង ចង្អុលបង្ហាញថា វិធាននេះត្រូវតែបកស្រាយស្របគ្នាជាមួយវិធាន២១ ដែលកំណត់អំពីករណីយកិច្ចជាសារវន្ត ក្នុងការការពារផលប្រយោជន៍របស់ជនរងគ្រោះ និងធានាអំពីតម្លាភាព និងសច្ចភាពផ្លូវច្បាប់[118]។

55. សហចៅក្រមស៊ើបអង្កេតត្រូវតែសម្រេចថា តើមានមូលដ្ឋានដែលអាចជឿជាក់បាន*ជាបឋម*ដែរឬទេ ដែលចង្អុលបង្ហាញថាអ្នកដាក់ពាក្យសុំ បានទទួលរងព្យសនកម្ម ដែលទាក់ទងជាមួយអង្គហេតុដែលស្ថិតក្រោមការស៊ើបអង្កេត ដោយផ្អែកលើមូលដ្ឋាននៃធាតុផ្សំនៅក្នុងសំណុំរឿង។ អង្គបុរេជំនុំជម្រះបានកត់សម្គាល់ថា ដោយសារតែកម្រិតធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម ដែលត្រូវដោះស្រាយនៅ អ.វ.ត.ក "ជាការមិនត្រឹមត្រូវ ប្រសិនបើយើងពិនិត្យមើលការខូចខាត ដែលបង្កដោយអំពើសាហាវយង់ឃ្នងជាទ្រង់ទ្រាយធំ តែទៅលើមូលដ្ឋានជាបុគ្គល ព្រោះការខូចខាតនេះគ្របដណ្ដប់ទៅលើផ្នែកជាបុគ្គលនានា"[119]។ ដោយទទួលស្គាល់អំពើសាហាវយង់ឃ្នងជាទ្រង់ទ្រាយធំ កើតចេញពីគោលនយោបាយជាប្រព័ន្ធ និងជាទ្រង់ទ្រាយធំ ដែលសំដៅទៅលើបុគ្គល ឬក្រុមជាក់លាក់ ព្រមទាំងសហគមន៍ទាំងមូលនោះ អង្គបុរេជំនុំជម្រះបានសម្រេចថា "ការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីជាបុគ្គល ត្រូវតែពិនិត្យមើលក្នុងស្ថានភាពពិសេសនៃជម្លោះ"[120]។

---

[117] សំណុំរឿង ០០២ ឯកសារ **D404/2/4** សាលដីកាលើគ្រប់បណ្ដឹងឧទ្ធរណ៍ទាំងអស់ ប្រឆាំងនឹងដីកាសម្រេចនានា របស់សហចៅក្រមស៊ើបអង្កេត លើភាពអាចទទួលយកបាន នៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៦២។

[118] សំណុំរឿង ០០២ **D404/2/4** សាលដីកាលើគ្រប់បណ្ដឹងឧទ្ធរណ៍ទាំងអស់ ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេត លើភាពអាចទទួលយកបាន នៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៦១។ សូមមើលផងដែរ សេចក្ដីសន្និដ្ឋានបឋម *ខាងលើ* ។

[119] សំណុំរឿង ០០២ ឯកសារ **D404/2/4** សាលដីកាលើគ្រប់បណ្ដឹងឧទ្ធរណ៍ទាំងអស់ ប្រឆាំងនឹងដីកាសម្រេចនានា របស់សហចៅក្រមស៊ើបអង្កេត លើភាពអាចទទួលយកបាន នៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៧០។

[120] សំណុំរឿង ០០២ **D404/2/4** សាលដីកាលើគ្រប់បណ្ដឹងឧទ្ធរណ៍ទាំងអស់ ប្រឆាំងនឹងដីកាសម្រេចនានា របស់សហចៅក្រមស៊ើបអង្កេត លើភាពអាចទទួលយកបាន នៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៧០។

56. នៅក្នុងដីកាស្តីពីភាពអាចទទួលយកបាន សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានទទួលស្គាល់កត្តាចំនួនបី ដែលសម្រាលភស្តុតាងនៃព្យសនកម្មចាំបាច់ថែមទៀត សម្រាប់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលរួមមាន៖

ក. ពេលវេលាកន្លងផុតទៅយូរ និងផលប៉ះពាល់ដែលបញ្ហានេះអាចមានមកលើលទ្ធភាពរបស់អ្នកដាក់ពាក្យសុំ ក្នុងការផ្តល់ឯកសារភស្តុតាង ពាក់ព័ន្ធនឹងព្យសនកម្មដែលខ្លួនទទួលរង ដូចជាឯកសារពេទ្យ ក្នុងករណីដែលមានការចោទប្រកាន់ អំពីព្យសនកម្មខាងរាងកាយ។

ខ. ក្រោយរបបកម្ពុជាប្រជាធិបតេយ្យ មានបញ្ហាសមត្ថភាពក្នុងការបង្ហាញ ក្នុងការឆ្លើយតប ឬធ្វើកំណត់ហេតុឲ្យបានស៊ីជម្រៅ និងត្រឹមត្រូវអំពីផលប៉ះពាល់ ដែលស្ថានភាពនៅសម័យកម្ពុជាប្រជាធិបតេយ្យ មានមកលើសុខភាពផ្លូវចិត្តរបស់ប្រជាជន។

គ. ការជម្លៀស ការប្តូរទីកន្លែង និងការផ្លាស់ទីលំនៅរបស់ប្រជាជន ទៅតាមតំបន់ផ្សេងៗ និងផលប៉ះពាល់ដែលបញ្ហានេះមាន មកលើលទ្ធភាពរបស់អ្នកដាក់ពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការផ្តល់ភស្តុតាងបញ្ជាក់អំពីកម្មសិទ្ធិ ក្នុងករណីមានការចោទប្រកាន់ អំពីការបាត់បង់ទ្រព្យសម្បត្តិ និងលទ្ធភាពក្នុងការផ្តល់ភស្តុតាង បញ្ជាក់អំពីប្រាក់ចំណូល ក្នុងករណីមានការចោទប្រកាន់អំពី ការបាត់បង់ប្រាក់ចំណូល[121]។

57. អង្គហេតុដែលថាសហចៅក្រមស៊ើបអង្កេត មិនបានជូនដំណឹងឲ្យទាន់ពេលវេលា និងបានត្រឹមត្រូវទៅដល់ជនរងគ្រោះ នៅក្នុងអំឡុងដំណើរការនីតិវិធី ដែលជាការរំលោភបំពានទៅលើវិធាន២១(១)(គ) នៃវិធានផ្ទៃក្នុង ក៏ជាកត្តាសម្រាលបន្ថែមមួយទៀតដែរ[122]។ ការទទួលបានព័ត៌មាន គឺជាការសំខាន់ជាពិសេស នៅក្នុងដំណាក់កាលមុនការជំនុំជម្រះ សម្រាប់ជនរងគ្រោះដែលអាចស្វែងរកការសុំចូលរួមជាដើមបណ្តឹងរដ្ឋប្បវេណី។ ដោយសារតែជនរងគ្រោះមិនអាចចូលពិនិត្យមើលសំណុំរឿងបាន ពួកគេត្រូវពឹងផ្អែកទាំងស្រុងទៅលើព័ត៌មានដែលផ្សព្វផ្សាយដោយសហចៅក្រមស៊ើបអង្កេត ក្នុងការធ្វើការសម្រេចថា តើពួកគេត្រូវដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែរឬ

---

[121] ដីកាស្តីពីភាពអាចទទួលយកបាន កថាខណ្ឌ ៤១។

[122] តាមវិធាន ២១ (១)(គ) នៃវិធានផ្ទៃក្នុង "អង្គជំនុំជម្រះវិសាមញ្ញ ត្រូវធានាថា ជនរងគ្រោះត្រូវទទួលបានការជូនព័ត៌មាន ហើយសិទ្ធិរបស់ជនរងគ្រោះ ត្រូវបានការពារក្នុងអំឡុងពេលនៃដំណើរការនីតិវិធីរឿងក្តី" (ដោយគូសបញ្ជាក់បន្ថែម)។

អត់។ ត្រង់ចំណុចនេះ បើទោះបីជាដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីពីរ ត្រូវបានដាក់នៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ ក៏ដោយ ក៏សហចៅក្រមស៊ើបអង្កេតមិនបានដាក់បង្ហាញដល់ជនរងគ្រោះនូវទីតាំងឧក្រិដ្ឋកម្មពាក់ព័ន្ធនានា រហូតដល់ថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១១ គឺនៅរយៈពេលពីរឆ្នាំកន្លះក្រោយ[123]។ អង្គបុរេជំនុំជម្រះគួរតែពិចារណាអំពីការរំលោភបំពានទៅលើសិទ្ធិរបស់ជនរងគ្រោះនេះ នៅពេលសម្រេចអំពីភាពគ្រប់គ្រាន់នៃភស្តុតាងរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ ដោយសារតែការដែលសហចៅក្រមស៊ើបអង្កេត មិនបានដាក់បង្ហាញព័ត៌មានដ៏សំខាន់ ឱ្យបានទាន់ពេលវេលានោះ ធ្វើឱ្យប៉ះពាល់ដល់លទ្ធភាពរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ ក្នុងការធ្វើការស៊ើបអង្កេតឱ្យបានទាន់ពេលវេលា វិភាគឱ្យបានត្រឹមត្រូវទៅលើភស្តុតាងពាក់ព័ន្ធ និងផ្តល់ព័ត៌មានលម្អិតអំពីព្យសនកម្មដែលពាក់ព័ន្ធ។

58. ដីកាស្តីពីភាពអាចទទួលយកបាន បានបដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដោយផ្អែកលើមូលដ្ឋានចំនួនបី ទាក់ទងភាពគ្រប់គ្រាន់ឬគុណភាពនៃព័ត៌មានដែលបានផ្តល់ឱ្យនៅក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី៖ (១) អ្នកដាក់ពាក្យសុំស្ថិត "ក្រៅវិសាលភាពនៃពេលវេលានៃសំណុំរឿង" (មូលដ្ឋានទី៥) (២) ពាក្យសុំតាំងខ្លួនមិនមានរយៈពេល ឬទីតាំងគ្រប់គ្រាន់ (មូលដ្ឋានទី៦) ឬ (៣) សក្ខីកម្មមិនស្របគ្នាជាមួយភស្តុតាង ឬមិនស៊ីសង្វាក់គ្នា (មូលដ្ឋានទី៧)។ ជាឧទាហរណ៍នៅក្នុងការបដិសេធដើមបណ្តឹងរដ្ឋប្បវេណីមួយ តាមមូលដ្ឋានទី៥ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានកំហុសឆ្គងដោយកម្រិតទៅលើអង្គហេតុ ដោយពិចារណាតែទៅលើការសម្លាប់ណា ដែលកើតឡើងនៅក្នុងឆ្នាំ១៩៧៣ និងឆ្នាំ១៩៧៤ ដោយមិនបានពិចារណាអំពីភស្តុតាងនៃឧក្រិដ្ឋកម្មជាច្រើនផ្សេងៗទៀត ដែលស្ថិតក្នុងវិសាលភាពសំណុំរឿង០០៣ ដែលកើតឡើងចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ឡើយ[124]។ ក្នុងករណីផ្សេងទៀត តាមមូលដ្ឋានទី៦ សហចៅក្រមស៊ើប

---

[123] សេចក្តីប្រកាសរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ស្តីពីសំណុំរឿង ០០៣ ថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១១ អាចរកមើលបាននៅគេហទំព័រ https://www.eccc.gov.kh/sites/default/files/media/ECCC%20INT-OCP%209%20May%202011%20ENG.pdf.

[124] សូមមើល ជាឧទាហរណ៍ សំអាងហេតុរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ សម្រាប់ការសម្រេចលើភាពមិនអាចទទួលយកបានរបស់អ្នកដាក់ពាក្យសុំតាងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី យ៉ាន់ សាន (11-VSS-00178) និងសហមេធាវី សម្រាប់ការដាក់សារណា នៅក្នុងឧបសម្ព័ន្ធ ច។ សំណុំរឿង ០០៣, **D269.2** ឧបសម្ព័ន្ធ ខ៖ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវបានប្រកាសថាមិនអាចទទួលយកបាន ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨។ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី បណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាសម្រេច លើភាពអាចទទួលយកបាន នៃអ្នកដាក់ពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេនី ឧបសម្ព័ន្ធ ច៖ ទឡ្ហីករណ៍លើភាពអាចទទួលយកបានរបស់អ្នកដាក់ពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវបានសម្រេចថាមិនអាច

អង្កេតអន្តរជាតិ បានកំណត់ដោយខុសឆ្គងនូវកាលបរិច្ឆេទ និងទីតាំងគន្លឹះនានាថា "មិនជាក់លាក់" ពេលដែលកាលបរិច្ឆេទនិងទីតាំងគន្លឹះទាំងនោះ ត្រូវបានរៀបរាប់យ៉ាងលម្អិតគ្រប់គ្រាន់ពិតប្រាកដ នៅក្នុងឯកសារ ដែលរួមមាននូវពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីបំពេញតាម បទដ្ឋានបង្ហាញភស្តុតាង ដែលបានតម្រូវសម្រាប់ភាពអាចទទួលយកបាន[125]។ ដូចគ្នានេះ ដើម បណ្តឹងរដ្ឋប្បវេណីជាច្រើន ត្រូវបានសម្រេចថាមិនអាចទទួលយកបានផ្អែកខ្លះ តាមមូលដ្ឋានទី៧ ដែលភាពមិនស៊ីសង្វាក់គ្នាជាក់លាក់ ដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានកំណត់នោះ គឺ មិនមានភាពច្បាស់លាស់ ហើយការពិនិត្យមើលដោយត្រឹមត្រូវទៅលើភស្តុតាង បង្ហាញថាមិនមាន ភាពមិនស៊ីសង្វាក់គ្នា ឬភាពមិនស៊ីសង្វាក់គ្នាដែលបានអះអាងនោះ គឺមិនមែនជាកត្តាកំណត់ សម្រាប់ការសម្រេចលើភាពអាចទទួលយកបាននោះទេ[126]។

59. សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សូមលើកឡើងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានកំហុសឆ្គងក្នុងការពឹងផ្អែកទៅលើមូលដ្ឋានទាំងអស់នេះ សម្រាប់ការសម្រេចបដិសេធពាក្យសុំ តាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ជនរងគ្រោះដែលបានកំណត់អត្តសញ្ញាណនៅក្នុងឧបសម្ព័ន្ធ ច។ កំហុសឆ្គងនីមួយៗ ត្រូវបានកំណត់ភ្ជាប់ជាមួយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋ ប្បវេណីនីមួយៗ នៅក្នុងឧបសម្ព័ន្ធទាំងនេះ ហើយសម្រាប់មូលហេតុដែលបានបញ្ជាក់ជូននៅទីនេះ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សូមស្នើឲ្យអង្គបុរេជំនុំជម្រះ ច្រានចោលការសម្រេច របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ លើភាពមិនអាចទទួលយកបាន ហើយផ្តល់នូវឋានៈជា ដើមបណ្តឹងរដ្ឋប្បវេណី ដល់ជនរងគ្រោះទាំងអស់នេះ។

---

ទទួលយកបាន ដោយសារតែមិនមានភស្តុតាងគ្រប់គ្រាន់ ឬដោយសារមូលដ្ឋានពាក់ព័ន្ធ (ដាក់ជាឯកសារភ្ជាប់ជាមួយ សារណា បណ្តឹងឧទ្ធរណ៍នេះ) [ចាប់ពីពេលនេះទៅគឺ "ឧបសម្ព័ន្ធ ច"]។

[125] សូមមើល ជាឧទាហរណ៍ សំអាងហេតុរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ សម្រាប់ការសម្រេចលើភាពមិនអាចទទួល យកបានរបស់អ្នកដាក់ពាក្យសុំតាងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ជា ម៉ារី (17-VSS-00001) និងសហមេធាវី សម្រាប់សារណា ដើមបណ្តឹងរដ្ឋប្បវេណី ដែលបានដាក់នៅក្នុងឧបសម្ព័ន្ធ ច។ សំណុំរឿង ០០៣ ឯកសារ **D269.2** ឧបសម្ព័ន្ធ ខ៖ ពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវបានប្រកាសថាមិនអាចទទួលយកបាន ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨។ ឧបសម្ព័ន្ធ ច។

[126] សូមមើល ជាឧទាហរណ៍ សំអាងហេតុរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ សម្រាប់ការសម្រេចលើភាពមិនអាចទទួល យកបានរបស់ អ្នកដាក់ពាក្យសុំតាងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី សឿង ឃៀង (11-VSS-00214) ព្រំ សាន (11-VSS-00264) និង ឡុង ឈឿម (11-VSS-00308) និងសហមេធាវីសម្រាប់សារណាដើមបណ្តឹងរដ្ឋប្បវេណី ដែលបានដាក់នៅក្នុង ឧបសម្ព័ន្ធ ច។ សំណុំរឿង ០០៣ ឯកសារ **D269.2** ឧបសម្ព័ន្ធ ខ៖ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវបាន ប្រកាសថាមិនអាចទទួលយកបាន ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨។ ឧបសម្ព័ន្ធ ច។

## VI. សេចក្តីសន្និដ្ឋាន

60. សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សូមលើកឡើងថា ដីកាស្តីពីភាពអាចទទួលយកបាន មានកំហុសអង្គហេតុ និងអង្គច្បាប់ ក្នុងការបដិសេធម្ចាស់បណ្តឹងឧទ្ធរណ៍សុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលបានបង្ហាញអត្តសញ្ញាណនៅក្នុងឧបសម្ព័ន្ធ ច។

61. ដោយផ្អែកលើការបកស្រាយខាងលើ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សូមគោរពស្នើសុំឱ្យអង្គបុរេជំនុំជម្រះ៖

(១) សម្រេច ជាបញ្ហាបឋម ថា អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីគ្រប់រូបនៅក្នុងសំណុំរឿង០០៣ រួមទាំងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលមានឈ្មោះនៅក្នុងឧបសម្ព័ន្ធ ក បន្តអនុវត្តសិទ្ធិជាដើមបណ្តឹងរដ្ឋប្បវេណី ក្នុងពេលមិនមានសេចក្តីសម្រេចដោយមតិភាគច្រើនលើសលប់របស់អង្គបុរេជំនុំជម្រះដែលសម្រេចផ្ទុយពីនេះ ឬជាជម្រើសមួយទៀត

(២) សម្រេចច្រានចោលដីកាស្តីពីភាពអាចទទួលយកបាន ដោយសារតែកំហុសអង្គហេតុ និងអង្គច្បាប់ ហើយពិចារណាឡើងវិញលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ នៅក្នុងឧបសម្ព័ន្ធ ក ផ្អែកលើបទដ្ឋានស្តីពីភាពអាចទទួលយកបានសមស្រប រាប់បញ្ចូលទាំងការពិចារណាទៅលើភាពពាក់ព័ន្ធនៃឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តនៅក្រៅតំបន់ស្វយ័តកំពង់សោម ឬនៅក្នុងដែនទឹក និងនៅលើកោះតាមឆ្នេរសមុទ្ររបស់កម្ពុជាប្រជាធិបតេយ្យ

(៣) ទទួលយកព័ត៌មានបន្ថែមនានា ដែលសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានដាក់ជូន

(៤) ផ្តល់ឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីដល់ម្ចាស់បណ្តឹងឧទ្ធរណ៍ទាំងអស់ និង

(៥) ជាជម្រើសមួយផ្សេងទៀត ទទួលស្គាល់ម្ចាស់បណ្តឹងឧទ្ធរណ៍ដែលមិនបានទទួលឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០៣ ជា "ដើមបណ្តឹង/អ្នកប្តឹង"។

ដោយសេចក្តីគោរព

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី៧ ខែមីនា ឆ្នាំ ២០១៩ | ជេត វណ្ណលី | រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា | |
| ថ្ងៃទី៧ ខែមីនា ឆ្នាំ ២០១៩ | ហុង គឹមសួន | រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា | |
| ថ្ងៃទី៧ ខែមីនា ឆ្នាំ ២០១៩ | ឡោ ជុនធី | រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា | |
| ថ្ងៃទី៧ ខែមីនា ឆ្នាំ ២០១៩ | សំ សុគង់ | រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា | |
| ថ្ងៃទី៧ ខែមីនា ឆ្នាំ ២០១៩ | ស៊ិន ស៊ុវ៉ន | រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា | |
| ថ្ងៃទី៧ ខែមីនា ឆ្នាំ ២០១៩ | ទី ស្រីនណា | រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា | |
| ថ្ងៃទី៧ ខែមីនា ឆ្នាំ ២០១៩ | វ៉ែន ពៅ | រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា | |
| ថ្ងៃទី៧ ខែមីនា ឆ្នាំ ២០១៩ | Martine JACQUIN | រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា | Me Martine JACQUIN |
| ថ្ងៃទី៧ ខែមីនា ឆ្នាំ ២០១៩ | Daniel MCLAUGHLIN | សាន់ហ្វ្រាន់ស៊ីស្កូ សហរដ្ឋអាមេរិក | |
| ថ្ងៃទី៧ ខែមីនា ឆ្នាំ ២០១៩ | Nushin SARKARATI | សាន់ហ្វ្រាន់ស៊ីស្កូ សហរដ្ឋអាមេរិក | |